

## បទពិសោធន៍ និងទស្សនៈរបស់ជនរួចពីរងគ្រោះស្តីពីការមាក់ងាយ នៅពេលធ្វើសមាហរណកម្មទៅសហគមន៍វិញ

# របាយការណ៍សង្ខេបសម្រាប់ការអនុវត្តន៍

## គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង

ជាគម្រោងស្រាវជ្រាវរបស់អង្គការសម្ព័ន្ធចាប់ដៃអំពីសមាហរណកម្ម ដែលសិក្សាទៅលើវដ្តជីវិតនៃជន ដែលត្រូវបានគេកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា


- អ្នកនិពន្ធ : ថដ ម៉ូរីសុន
- សហការីនិពន្ធ : ស៊ីវន ម៉ាលយ៍, លឹម វណ្ណធារី, ញ៉ាញ់ ចន្ថា, ស្រៀង ផល្លី, និងប៊ុន ដារីន



ឆ្នាំ ២០១៥

សម្ព័ន្ធចាប់ដៃ
CHAB DAI COALITION

equitas.
LOVE146.ORG
end child sex slavery & exploitation
TENTH CHURCH
imago dei fund
EARTH HEIR

# សេចក្តីថ្លែងអំណរគុណ

ដើម្បីឲ្យការស្រាវជ្រាវនេះមានដំណើរការ យើងបានសហការដៃគូជាមួយមនុស្សមួយចំនួន និងបណ្តាអង្គការជាច្រើន ហើយបានទទួលនូវការឧបត្ថម្ភគាំទ្រយ៉ាងមុតមាំពីម្ចាស់ជំនួយរបស់គម្រោងនេះ។ យើងសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់អ៊ីឃ្វីតាស់ (Equitas) ដែលជាម្ចាស់ជំនួយដើមដំបូងបំផុតរបស់គម្រោងចំពោះការជឿជាក់ និងការបន្តផ្តល់ជំនួយដល់គម្រោងនេះតាំងពីឆ្នាំកន្លងៗមក។ យើងក៏សូមអរគុណដល់ម្ចាស់ជំនួយដទៃទៀតដូចជា Tenth Church, Imago Dei, Love 146, Earth Heir និងបណ្តាម្ចាស់ជំនួយផ្សេងៗទៀតសម្រាប់ការឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្ត។

យើងសូមអរគុណចំពោះអង្គការដៃគូរបស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង។ យើងពិតជាកោតសរសើរនូវរាល់ការខ្នះខ្នែងជួយសម្របសម្រួល និងការផ្តល់ព័ត៌មានទាក់ទងនឹងអតិថិជននៅក្នុងគម្រោង។ យើងក៏សូមអរគុណចំពោះការចូលរួមផ្តល់ជាមតិវាយតម្លៃលើលទ្ធផលនៃការសិក្សា និងអនុសាសន៍នានានៅក្នុងរបាយការណ៍សិក្សារបស់យើង។ ជាពិសេស យើងក៏សូមអរគុណចំពោះអង្គការមួយចំនួនដូចជា អង្គការAgape International Mission, អង្គការ American Rehabilitation Ministries នៅបាត់ដំបង និងសៀមរាប, អង្គការប្លូមអាស៊ី, អង្គការ Cambodian Hope Organization, អង្គការ Citipointe, អង្គការកូនស្រី, អង្គការសង្គ្រោះជោគវាសនា, អង្គការហាហ្គារ, អង្គការថៃទាំសុខភាពកុមារ, អង្គការបេសកម្មយុត្តិធម៌អន្តរជាតិ, អង្គការPleroma Home for Girls, អង្គការសួននៃក្តីសង្ឃឹមកម្ពុជា, អង្គការរតនៈអន្តរជាតិ, អង្គការ Hope for Justice, អង្គការ World Hope, និងអង្គការទស្សនៈពិភពលោកកម្ពុជា។

យើងក៏សូមថ្លែងអំណរអរគុណចំពោះអ្នកចូលរួមចំណែកក្នុងគម្រោងដូចខាងក្រោម៖

- លោកស្រី ហេឡេន ស្វ៊ន ជាស្ថាបនិក និងជានាយិកាអន្តរជាតិនៃអង្គការសម្ព័ន្ធចាប់ដៃ សម្រាប់ទស្សនៈវិស័យ ការណែនាំ និងទឹកចិត្តដ៏មុតមាំចំពោះការស្រាវជ្រាវនេះ។
- លោក រស់ យ៉េង ប្រធានប្រចាំប្រទេសអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការគាំទ្រ និងលើកទឹកចិត្ត។
- កញ្ញា អោង មួយឡែន ប្រធានផ្នែកហិរញ្ញវត្ថុអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការខិតខំប្រឹងប្រែងមិនគិតពីការនឿយហត់ក្នុងការរៀបចំខ្ទង់ចំណាយ និងការទំនាក់ទំនងជាមួយម្ចាស់ជំនួយសម្រាប់គម្រោងស្រាវជ្រាវនេះ។
- លោកស្រី ស៊ីវន ម៉ាលយ៍ អ្នកប្រឹក្សាគម្រោងស្រាវជ្រាវមេអំបៅ សម្រាប់គំនិត ទស្សនៈវិស័យ និងការជ្រោមជ្រែងគាំទ្រដល់ក្រុមអ្នកស្រាវជ្រាវ។

- បណ្ឌិត Laura Cordisco Tsai ចំពោះការរួមចំណែកជាមតិវាយតម្លៃ និងអនុសាសន៍ដ៏មានតម្លៃទៅលើរបាយការណ៍ពង្រាងចុងក្រោយ។
- កញ្ញា ភឿក ផលឡៃន ចំពោះការខិតខំប្រឹងប្រែង ដោយមិនគិតពីការនឿយហត់ ក្នុងការចំលងទិន្នន័យជាសម្លេងឱ្យទៅជាអត្ថបទភាសាខ្មែរ និងបកប្រែឱ្យទៅជាភាសាអង់គ្លេស។

រូបថតទំព័រមុខដោយ៖ លោក អ៊ុំ សំអុល
រចនាទំព័រមុខដោយ៖ លោក ស្រៀង ផល្លី

ដើម្បីស្វែងរករបាយការណ៍សិក្សាទាំងមូល និងឯកសារយោងស្តីពី "***បទពិសោធន៍ និងទស្សនៈរបស់ជនរួចពីរងគ្រោះស្តីពីការមាក់ងាយនៅពេលធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍វិញ***" សូមទៅមើលនៅក្នុង៖

Morrison, Todd. Miles, Siobhan. Lim, Vanntheary. Nhanh, Channtha. Sreang, Phally. Bun, Davin. (2015), 'Survivor Experiences and Perceptions of Stigma: Reintegrating into the Community', *The Butterfly Longitudinal Research Project: A Chab Dai study on (Re-) integration: Researching the lifecycle of sexual exploitation & trafficking in Cambodia* (Phnom Penh: Chab Dai).

www.chabdai.org.
and/or
freedomcollaborative.org

# មាតិកា


**1.0 សេចក្តីផ្តើម ..... 1**

**2.0 កម្មវត្ថុនៃការសិក្សា ..... 1**

**3.0 វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ..... 1**

ទំហំនៃការសិក្សាប៉ាន់ប្រមាណ ..... 2

**4.0 លទ្ធផលនៃការសិក្សា និងការពិភាក្សា ..... 4**

**4.1 និយមន័យនៃការមាក់ងាយ ..... 4**

**4.2 ឫសគល់នៃការមាក់ងាយសង្គមនៅក្នុងប្រទេសកម្ពុជា ..... 5**

ក្រមសីលធម៌ស្តីអំពីយេនឌ័រ ..... 5

ការមាក់ងាយ និងការរើសអើងទាក់ទងនឹងបញ្ហាយេនឌ័រ ..... 8

ការមាក់ងាយពូជសាសន៍ ..... 9

**4.3 បទពិសោធន៍នៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ ..... 9**

ការមាក់ងាយនៅក្នុងចំណោមក្រុមអតិថិជន ..... 11

ក្រុមអ្នកមាក់ងាយ ..... 13

ការអនុវត្តន៍ការរើសអើង ..... 14

សេចក្តីសង្ខេបទាក់ទងនឹងការមាក់ងាយ ..... 17

កត្តាដែលមានឥទ្ធិពលលើការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ ..... 20

**4.4 ការយល់ដឹងពីការមាក់ងាយដោយខ្លួនឯង ..... 23**

ការឆ្លើយតបជាបន្តបន្ទាប់ទៅនឹងការមាក់ងាយ ..... 24

**4.5 កម្រិតនៃការមាក់ងាយ ..... 25**

**4.6 បញ្ហារុំារ៉ៃនៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ ..... 26**

ការរំលឹកប្រវត្តិអតីតកាលម្តងហើយម្តងទៀត ..... 27

ការមាក់ងាយទាក់ទងនឹងលទ្ធភាពអាពាហ៍ពិពាហ៍ ..... 28

ការបាត់បង់ឱកាសទទួលបានការអប់រំ ..... 30

អាពាហ៍ពិពាហ៍ស្របច្បាប់ ..... 31

ស្ថានភាពសុខភាព ..... 33

**4.7 វិធីសាស្ត្រដោះស្រាយសម្រាប់ការមាក់ងាយ ..... 34**

ការយកឈ្នះលើការមាក់ងាយរបស់ជនរួចពីរងគ្រោះ ..... 37

**5.0 លទ្ធផលនៃការសិក្សា និងអនុសាសន៍ ..... 41**

# បញ្ជីតារាង និងក្រាហ្វិក


តារាងទី1៖ ស្ថិតិនៃចំនួនអ្នកចូលរួមនៅក្នុងការសិក្សាប៉ាន់ប្រមាណពីឆ្នាំ ២០១១ដល់២០១៤ ........... 3

តារាងទី2៖ ប្រភេទនៃការមាក់ងាយ និងការដាក់ងារអរិជ្ជមាន ........................................................ 10

តារាងទី3៖ ការបែងចែកអត្រាប្រេវ៉ាឡង់ ដែលរៀបរាប់ដោយជនរួចពីរងគ្រោះក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងក្រុមស្ត្រី/ក្មេងស្រី RC (n=27នាក់) .......................... 12

តារាងទី4៖ អត្រាប្រេវ៉ាឡង់នៃអ្នកមាក់ងាយ ដែលស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់)បានប្រាប់ពីឆ្នាំ២០១១ដល់២០១៤ ................................................... 13

តារាងទី5៖ អត្រាប្រេវ៉ាឡង់នៃការរើសអើង ដែលស្ត្រី/ក្មេងស្រី SP/RCបានជួបប្រទះ (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់) ឆ្នាំ២០១១ដល់២០១៤................................................ 15

តារាងទី6៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រីSP/RC និងក្រុមស្ត្រី/ក្មេងស្រីRC បែងចែកតាមឆ្នាំបន្ទាប់ពីធ្វើសមាហរណកម្ម.......... 21

តារាងទី7៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយបែងចែកតាមជាតិសាសន៍ ខណៈពេលពួកគេរស់នៅក្នុងសហគមន៍ ........................................................................ 22

តារាងទី8៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រីជនជាតិខ្មែរបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និងក្រុមអ្នកចូលរួម ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤ ........................................................................................................ 23

តារាងទី9៖ ជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការជួបប្រទះនឹងការមាក់ងាយច្រើនទម្រង់ក្នុងរយៈពេលជាច្រើនឆ្នាំក្នុងចំណោមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់) ឆ្នាំ២០១១ដល់ឆ្នាំ២០១៤ ................................................................ 26

តារាងទី10៖ អត្រាប្រេវ៉ាឡង់នៃយន្តការដោះស្រាយបញ្ហាការមាក់ងាយ និងការរើសអើងដែលបានរៀបរាប់ដោយក្រុមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់ និងស្ត្រី/ក្មេងស្រីRC (n=27នាក់) ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤ ............................................................................................. 35

ការបង្ហាញទី1៖ ការពិភាក្សក្រុមតូចជាមួយជនរួចពីរងគ្រោះស្តីពីច្បាប់ស្រី ................................. 7

ក្រាហ្វិកទី1៖វដ្តនៃការមាក់ងាយទាក់ទងនឹងលទ្ធភាពអាពាហ៍ពិពាហ៍................................................ 29

## 1.0 សេចក្តីផ្តើម

ឯកសារនេះ គឺជារបាយការណ៍សិក្សាសង្ខេបដកស្រង់ពីរបាយការណ៍សិក្សាប្រធានបទរួម ដែលសិក្សាអំពី "បទពិសោធន៍ និងទស្សនៈរបស់ជនរួចពីរងគ្រោះ ស្តីពីការមាក់ងាយនៅពេលធ្វើសមាហរណកម្មទៅសហគមន៍វិញ"។ របាយការណ៍សិក្សានេះ មានបង្ហាញនូវលទ្ធផលលម្អិតនៃការសិក្សាសង្ខេប ដែលបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវទៅលើប្រធានបទរួម។ របាយការណ៍សង្ខេបនេះក៏បានផ្តល់នូវអនុសាសន៍មួយចំនួនទាក់ទងនឹងបញ្ហាការមាក់ងាយ សម្រាប់អង្គការធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ដែលកំពុងធ្វើការជាមួយជនរងគ្រោះ ឬជនរួចពីរងគ្រោះដោយការរំលោភបំពានផ្លូវភេទនេះផងដែរ។

## 2.0 កម្មវត្ថុនៃការសិក្សា

គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង គឺជាការសិក្សាស្រាវជ្រាវមួយដែលធ្វើការតាមដានជាបន្តបន្ទាប់ក្នុងរយៈពេល១០ឆ្នាំទៅលើការធ្វើសមាហរណកម្មរបស់ជនរួចពីរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវចាប់ផ្តើមក្នុងឆ្នាំ២០១០ ហើយឆ្នាំនេះគឺជាឆ្នាំទី៦នៃការសិក្សា។ គោលបំណងសំខាន់បំផុតរបស់គម្រោងសម្រាវជ្រាវមេអំបៅរយៈពេលវែង គឺដើម្បីស្តាប់ពី "សម្លេង" ផ្ទាល់របស់ជនរួចពីរងគ្រោះ ហើយតាមរយៈការស្តាប់នេះនឹងធ្វើឲ្យយើងមានការយល់ដឹងទូលំទូលាយថែមទៀតទាក់ទងនឹងទស្សនៈ និងបទពិសោធន៍នៅពេលពួកគេធ្វើសមាហរកម្មត្រលប់ទៅសហគមន៍វិញ។ តាមរយៈការផ្សព្វផ្សាយពី "សម្លេង" របស់ពួកគេ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងក្នុងថ្នាក់ស្រុក ថ្នាក់តំបន់ និងសាកលលោក អង្គការសម្ព័ន្ធចាប់ដៃយើង សង្ឃឹមជឿជាក់ថាកម្មវិធី និងគោលនយោបាយធ្វើសមាហរកម្មនានានឹងទទួលបានព័ត៌មាន និងមានភាពវិវឌ្ឍន៍ទៅមុខដើម្បីឲ្យជីវិតរបស់ជនរួចផុតពីការកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទ មានភាពល្អប្រសើរ ឡើង។

របាយការណ៍សិក្សាតាមប្រធានបទនេះមានគោលបំណងដើម្បីរៀបចំចងក្រងជាឯកសារ និងពិព័ណ៌នារៀបរាប់ពីការមាក់ងាយ និងការរើសអើង ដែលជនរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទប្រឈមនៅក្នុងសហគមន៍របស់ពួកគេ។ របាយការណ៍នេះក៏មានគោលបំណងកំណត់ពីបញ្ហារុំរ៉ៃមួយចំនួនជុំវិញបញ្ហាការមាក់ងាយនៅក្នុងចំណោមជនរួចពីរងគ្រោះ ព្រមទាំងបង្ហាញឲ្យឃើញផងដែរពីវិធីសាស្រ្ត និងយន្តការនានា ដែលពួកគេបានរៀបរាប់ប្រាប់នៅពេលពួកគេបានជួបប្រទះការមាក់ងាយនៅក្នុងសង្គមកម្ពុជា។

## 3.0 វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ

គម្រោងសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែង បានប្រើប្រាស់វិធីសាស្រ្តស្រាវជ្រាវចម្រុះក្នុងរយៈពេលជាង៥ឆ្នាំមកនេះ (មើលនៅក្នុង MILES AND MILES 2010; MILES AND MILES 2011; MILES ET AL. 2012; MILES ET AL. 2013, MILES ET AL. 2014)។ ក្រុមស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ

(បញ្ជីសំណួរ) ដែលមានសួរទាំងសំណួរបែបទម្រង់សំណួរបិទ និងសំណួរបើក។ ក្រុមស្រាវជ្រាវនេះក៏បានប្រើប្រាស់សកម្មភាពមួយចំនួនផ្សេងទៀត ក្នុងការប្រមូលទិន្នន័យបែបគុណវិស័យដូចជា ការពិភាក្សាក្រុមតូច (FGD) ការសម្ភាសន៍បែបស៊ីជម្រៅ ការសម្ភាសន៍មិនផ្លូវការ ការលេងល្បែងកំសាន្តគំនូរ និងការសង្កេតទៅលើអ្នកចូលរួមការស្រាវជ្រាវជាដើម។ ហើយក្រៅពីនោះ ដើម្បីនៅតែអាចបន្តប្រមូលព័ត៌មានពីអ្នកចូលរួមការស្រាវជ្រាវ ដែលបានធ្វើចំណាកស្រុកបាន (ឧទាហរណ៍៖ ចំណាកស្រុកទៅប្រទេសថៃ) ឬផ្លាស់ប្តូរទៅទីលំនៅទៅរស់នៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ក្រុមស្រាវជ្រាវក៏បានធ្វើការសម្ភាសន៍ជាមួយពួកគេតាមទូរសព្ទដែរ។ ការប្រើប្រាស់វិធីសាស្រ្តចម្រុះនេះ បានធ្វើឲ្យក្រុមសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែងបានទទួលនូវព័ត៌មានយ៉ាងទូលំទូលាយ ស្តីពីដំណើរជីវិតរបស់អ្នកចូលរួមនៅក្នុងការសិក្សា (ជនរួចពីរងគ្រោះ)។

នៅពាក់កណ្តាលនៃអាយុគម្រោងស្រាវជ្រាវដ៏ធំមួយនេះ ក្រុមស្រាវជ្រាវបានរៀបចំករណីសិក្សាមូលដ្ឋានមួយវិភាគទៅលើជីវិតរបស់អតិថិជននីមួយៗ។ ទិន្នន័យទាំងបែបគុណវិស័យ និងបរិមាណវិស័យប្រមូលបានជាងបួនឆ្នាំកន្លងមកនេះត្រូវបានប្រមូល និងសង្ខេបឡើងវិញនូវអ្វីដែលគម្រោងដឹង ដើម្បីជៀសវាងការបាត់បង់សាច់រឿងរបស់អតិថិជនម្នាក់ៗ។ ករណីសិក្សានេះ វិភាគទិន្នន័យលម្អិតសង្ខេបបែបគុណវិស័យរបស់អតិថិជនម្នាក់ៗទាំងអស់នៅក្នុងគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង។ ការសិក្សាស្រាវជ្រាវបែបគុណវិស័យត្រូវបានធ្វើឡើង ហើយព័ត៌មានទាំងនោះត្រូវបានបញ្ចូលបន្ថែមជាបន្តបន្ទាប់ទៅក្នុងកម្រងព័ត៌មានលំអិតសង្ខេប ដើម្បីឲ្យទិន្នន័យរបស់អតិថិជនម្នាក់ៗនោះក្លាយជាទិន្នន័យបែបរយៈពេលវែងចំពោះអតិថិជនចូលរួមនៅក្នុងការសិក្សានេះភាគច្រើន។

## ទំហំនៃការសិក្សាប៉ាន់ប្រមាណ

ការសិក្សាប៉ាន់ប្រមាណតាមប្រធានបទនេះ មានស្ត្រីជាអ្នកចូលរួមក្នុងការសិក្សាចំនួន៦០នាក់ដែលមកពីក្រុមផ្សេងៗគ្នា (មើលនៅក្នុងតារាងទី១)។ ការសិក្សាប៉ាន់ប្រមាណនេះសិក្សាផ្តោតទៅលើការឆ្លើយតបរបស់ក្រុមស្ត្រីពាក់ព័ន្ធនឹងការមាក់ងាយតែក្នុងសហគមន៍ប៉ុណ្ណោះ គឺមានតែស្ត្រីដែលត្រូវបានកម្មវិធីមណ្ឌលធ្វើសមាហរណកម្មប៉ុណ្ណោះ ដែលត្រូវបានក្រុមស្រាវជ្រាវជ្រើសរើសសម្រាប់ការសិក្សានេះ។ ស្ត្រីដែលត្រូវបានដាក់បញ្ចូលនៅក្នុងការសិក្សានេះ លុះត្រាតែពួកគេបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវយ៉ាងហោចណាស់បាន៤ជំនួប គិតជារយៈពេលស្មើនឹងពីរឆ្នាំស្ថិតក្នុងការសិក្សា។ អតិថិជននៅក្នុងការសិក្សាត្រូវបានដាក់ជាក្រុមដោយផ្អែកទៅលើបទពិសោធន៍ ថាតើពួកគេធ្លាប់ស្នាក់នៅក្នុង កម្មវិធីមណ្ឌលមុនពេលធ្វើ សមាហរណកម្មទៅសហគមន៍វិញយ៉ាងហោចណាស់៤ខែដែរ ឬទេ។ ក្រុមអតិថិជនត្រូវបានបែងចែកជាក្រុមដូចខាងក្រោម៖

1. ក្រុមស្ត្រី/ក្មេងស្រី SP/RC គឺជាស្ត្រី/ក្មេងស្រី ដែលធ្លាប់ស្នាក់នៅក្នុងកម្មវិធីមណ្ឌល ហើយបានធ្វើសមាហរណកម្មទៅសហគមន៍
2. ក្រុមស្ត្រី/ក្មេងស្រី RC គឺជាស្ត្រី/ក្មេងស្រី ដែលមិនដែលបានស្នាក់នៅក្នុងកម្មវិធីមណ្ឌលសោះ (ឬធ្លាប់ស្នាក់នៅតិចជាង៤ខែ) ហើយបានធ្វើសមាហរណកម្មទៅសហគមន៍វិញ។

បណ្តាទិន្នន័យរយៈពេលវែងមួយចំនួន ដែលទាក់ទងទៅនឹងប្រធានបទស្តីពីការមាក់ងាយត្រូវបានប្រមូលចងក្រងនៅក្នុងការប៉ាន់ប្រមាណនេះ។ ទិន្នន័យទាំងនេះរួមបញ្ចូលទាំង ការឆ្លើយតបរបស់អតិថិជន ឥរិយាបថ ផ្នត់គំនិត និងបទពិសោធន៍នានារបស់ពួកគេទាក់ទងនឹង "ការមាក់ងាយ" "ក្រុមមនុស្សដែលធ្វើការមាក់ងាយ" "បទពិសោធន៍ការរើសអើង" "ការឆ្លើយតប និងវិធីដោះស្រាយរបស់ជនរួចពីរងគ្រោះទៅនឹងការមាក់ងាយ" ។ ការឆ្លើយតបរបស់អ្នកចូលរួមសិក្សាម្នាក់ៗត្រូវបានយកមកបូកបញ្ចូលចងក្រងតាមឆ្នាំដែលបានចុះសម្ភាសន៍។ ដោយហេតុនេះ ការសិក្សាតាមដានទៅលើអ្នកចូលរួមក្នុងការសិក្សាម្នាក់ៗតាមឆ្នាំនីមួយៗត្រូវបានធ្វើឡើងជាង៤ឆ្នាំពេញ ដែលទិន្នន័យទាំងនោះបានប្រមូលតាំងពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤។ ទិន្នន័យតាមលំដាប់ឆ្នាំនីមួយៗនេះក៏ត្រូវបានយកមកប្រើប្រាស់នៅក្នុងការសិក្សានៃរបាយការណ៍នេះផងដែរ។

**តារាងទី1៖ ស្ថិតិនៃចំនួនអ្នកចូលរួមនៅក្នុងការសិក្សាប៉ាន់ប្រមាណពីឆ្នាំ ២០១១ដល់២០១៤**

| Assessment Groups | Starting Ages | | Total Number of Individuals | Total Number of Years Assessed | Count of Individuals by the Number of Years Included in Longitudinal Assessment | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Shelter | | | Community | | | |
| | Range | Average | | | 1 | 2 | 3 | 1 | 2 | 3 | 4 |
| Female RC | 16-36 | 24.7 | 27 | 100 | | | | 0 | 0 | 8 | 19 |
| Female SP/RC | 13-21 | 16.9 | 33 | 50/75 | 18 | 13 | 2 | 4 | 16 | 13 | 0 |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community

ជាទូទៅទិន្នន័យរយៈពេលវែង បានចំណាយពេលប្រមូលទិន្នន័យក្នុងរយៈពេលបីទៅបួនឆ្នាំជាប់ៗគ្នាសម្រាប់ក្រុមអតិថិជននីមួយៗ។ ការប៉ាន់ប្រមាណក្នុងឆ្នាំនីមួយរបស់ក្រុមស្ត្រី/ក្មេងស្រី RC គឺជាក្រុមអតិថិជននៅក្នុងសហគមន៍ទាំងស្រុង ឯទិន្នន័យរបស់ក្រុមស្ត្រី/ក្មេងស្រី SP/RC ត្រូវបានបែងចែកជាពីរផ្នែកធំៗ ដែលអតិថិជនភាគច្រើនបានចំណាយពេល១ឆ្នាំទៅ២ឆ្នាំស្នាក់នៅក្នុងកម្មវិធីមណ្ឌល និងបានធ្វើសមាហរណកម្មទៅរស់នៅក្នុងសហគមន៍ពី២ឆ្នាំទៅ៣ឆ្នាំ (មើលនៅក្នុងតារាងទី១)។ ចំនួននៃការប៉ាន់ប្រមាណសរុបមានចំនួន១០០ដង សម្រាប់ក្រុមស្ត្រី/ក្មេងស្រី RC និងមាន៧៥ដង សម្រាប់ក្រុមស្ត្រី/ក្មេងស្រី SP/RC ដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ។

ក្រុមអ្នកស្រាវជ្រាវបានធ្វើការវិភាគលើប្រធានបទរួម។ ទិន្នន័យបែបគុណវិស័យត្រូវបានចងកូដដោយប្រើប្រាស់វិធីសាស្ត្រដំបូង (inductive methods) ដោយរួមបញ្ចូលជាមួយនឹងទ្រឹស្តី និងការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធនឹងការមាក់ងាយ ព្រមជាមួយនឹងការយល់ឃើញពីវប្បធម៌ស្តីពីសមាសភាពនៃការមាក់ងាយនៅក្នុងសង្គមកម្ពុជា។ សមាជិកក្រុមអ្នកស្រាវជ្រាវមានទាំងបុគ្គលិកជំនាញបច្ចេកទេសបុគ្គលិកជនជាតិខ្មែរ និងអ្នកផ្តល់ប្រឹក្សា ដោយមានទាំងបុគ្គលិកស្រី និងបុគ្គលិកប្រុស។ ក្រុមនេះបានសហការគ្នាធ្វើការសិក្សាវិភាគទៅលើទិន្នន័យដើម្បីកំណត់ និងបរិយាយពីការមាក់ងាយនៅក្នុងបរិបទសង្គមកម្ពុជា។ ទិន្នន័យសង្ខេបតាមឆ្នាំនីមួយៗត្រូវបានយកមកវិភាគមើលព្រមជាមួយគ្នានឹងទិន្នន័យសិក្សាបែបគុណវិស័យ ដែលបានប្រមូលក្នុងឆ្នាំ២០១៤ថ្មីៗនេះដែរ។ សមាជិកក្រុមម្នាក់ៗបានត្រួតពិនិត្យ វិភាគនិន្នន័យដាច់ដោយឡែករៀងៗខ្លួន បន្ទាប់មកពួកគេបានជួបជុំគ្នាធ្វើការវិភាគជាក្រុមដើម្បីកំណត់នូវចំនុចមួយចំនួនដូចជា ស្ថានភាពជាក់ស្តែងណាមួយ ពាក្យគន្លឹះសំខាន់ៗ ឃ្លាប្រយោគមួយចំនួន ដែលទាក់ទងនឹងការមាក់ងាយ និងសមាសភាពនៃការមាក់ងាយ។ តាមរបៀបបែបនេះ ក្រុមអ្នកស្រាវជ្រាវបានធ្វើការ ដោយប្រមូលមតិសម្រាប់ធ្វើការចងក្រងជាឯកសារ និងពិព័ណ៌នាពីទិដ្ឋភាពវប្បធម៌សំខាន់ៗស្តីពីការមាក់ងាយ និងការទំនាក់ទំនងនៃការមាក់ងាយរវាងជនរួចពីរងគ្រោះនឹងសហគមន៍របស់ពួកគេ។

## 4.0 លទ្ធផលនៃការសិក្សា និងការពិភាក្សា

ការសិក្សាប៉ាន់ប្រមាណនេះបានចងក្រងនូវទម្រង់នៃការមាក់ងាយផ្សេងៗគ្នា ដែលជនរួចពីរងគ្រោះដោយការជួញដូរផ្លូវភេទប្រឈមក្នុងជីវិតរស់នៅរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ មានការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញពីការរើសអើង និងកម្រិតមួយចំនួនឆ្លើយតបនឹងការមាក់ងាយដោយសារវាជាបញ្ហាមួយសំខាន់ដែលជនរួចពីរងគ្រោះជួបប្រទះក្នុងអំឡុងពេលធ្វើសមាហរណកម្ម ប៉ុន្តែយើងពុំឃើញមានការសិក្សាណាមួយមានបំណងវិភាគពីវិចទ័រ (កត្តាចម្បងៗ) និងទំហំនៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ ដែលបានធ្វើសមាហរណកម្មហើយក្នុងរយៈពេលវែងនោះទេ។

## 4.1 និយមន័យនៃការមាក់ងាយ

បញ្ញត្តិនៅក្នុងឯកសារយោងថ្មីៗនេះ បានផ្តោតលើការមាក់ងាយ ថាជាផលបូក នៃសមាសភាពនៃការមាក់ងាយ។ Link and Phelan (2001) លើកឡើងថាការមាក់ងាយបានរួមបញ្ចូលនូវការកើតឡើងនៃការដាក់ងារអវិជ្ជមាន និងផ្នត់គំនិតអវិជ្ជមាន ការបែងចែករវាង "ពួកយើង និងពួកគេ" ការបាត់បង់ឋានៈ និងការរើសអើង។ ការមាក់ងាយកើតមានឡើង ប្រសិនបើ សមាសភាពទាំងបួន មានវត្តមាន និងមូលដ្ឋាននៅក្នុងស្ថានភាពនៃវិសមភាពអំណាចណាមួយ។ វិសមភាពអំណាចកើតមាននៅពេលដែល

ក្រុមមួយមិនសូវបានទទួលនូវធនធាន និងមានឥទ្ធិពលតិចជាងក្រុមមួយផ្សេងទៀត ហើយការចាត់ចែងជោគវាសនាផ្ទាល់ខ្លួនរបស់ពួកគេក៏បានតិចតួចដែរ។

ការស្រាវជ្រាវអំពីការមាក់ងាយភាគច្រើនផ្តោតទៅលើពីរចំនុចសំខាន់ៗ ១) ការមាក់ងាយពីសង្គម ឬការមាក់ងាយពីសាធារណជន ត្រូវបានគេកំណត់ថាជាការមាក់ងាយកើតមាននៅក្នុងសហគមន៍ ឬនៅក្នុងសង្គម ដែលគំនិតជាទូទៅយល់ថាជាផ្នត់គំនិតអវិជ្ជមាន ការបែងចែក និងការរើសអើង និង២) ការមាក់ងាយខ្លួនឯង ត្រូវបានគេកំណត់ថាជាការយល់ឃើញ និងការគិតដោយខ្លួនឯងអំពីការមាក់ងាយ (Corrigan et al. 2009)។

## 4.2 ឫសគល់នៃការមាក់ងាយសង្គមនៅក្នុងប្រទេសកម្ពុជា

ការទំនាក់ទំនងនៅក្នុងសង្គមកម្ពុជា ត្រូវបានរៀបចំទៅតាមការកំណត់រចនាសម្ព័ន្ធឋានានុក្រម (Gorman and Kheng 1999; UNIFEM 2004; ក្រសួងកិច្ចការនារីឆ្នាំ២០០៨) ។ គំនិតនៃការបែងចែកឋានៈ និងកិត្តិយសនេះគឺជាចំនុចកណ្តាលនៃឋានានុក្រម និងត្រូវបានប្រើប្រាស់ក្នុងការទំនាក់-ទំនង។ វាត្រូវបានប្រើប្រាស់នៅក្នុងការកំណត់ពីមុខតំណែងនៅក្នុងក្រុមគ្រួសារ និងមុខដំណែងរបស់គ្រួសារនៅក្នុងសហគមន៍។ មានសមាសភាពសង្គមជាច្រើន ដែលបានកំណត់ឋានានុក្រមនេះ។ សមាសភាពដែលសំខាន់ជាងគេបំផុតនោះគឺកត្តាយេនឌ័រ។ បន្ទាប់មកទៀត មានចំនុចផ្សេងទៀតដូចជាអាយុ ធនធានហិរញ្ញវត្ថុ ស្ថានភាពគ្រួសារ គ្រួសារនោះមានកូន ឬអត់ កេរ្តិ៍ឈ្មោះគ្រួសារ ចរិកលក្ខណៈបុគ្គល តួនាទីក្នុងផ្នែកនយោបាយ កម្រិតការសិក្សាអប់រំ មុខរបរ និងសាសនាជាដើម (Gorman and Kheng 1999; UNIFEM 2004)។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ក្រុម ឬសហគមន៍ជាអ្នកកំណត់ពីឋានៈសង្គម ឬតួនាទីរបស់បុគ្គលម្នាក់ ឬក្រុមគ្រួសារមួយ។ ឋានៈសង្គមដែលគេផ្តល់ឲ្យនេះ គឺវាមិននៅស្ថិតស្ថេររហូតនោះទេ។ ដូច្នេះបញ្ញត្តិមួយចំនួនដូចជា ក្រមសីលធម៌ និង"ការយល់មុខ" គឺត្រូវការជាចាំបាច់ដើម្បីទទួលបាននូវកិត្តិយស ឬរក្សាកិត្តិយស និងឋានៈរបស់បុគ្គលម្នាក់ និងក្រុមគ្រួសារមួយនៅក្នុងសហគមន៍។ ក្រុមអ្នកស្រាវជ្រាវបានចង្អុលបង្ហាញផងដែរថា សូម្បីតែកុមារក៏មានការយល់ដឹងពីសារៈសំខាន់នៃកិត្តិយស ហើយបានពិចារណាយ៉ាងច្បាស់ថា វាជាកត្តាបើក ឬបិទសម្រាប់ជីវិតនាពេលអនាគត (Reimer et al. 2007)។

### ក្រមសីលធម៌ស្តីអំពីយេនឌ័រ

ច្បាប់ស្រី ឬ"ក្បួនច្បាប់ស្រី" គឺត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ និងជាក្រមសីលធម៌បែបប្រពៃណីដែលស្ត្រីកម្ពុជាអនុវត្តតាម។ វាបានជះឥទ្ធិពលទៅលើចំណុចជាច្រើនដែល "ស្ត្រីម្នាក់ដែលគួរឲ្យគេគោរព" ត្រូវមានបុគ្គលិកលក្ខណៈ និងការប្រព្រឹត្តិនៅក្នុងសង្គម ដោយរួមទាំង របៀបនៃស្លៀកពាក់ របៀបប្រព្រឹត្ត របៀបក្នុងការនិយាយស្តី ការងារអ្វីដែលស្ត្រីគួរ ឬមិនគួរធ្វើ និងរបៀបដែលនាងគួរតែដោះ

ស្រាយ និងឆ្លើយតបទៅនឹងអ្នកដទៃទៀត។ ទោះបីជាទម្រង់នៃបញ្ហាលំអៀងយេនឌ័រជាច្រើន ត្រូវបាន គេយល់ថា ជាបញ្ហាប្រឈមនៅប្រទេសកម្ពុជាក៏ដោយ ក៏ទិដ្ឋភាពផ្សេងៗនៃក្រមសីលធម៌នេះ នៅតែ មានជាប់ពាក់ព័ន្ធនៅក្នុងសង្គមដដែល (ក្រសួងកិច្ចការនារីឆ្នាំ២០០៨)។ ជាការពិតណាស់ ច្បាប់ស្រីត្រូវ បានបង្រៀននៅក្នុងសាលារដ្ឋតាំងពីថ្នាក់បឋម រហូតដល់ឆ្នាំ២០០៧។ ចំនុចនេះបញ្ជាក់ឲ្យឃើញថា ប្រជាជនគ្រប់សណ្ឋានអាយុនៅក្នុងប្រទេសកម្ពុជា អាចយល់ដឹងអំពីក្រមសីលធម៌នេះ គ្រាន់តែថាអាច ដឹងតិច ឬក៏ច្រើនប៉ុណ្ណោះ (ក្រសួងកិច្ចការនារីឆ្នាំ២០០៨)។

ដើម្បីស្វែងយល់បន្ថែមទៀតទៅលើបញ្ហានានា ដែលពាក់ព័ន្ធក្នុងចំណោមជនរួចពីរងគ្រោះ នៅក្នុងឆ្នាំ ២០១២ គម្រោងស្រាវជ្រាវមេអំបៅ បានធ្វើការពិភាក្សាក្រុមតូច (FGD) ជាមួយជនរួចពីរងគ្រោះ។ នៅ ក្នុងការពិភាក្សានេះ ជនរួចពីរងគ្រោះបានរៀបរាប់អំពីការយល់ដឹងរបស់ពួកគេផ្ទាល់ ចំពោះច្បាប់ស្រី និង ទិដ្ឋភាព ដែលពួកគេបានគិតថា មានសារៈសំខាន់បំផុតដល់ជីវិតរបស់ពួកគេ។ ការបង្ហាញក្នុងប្រអប់ ខាងក្រោមនេះ បានយកពីរបាយការណ៍ស្រាវជ្រាវរបស់គម្រោងស្រាវជ្រាវមេអំបៅ ដើម្បីបង្ហាញពីការ យល់ឃើញរបស់ពួកគេផ្ទាល់ទៅលើតួនាទីយេនឌ័រ ការដាក់ងារអវិជ្ជមាន ផ្នត់គំនិតអវិជ្ជមាន និងប្រភព នៃការមាក់ងាយនៅក្នុងប្រទេសកម្ពុជា (Miles et al.2012)។

### ការបង្ហាញទី1៖ការពិភាក្សក្រុមតូចជាមួយជនរួចពីរងគ្រោះស្តីពីច្បាប់ស្រី

អ្នកចូលរួមសិក្សាស្រាវជ្រាវត្រូវបានគេសាកសួរនៅក្នុងការពិភាក្សាជាក្រុមអំពីការយល់ដឹងរបស់ពួកគេពីច្បាប់ស្រី និងថាតើវាទាក់ទងនឹងពួកគេនៅក្នុងប្រទេសកម្ពុជានៅថ្ងៃនេះ។ ក្រុមនេះជាទូទៅបានរៀបរាប់ច្បាប់ស្រីជាក្រមនៃការប្រព្រឹត្តដ៏ត្រឹមត្រូវសម្រាប់ស្ត្រី និងក្មេងស្រី។ ពួកគេបាននិយាយថា ជាទូទៅវាជារឿងសំខាន់ព្រោះវាបាននាំកិត្តិយសដល់ស្វាមី, ក្រុមគ្រួសារ និងសង្គម។ ពួកគេបានរៀបរាប់ពីប្រភេទជាច្រើននៃឥរិយាបថ ដូចជាសារៈសំខាន់នៃការគោរព និងការធ្វើតាមប្តី របស់គេនៅគ្រប់កាលៈទេសៈទាំងអស់, បើទោះបីជាគាត់ជាអ្នកខុស។ ពួកគេបាននិយាយអំពីសារៈសំខាន់សម្រាប់ក្មេងស្រី និងស្ត្រីដើម្បីរក្សាបាននូវព្រហ្មចារីរបស់ខ្លួនរហូតដល់បានអាពាហ៍ពិពាហ៍ ហើយការរក្សានូវសម្ព័ន្ធភាពឯកព័ន្ធភាព ដោយមិនគិតពីការប្រព្រឹត្តផ្លូវភេទដែលប្តីរបស់ពួកគេប្រព្រឹត្តឡើយ។ ពួកគេបាននិយាយអំពីការទទួលខុសត្រូវរបស់ស្ត្រីក្នុងការគ្រប់គ្រងគ្រួសារ និងធានាថាគ្រួសារមានដំណើរការយ៉ាងរលូន, ដើម្បីបញ្ឈប់ការប្រព្រឹត្តមកលើពួកគេដោយប្រើឥរិយាបថខ្លាំងៗ ឬដោយការសម្តែងនូវគំនិតខ្លាំងៗ, ដើម្បីកម្រិតការដើរហើររបស់ពួកគេដោយអោយតែនៅក្នុងផ្ទះ ហើយមិនអោយចំណាយពេលមិនចាំបាច់ទៅឆ្ងាយពីក្រុមគ្រួសារ និងដោយមិនចេញទៅក្រៅនៅពេលយប់, មិនអោយដេកលក់ជ្រុលម៉ោងដោយមានបំណងអោយពួកគេត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីបម្រើប្តី និងគ្រួសារ, និងដើម្បីជៀសវាងការនិយាយបង្កាច់បង្ខូច និងការនិយាយដើមគេ

ក្រុមពិភាក្សាបានចាត់ថ្នាក់ចំពោះការប្រព្រឹត្តអ្វីខ្លះដែលពួកគេគិតថាជាចំនុចសំខាន់នៅក្នុងច្បាប់ស្រី។

1. កុំដើរលេងពេលយប់
2. កុំដើរលឺសូរសំលេងខ្លាំង
3. កុំនិយាយដើមគេ
4. កុំនិយាយ ឬសើចខ្លាំងៗ
5. កុំដេរបណ្តាសាគេ
6. កុំដេកទ្រមក់
7. កុំទៅលេងផ្ទះអ្នកដទៃយូរពេក
8. ជួយគេធ្វើកិច្ចការងារផ្ទះ
9. គោរពចាស់ទុំ
10. កុំជេរប្តី
11. ស្លៀកពាក់សមរម្យ
12. កុំចចេសរឹងរូស
13. រក្សាព្រហ្មចារី

អ្នកចូលរួម ត្រូវបានសុំអោយធ្វើការពិភាក្សាអំពី ការយល់ដឹងរបស់ពួកគេ ពីអ្វីដែលពួកគេបានគិតថា សង្គមខ្មែរអោយតម្លៃចំពោះរបៀប ដែលប្រជាជនកម្ពុជា គួរមានឥរិយាបថ និងប្រព្រឹត្តខ្លួនឯងយ៉ាងដូចម្តេច។ ការឆ្លើយតបរបស់ពួកគេ បានផ្តោតសំខាន់លើសារៈសំខាន់នៃការបង្ហាញការគោរពចំពោះពួកអ្នកចាស់ទុំក្នុងសង្គម និងទៅឪពុកម្តាយរបស់គេម្នាក់ៗ, និងពីសារៈសំខាន់នៃការគោរពប្រតិបត្តិ និងធ្វើតាមយោបល់របស់ពួកគេ។ ពួកគេ បាននិយាយអំពីរបៀបដែលសង្គមឱ្យតម្លៃចំពោះមនុស្ស ដែលអាចគ្រប់គ្រងអារម្មណ៍របស់ពួកគេ ហើយជាពិសេសមិនត្រូវបង្ហាញកំហឹង ឬការគុំគួន។ ពួកគេបាននិយាយអំពីសារៈសំខាន់នៃការក្លាយជាអ្នក ដែលអាចជឿទុកចិត្តបាន, ភាពស្មោះត្រង់ និងទទួលស្គាល់កំហុសខ្លួនឯង។ ពួកគេបាននិយាយអំពីរបៀប ដែលសង្គមឱ្យតម្លៃស្ត្រី ដែលស្អាតតែរាងកាយ ប៉ុន្តែមិនឱ្យតម្លៃស្ត្រី ដែលមានបំរើសេវាផ្លូវភេទ។

មានឧទាហរណ៍ជាក់ស្តែងមួយចំនួនស្តីពីការខាតបង់កិត្តិយស និងឋានៈក្នុងសង្គមរបស់នារី ដែលជាលទ្ធផលនៃអាកប្បកិរិយា ឬស្ថានភាពជីវិតដែលប្រាស់ចាកពីបទដ្ឋានសង្គម វប្បធម៌ និងក្រមសីសធម៌នៅក្នុងប្រទេសកម្ពុជា។ ចំពោះស្ត្រីដែលប្រកបរបររកស៊ីផ្លូវភេទ(បូករួមទាំងជនរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ) ស្ត្រីដែលបានលែងលះប្តី ឬមកពីក្រុមគ្រួសារបានលែងលះគ្នា និងនៅក្នុងករណីខ្លះទៀត តាមបែបវប្បធម៌ប្រពៃណីត្រូវបានគេយល់ថានាង និងកូនៗរបស់នាង មិនត្រូវបានគេអញ្ជើញឱ្យចូលរួមក្នុងពិធីជូនពរជ័យដល់គូស្វាមីភរិយាថ្មោងថ្មី នៅក្នុងពិធីជាក់លាក់មួយចំនួនដូចជា៖

1. **ពិធីហែរជំនូន** "*Pi Ti Hae Chum noun*" - Fruits ceremony in the front of the line
2. **ពិធីកាត់សក់** "*Pi Ti kat sok*" - Blessing by cutting hair for groom and bride
3. **ពិធីបង្វិលពពិល** "*Pi Ti bang vil po pil*" - Candle blessing
4. **ធ្វើជាអ្នកកំដរកូនកម្លោះកូនក្រមុំ** "*Nak Kam dor Koun Kam laos neung Koun Kra mum*" - To be the groom or bride's mate of honor

## ការមាក់ងាយ និងការរើសអើងទាក់ទងនឹងបញ្ហាយេនឌ័រ

វិសមភាពយេនឌ័រ គឺជាប្រភពចម្បងនៃការមាក់ងាយ និងការរើសអើង ក្នុងចំណោមស្ត្រីនៅក្នុងប្រទេសកម្ពុជា។ ជាប្រពៃណី ស្ត្រីត្រូវបានគេផ្តល់ឋានៈទាបជាងបុរសនៅក្នុងសង្គមកម្ពុជា។ ការបែងចែកឋានៈ និងភាពខុសគ្នានៃអំណាចតាមប្រពៃណីរវាងបុរស និងស្ត្រី បានបណ្តាលអោយមានការចាក់ឫសយ៉ាងជ្រៅ និងមានភាពចម្រូងចម្រាសចំពោះបញ្ហាការមាក់ងាយ និងការរើសអើងក្នុងចំណោមស្ត្រី (Gorman and Kheng 1999; USAID 2010)។ មានរបាយការណ៍ជាច្រើនបានកត់ត្រា និងរៀបរាប់អំពីទិដ្ឋភាពនៃការមាក់ងាយទាក់ទងនឹងយេនឌ័រ (ឧទាហរណ៍៖ ការលំអៀងយេនឌ័រ និងវិសមភាព) និងការរើសអើង (Amnesty International 2010; USAID 2010; ADHOC 2011)។ ចំណុចខាងក្រោមនេះបញ្ជាក់ពីបញ្ហាចម្បងជុំវិញការមាក់ងាយទាក់ទងនឹងបញ្ហាយេនឌ័រក្នុងប្រទេសកម្ពុជា។

- មានការពិព័ណ៌នាជាច្រើនទាក់ទងនឹងកត្តា និងអាកប្បកិរិយា ដែលរួមចំណែកដល់អំពើហិង្សាក្នុងគ្រួសារក្នុងចំណោមស្ត្រី (Yount and Carrera 2006; Eng et al, 2010, Amnesty International 2010 ; ADHOC 2011)
- មានទម្រង់នៃការរើសអើងពីក្រុមគ្រួសារចំពោះកូនស្រី ហើយគំលាតលំអៀងខ្លាំងរវាងការទទួលបានការអប់រំរបស់កូនស្រីធៀបទៅនឹងកូនប្រុស (Khun 2008, USAID 2010)
- មានទម្រង់ជាច្រើននៃការមាក់ងាយ និងការរើសអើងជាប្រព័ន្ធនៅក្នុងប្រព័ន្ធផ្លូវច្បាប់ទាក់ទងនឹងអាពាហ៍ពិពាហ៍ និងការលែងលះក្នុងចំណោមស្ត្រី (Van Der Keur 2014)
- សន្ទស្សន៍នៃភាពក្រីក្រខ្ពស់ក្នុងចំណោមស្ត្រី និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ជាគ្រួសារក្រីក្របំផុតក្នុងចំណោមគ្រួសារអ្នកក្រីក្រ (UNIFEM 2004)
- មានចន្លោះគំលាតធំរវាងបុរស និងស្ត្រី នៅក្នុងប្រព័ន្ធច្បាប់ និងរដ្ឋាភិបាល (USAID 2010)
- មានបញ្ហាប្រឈមជាច្រើនសម្រាប់ស្ត្រីក្នុងការទទួលបាននូវការថែទាំសុខភាព (USAID 2010)
- មានឧបសគ្គផ្នែកសេដ្ឋកិច្ច និងការរើសអើងប្រាក់ឈ្នួល ក្នុងចំណោមស្ត្រី ដែលធ្វើការដោយប្រើកំលាំង (USAID 2010)

- មានកម្រិតមិនស្មើគ្នានៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនឹងស្ត្រី (អំពើហិង្សាក្នុងគ្រួសារ ការរំលោភយកដីធ្លី ការជួញដូរ) និងកម្រិតខ្ពស់នៃនិទណ្ឌភាព សម្រាប់ឧក្រិដ្ឋកម្មទាំងនេះ (ADHOC 2011)

## ការមាក់ងាយពូជសាសន៍

បុរេនិច្ឆ័យពូជសាសន៍ ការរើសអើង និងការមាក់ងាយ គឺជាបញ្ហាដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសាកលលោក ដែលកើតមានឡើងនៅក្នុងបណ្តាប្រទេស ក្រុមមនុស្ស និងទ្វីបមួយចំនួន។ ហើយប្រទេសកម្ពុជាក៏មិនខុសអីនឹងប្រទេសទាំងនោះដែរ ពាក់ព័ន្ធនឹងបញ្ហានេះ។ វាមានភាពតានតឹងផ្នែកជាតិសាសន៍កើតឡើងតាំងពីយូរមកហើយរវាងប្រទេសកម្ពុជានឹងប្រទេសជិតខាង។ ប្រជាជនខ្មែរ និងប្រជាជនវៀតណាមមានប្រវត្តិសាស្ត្រយូរអង្វែងជាមួយគ្នាទាក់ទងនឹងអំពើហិង្សា ការរើសអើង និងបុរេនិច្ឆ័យ (Berman 1996)។ ប្រជាជនវៀតណាមគឺជាក្រុមជនជាតិភាគតិចដែលរស់នៅក្នុងប្រទេសកម្ពុជាច្រើនជាងគេបំផុត។ ជាក់ស្តែង ការមាក់ងាយ និងការរើសអើងពូជសាសន៍កើតឡើងយ៉ាងខ្លាំងប្រឆាំងនឹងសហគមន៍វៀតណាម ហើយមានប្រជាជនវៀតណាមជាច្រើននាក់ បានសម្រេចចិត្តប្រមូលផ្តុំទៅរស់នៅដាច់តែឯងពីសង្គមប្រជាជនខ្មែរ។ របាយការណ៍សិក្សាបានបង្ហាញថា ជនជាតិវៀតណាម និងកូនចៅជាប់សាច់ឈាមជនជាតិវៀតណាមបានប្រឈមនឹងការរើសអើងជាលក្ខណៈបុគ្គល និងជាប្រព័ន្ធដែលមានជាច្រើនទម្រង់ផ្សេងៗគ្នា(Berman 1996)។

## 4.3 បទពិសោធន៍នៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ

ជនរួចពីរងគ្រោះមួយចំនួនបានរៀបរាប់ពីការប្រឈមជាមួយនឹងការមាក់ងាយច្រើនទម្រង់ នៅក្នុងការប៉ាន់ប្រមាណរយៈពេលវែងនេះ។ ស្ថានភាពនៃការមាក់ងាយនេះត្រូវក្រុមអ្នកស្រាវជ្រាវយកមកវិភាគ និងចងក្រងបែងចែកទៅតាមផ្នែកនីមួយៗ ដែលវាបានពិព័ណ៌នាយ៉ាងត្រឹមត្រូវបំផុតស្របតាមស្ថានភាពដែលពួកគេបានរៀបរាប់ប្រាប់នៅក្នុងសហគមន៍ (មើលនៅក្នុងតារាងទី២)។ ឧទាហរណ៍មួយចំនួនស្តីពី "ការដាក់ងារអវិជ្ជមាន" ត្រូវបានបង្កើតឡើងដោយផ្អែកទៅតាមការពិភាក្សាជាមួយជនរួចពីរងគ្រោះ និងចំណេះដឹង និងការយល់ដឹងពីវប្បធម៌របស់ក្រុមអ្នកស្រាវជ្រាវទាក់ទងនឹងពាក្យគ្រោមភាសា ការជេរប្រមាថ ការស្តីបន្ទោស និង ការដាក់ងារអវិជ្ជមានជាដើម។ ជាញឹកញាប់ ជនរួចពីរងគ្រោះបាននិយាយរៀបរាប់ពីស្ថានភាព ឬបទពិសោធន៍នៃការមាក់ងាយដែលកើតឡើងក្នុងផ្ទះ និងសហគមន៍របស់ពួកគេព្រមជាមួយគ្នានឹង ការដាក់ងារអវិជ្ជមានដល់ពួកគេ ដែលវាពាក់ព័ន្ធនឹងប្រភេទនៃការមាក់ងាយផ្សេងៗគ្នា។

⇨ *មិត្តភក្តិនៅសាលាធ្វើឲ្យខ្ញុំមានអារម្មណ៍មិនសូវសប្បាយចិត្តទេ ព្រោះពួកគេចំអកមើលងាយដាក់ខ្ញុំ ហើយនិយាយមិនល្អពីខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាពួកគេមើលងាយខ្ញុំ ព្រោះពួកគេដឹងថាខ្ញុំធ្លាប់*

*រស់នៅក្នុងមណ្ឌល។ ពួកគេនិយាយថាក្មេងមណ្ឌល គឺសុទ្ធតែជាក្មេងដែលបានត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ និងចាប់រំលោភរហូតមានផ្ទៃពោះដោយអត់មានប្តី។*

- ⇨ *ក្មេងអ្នកមានខ្លះនៅសាលារៀនធ្វើអត់ល្អដាក់ខ្ញុំ ព្រោះខ្ញុំជាអ្នកក្រ។ ពួកគេគិតថាពួកគេល្អជាក្មេងអ្នកក្រ។ ខ្ញុំបានប្រាប់លោកគ្រូ ប៉ុន្តែគាត់មិនអាចធ្វើអីបានចំពោះក្មេងអ្នកមានអស់នោះទេ។ ពួកគេមានឪពុកម្តាយជាអ្នកមាន ហើយពួកគេមិនចាំបាច់ធ្វើតាមច្បាប់ទេ។*
- ⇨ *ខ្ញុំអត់ចេះអក្សរទេ។ បងប្រុសខ្ញុំប្រាប់ខ្ញុំឲ្យខំរៀន ប៉ុន្តែតើឲ្យខ្ញុំរៀនម្តេចទៅ? គាត់សើចឲ្យខ្ញុំ។ គ្រប់គ្នានឹងជេរស្តីបន្ទោសឲ្យខ្ញុំព្រោះខ្ញុំធំហើយ តែមិនចេះអាន មិនចេះសរសេរទៀត។ ឥលូវខ្ញុំបោះបង់ការរៀនសរសេរ និងអានអក្សរហើយ។*
- ⇨ *ខ្ញុំជាក្មេងធ្វើការពេលយប់ ប៉ុន្តែអ្នកជិតខាង និងអ្នកនៅក្នុងភូមិនិយាយថាការងារខ្ញុំជាការងារមិនល្អ។ ពួកគេនិយាយថា "ក្មេងធ្វើការនៅពេលយប់ គឺជាក្មេងមិនល្អ"។ មុនពេលខ្ញុំទៅធ្វើការនៅហាងខារ៉ាអូខេ ខ្ញុំមានទំនាក់ទំនងល្អជាមួយអ្នកជិតខាង ប៉ុន្តែបន្ទាប់ពីពួកគេដឹងថាខ្ញុំធ្វើការនៅក្នុងហាងខារ៉ាអូខេ ពួកគេឈប់រាប់អានខ្ញុំ និងគោរពខ្ញុំទៀតហើយ។*

**តារាងទី2៖ ប្រភេទនៃការមាក់ងាយ និងការដាក់ងាររអវិជ្ជមាន**

| Stigma | Examples of Commonly Used Negative Labels |
|---|---|
| **Current or Past Work in the Sex Industry** | - ស្រីខារ៉ាអូខេ "Srey Karaoke" - **Karaoke girl/KTV girl**<br>- ស្រីខូច "SreyKouch"/ស្រីរកស៊ី "srey roksi"/ស្រីសំផឹង "sreysampeung"(strong insult) - **Broken girl**<br>- ដើរលេងផ្តេសផ្តាស "Deur leng yub pdes pdas"/ដើរហាច់ "Deur Hach" (insult)- **You go out and walk at night**<br>- ធ្វើការងារអាក្រក់ "Tver ka ngear a krok" - **You do the bad work** |
| **Associated with Shelter (Aftercare) Programs** | - ក្មេងអង្គការ "Kmeng Angka"-**NGO girl**<br>- ស្រីខូច "SreyKouch"/ស្រីរកស៊ី "srey roksi"-**Broken girl**<br>- អ្នកក្រ "Nak Kro"-**Poor person** |
| **Pregnant Without a Husband<br>Child Without a Husband** | - ដើរលេងយប់ផ្តេសផ្តាស "Deur leng yub pdes pdas" -**You go out and walk at night**<br>- កូនអត់ខាន់ស្លា "Kon ort Khan sla"/កូនអត់ឪ "kon ort ov" -**Illegitimate child**<br>- ផើមព្រៃ "Pheum Prey"/ផើមអត់ប្តី "Pheum ort bdey"/ពោះធំអត់ប្តី " Pos thom ort bdey" -**Pregnant without husband/ don't who child's father is** |

| | |
|---|---|
| **Partnership and Second Wife** | - ប្រពន្ធអត់ខាន់ស្លា "Propun ort khansla"/ប្រពន្ធអត់ស្របច្បាប់ " Propun ort srob Chbab" -**Illegal wife**<br>- ប្រពន្ធចុង "Propun Jong" -**Second wife**<br>- ស្រីកំណាន់ "Srey Kamnan"/ស្រីលួចលាក់ "Srey louch lak" -**Mistress**<br>- សង្សារ " Sangsa"/ស្រីរបស់គេ "Srey bos ke" - **Girlfriend**<br>- ប្តីច្រើន "bdey chreun"/ប្រុសច្រើន "bros chreun" - **Multi partners** |
| **Divorce** | - បាក់មែកបាក់ធាង "Bak mek bak theang"/បែកបាក់ "bek bak" - **Breaks relationship**<br>- ស្រីមេម៉ាយ "Srey mae may"/ស្រីលែងប្តី"srey leng bdey" - **Divorced woman** |
| **Marriageability** | - ស្រីអត់គ្រប់ល័ក្ខ"Srey ort krub leak"/ស្រីអភ័ព្វ"srey ak phoub" /បាក់មែកបាក់ធាង "Bak meik bak theang"- **Unfit woman**<br>- ស្រីអាក្រក់ "Srey a krok" /ស្រីអត់ល្អ "srey ort la or"/ស្រីថោក "Srey thouk" (strong insult) - **Messy woman**<br>- ស្រីក្រីក្រ "Srey krey kro" / ស្រីរហេមរហាម "srey ro hem ro harm" /ស្រីថោកទាប "Srey thouk teap" (putting them into a very low status ) - **Poor girl** |
| **Gender Inequality in Marriage** | - គ្រាន់តែជាប្រពន្ធទេ "Kran te jea propun te" - **You are just a wife**<br>- ប្រពន្ធប្តីវាយ "Propun bdey vai"/សាច់កម្ម "sach kam" - **The wife who is** |
| **Socioeconomic status** | - ចាស់ហើយ "Jas heuy"/អាយុច្រើន "Ayu chreun" -**Too old for school**<br>- ពួកអ្នកក្រ "Pouk nak kro"/ពួករហេមរហាម "pouk ro hem ro harm" -**Poor person**<br>- រហេមរហាម "ro hem ro harm" /តោកយ៉ាក "Touk yak" -**The have-nots** |
| **Ethnicity** | - ស្រីយួន "Srey Youn"/ស្រីខូច "srey Koch" - **Vietnam girl** |
| **Mental Health** | - មនុស្សល្ងង់ "Monus la ngung"/ភ្លីភ្លើ "Pli Pleu"/ស្ទួក "Stuk" – **Stupid person**<br>- មនុស្សឆ្កួត "Monus chhkout" -**Crazy person** |
| **Physical Health e.g. HIV** | - ស្រីខូច "Srey Koch"/ស្រីកើតអេដស៍ "Srey keut aid"/ស្រីរកស៊ី "Srey roksi" - **Broken woman** |

## ការមាក់ងាយនៅក្នុងចំណោមក្រុមអតិថិជន

ក្នុងចំណោមអ្នកតបសម្ភាសន៍ភាគច្រើន (ស្មើនឹង៦៥%)បានប្រឈមជាមួយនឹងបទពិសោធន៍មាក់ងាយយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលធ្វើប៉ាន់ប្រមាណ៤ឆ្នាំកន្លងមកនេះ (មើលតារាងទី៣)។ សរុបទាំងអស់ អ្នកចូលរួមការស្រាវជ្រាវភាគច្រើនបាននិយាយជាញឹកញាប់ពីការមាក់ងាយទាក់ទងនឹងវិសមភាពយេនឌ័រនៅក្នុងជីវិតអាពាហ៍ពិពាហ៍ (ស្មើនឹង២៥% នៃអ្នកតបសម្ភាសន៍ទាំងអស់) ការប្រកបរបររកស៊ីផ្លូវ

ភេទ មិនថាការងារបច្ចុប្បន្ន ឬអតីតកាល (ស្មើនឹង២៣.៣%នៃអ្នកតបសម្ភាសន៍ទាំងអស់) និងកម្រិតសេដ្ឋកិច្ចសង្គមទាប (ស្មើនឹង២៣.៣%នៃអ្នកតបសម្ភាសន៍ទាំងអស់)។ ប្រភេទនៃការមាក់ងាយទាំងនេះក៏បានបង្ហាញពីចំនួនអ្នកឆ្លើយតបខ្ពស់ជាងគេ ដែលបានជួបនូវបទពិសោធន៍មាក់ងាយក្នុងរយៈពេលជាច្រើនឆ្នាំដែរ។

អត្រាប្រេវ៉ាឡង់មានភាពខុសគ្នាយ៉ាងខ្លាំងរវាងក្រុមអតិថិជននៅក្នុងការប៉ាន់ប្រមាណនេះ។ ភាគរយនៃអតិថិជនដែលបានរៀបរាប់ពីការមាក់ងាយច្រើនគួរឲ្យកត់សម្គាល់គឺក្រុមស្ត្រី/ក្មេងស្រី RC ដែលស្មើនឹង ៨១.៥%បើប្រៀបធៀបនឹងក្រុមស្ត្រី/ក្មេងស្រី SP/RC មានតែ៥១.៥% (មើលតារាងទី៣)។លើសពីនោះទៀត បើយើងប្រៀបធៀបជាមួយនឹងក្រុមស្ត្រី/ក្មេងស្រី SP/RC យើងឃើញថាក្រុមស្ត្រី/ក្មេងស្រីRC មានច្រើនជាងពីរដង ដែលអ្នកតបសម្ភាសន៍ច្រើននាក់បានប្រាប់ ថាពួកគេជួបប្រទះនូវបទពិសោធន៍នៃការមាក់ងាយប្រភេទដូចៗគ្នាក្នុងរយៈពេលជាច្រើនឆ្នាំ។ បើប្រៀបធៀបចំនួនសរុបនៃបទពិសោធន៍ការមាក់ងាយក៏មានចំនួនខ្ពស់ដែរនៅក្នុងចំណោមស្ត្រី/ក្មេងស្រី RC គឺមាន៧៥ឧប្បត្តិហេតុនៃការមាក់ងាយនៅពេលដែលក្រុមស្ត្រី/ក្មេងស្ត្រី SP/RCមានតែ៤០ឧប្បត្តិហេតុនៃការមាក់ងាយប៉ុណ្ណោះ។ នៅក្នុងក្រុមស្ត្រី/ក្មេងស្រី SP/RC មានអ្នកតបសម្ភាសន៍៦នាក់ (ស្មើនឹង១៨.២%នៃចំនួនសមាជិកក្រុម) បានរៀបរាប់ថាពួកគេជួបប្រទះនឹងបញ្ហាការមាក់ងាយពាក់ព័ន្ធនឹងកម្មវិធីមណ្ឌល ខណៈពេលដែលមានតែម្នាក់ប៉ុណ្ណោះនៅក្នុងក្រុមស្ត្រី/ក្មេងស្រី RCដែលនិយាយពីការមាក់ងាយនេះ។

**តារាងទី3៖ ការបែងចែកអត្រាប្រេវ៉ាឡង់ ដែលរៀបរាប់ដោយជនរួចពីរងគ្រោះក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងក្រុមស្ត្រី/ក្មេងស្រី RC (n=27នាក់)**

| Survivors talk about stigma related to: | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | n* | % | Total Count | Individuals w/ Multiple Years | n* | % | Total Count | Individuals w/ Multiple Years |
| Gender inequality in marriage | 4 | *12.1* | 7 | 2 | 11 | *40.7* | 19 | 6 |
| Current or past work in the sex industry | 4 | *12.1* | 8 | 2 | 10 | *37.0* | 19 | 5 |
| Lower socioeconomic levels | 6 | *18.2* | 8 | 1 | 8 | *29.6* | 15 | 5 |
| Pregnant without a husband<br>Child without a husband | 3 | *9.1* | 4 | 1 | 6 | *22.2* | 7 | 1 |
| Marriage "Fitness" | 3 | *9.1* | 3 | | 3 | *11.1* | 3 | |
| Divorce | 0 | *0* | 0 | | 2 | *7.4* | 4 | 1 |
| Mental health | 1 | *3.0* | 2 | 1 | 1 | *3.7* | 2 | 1 |
| Physical health | 0 | *0* | 0 | | 1 | *3.7* | 1 | |
| Religious beliefs | 1 | *3.0* | 1 | | 1 | *3.7* | 3 | 1 |
| Associated with Shelter (Aftercare) Programs | 6 | *18.2* | 6 | | 1 | *3.7* | 1 | |
| Partnership and second wife | 1 | *3.0* | 1 | | 1 | *3.7* | 1 | |
| Total** | 17 | *51.5* | 40 | 5 | 22 | *81.5* | 75 | 11 |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
Blank - No Observations
* - Number of Individuals
** - Individuals talk about multiple stigma; therefore, counts are not additive.

## ក្រុមអ្នកមាក់ងាយ

អ្នកតបសម្ភាសន៍ស្ទើរតែទាំងអស់ ដែលបានរៀបរាប់ពីបទពិសោធន៍ទទួលការមាក់ងាយក៏បានបង្ហាញឲ្យស្គាល់ផងដែរ ថាតើមាននរណាខ្លះជាអ្នកមាក់ងាយដល់ពួកគេ គឺមាន៦១.៧%នៃអ្នកតបសម្ភាសន៍ទាំងអស់ បានបង្ហាញថាមានមនុស្សម្នាក់ ឬមនុស្សច្រើនក្រុមបានមាក់ងាយដល់ពួកគេក្នុងអំឡុងពេលសិក្សាប៉ាន់ប្រមាណរយៈពេល៤ឆ្នាំកន្លងមកនេះ (មើលតារាងទី៤)។ សរុបទាំងអស់មាន៖

- ៣៥%នៃជនរួចពីរងគ្រោះ បានប្រឈមនឹងការមាក់ងាយសង្គមពីអ្នកជិតខាងនៅក្នុងសង្គមរបស់ពួកគេ (ចំនួន៦០ដង)
- ៥១.៤%នៃជនរួចពីរងគ្រោះ ដែលបានរៀបការហើយ ឬមានដៃគូបានប្រឈមនឹងការមាក់ងាយសង្គមពីសំណាក់ប្តី ឬដៃគូ និង/ឬឪពុកម្តាយក្មេករបស់ពួកគេ (ចំនួន៣៥ដង)
- ២២%នៃជនរួចពីរងគ្រោះ ដែលបានចូលរៀននៅសាលាបាននិយាយរៀបរាប់ពីការប្រឈមនឹងការមាក់ងាយសង្គមពីសំណាក់មិត្តភក្តិរួមថ្នាក់របស់គេ (ចំនួន២៣ដង)។

តារាងទី4៖ អត្រាប្រេវ៉ាឡង់នៃអ្នកមាក់ងាយ ដែលស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់)បានប្រាប់ពីឆ្នាំ២០១១ដល់២០១៤

| Survivors talk about discrimination from: | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | n* | % | Total Count | Individuals w/ Multiple Years | n* | % | Total Count | Individuals w/ Multiple Years |
| Neighbors / Community | 8 | *24.2* | 10 | 1 | 13 | *48.1* | 20 | 5 |
| Partner/Husband | 3 | *9.1* | 5 | 2 | 11 | *40.7* | 20 | 7 |
| Partner/Spouse's Parents | 3 | *9.1* | 4 | 1 | 10 | *37.0* | 18 | 4 |
| Family | 2 | *6.1* | 6 | 1 | 5 | *18.5* | 9 | 2 |
| Co-workers and/or Clients | 1 | *3.0* | 1 | | 5 | *18.5* | 9 | 3 |
| Workplace Supervisor | 2 | *6.1* | 2 | | 2 | *7.4* | 2 | |
| Community Leader | 1 | *3.0* | 1 | | 1 | *3.7* | 1 | |
| Classmates | 5 | *15.2* | 5 | | 0 | *0* | 0 | |
| Total** | 16 | *48.5* | 34 | 4 | 21 | *77.8* | 79 | 12 |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
Blank - No Observations
* -Number of Individuals
** - Individuals talk about multiple stigmatizing groups; therefore, counts are not additive.

ស្រដៀងគ្នាទៅនឹងលទ្ធផលស្តីពីប្រភេទនៃការមាក់ងាយនៅក្នុងតារាងទី៣ដែរ យើងឃើញថាមានភាពខុសគ្នាយ៉ាងខ្លាំងដែរ ទាក់ទងនឹងអត្រាប្រេវ៉ាឡង់នៃក្រុមអ្នកមាក់ងាយរវាងក្រុមស្ត្រី/ក្មេងស្រី SP/RC និងក្រុមស្ត្រី/ក្មេងស្រី RC។ ចំនួនសរុប និងភាគរយនៃអតិថិជនម្នាក់ៗ ដែលបានរៀបរាប់ឲ្យស្គាល់ពីក្រុមអ្នកមាក់ងាយគឺក្រុមស្ត្រី/ក្មេងស្រី RC មានចំនួនខ្ពស់ជាងក្រុមស្ត្រី/ក្មេងស្រី SP/RC។ ភាគរយនៃ

អតិថិជន ដែលនិយាយពីក្រុមអ្នកមាក់ងាយ មាន៧៧%សម្រាប់ស្រ្តី/ក្មេងស្រីRC តែក្រុមស្រ្តី/ក្មេងស្រី SP/RCមានតែ៤៨.៥%ប៉ុណ្ណោះ (មើលតារាងទី៤)។

ដៃគូ ឬប្តី និងឪពុកម្តាយរបស់ពួកគេបានដើរតួយ៉ាងសំខាន់ចំពោះបទពិសោធន៍មាក់ងាយរយៈពេលយូរ ក្នុងចំណោមជនរួចពីរងគ្រោះ។ អតិថិជនដែលទទួលរងនូវការមាក់ងាយ និងការរើសអើងក្នុងរយៈពេលជាច្រើនឆ្នាំពីសំណាក់ដៃគូ/ប្តី និងឪពុកម្តាយរបស់ពួកគេ គឺមាន៣ក្នុងចំណោម៤នាក់សម្រាប់ក្រុមស្រ្តី/ក្មេងស្រី SP/RC និង១០ក្នុងចំណោម១២នាក់សម្រាប់ក្រុមស្រ្តី/ក្មេងស្រីRC (មើលតារាងទី៤)។

ជនរួចពីរងគ្រោះបានពិព៌ណ៌នាឲ្យស្គាល់ពីក្រុមអ្នកមាក់ងាយដូចបានរៀបរាប់ខាងក្រោម៖

- ⇨ *អ្នកខ្លះគិតថាខ្ញុំជាក្មេងស្រីអត់ល្អ។ អ្នកខ្លះមានអាកប្បកិរិយាមិនសមរម្យដាក់ខ្ញុំ...ខ្ញុំធ្លាប់លឺពួកគេនិយាយគ្នា(អ្នកជិតខាងជាប់ផ្ទះខ្ញុំ)ថា ក្មេងៗរស់នៅក្នុងមណ្ឌលទាំងអស់សុទ្ធតែអត់ល្អ។ ពួកគេមើលងាយពួកយើងទាំងមិនបានយល់ពីអារម្មណ៍របស់ក្មេងៗ ដែលរស់នៅក្នុងមណ្ឌលទេ។*
- ⇨ *ខ្ញុំ និងម្តាយក្មេកខ្ញុំ ពួកយើងតែងតែឈ្លោះប្រកែកគ្នា។ ខ្ញុំចាំថាមានពេលមួយគាត់ជេរខ្ញុំ និងហៅខ្ញុំថាជាស្រីសំផឹង ហើយក្រោយមកគាត់បានហៅកូនស្រីខ្ញុំដូចនោះដែរ។ នៅពេលខ្ញុំលឺគាត់និយាយពាក្យសម្តីបែបនេះ ខ្ញុំពិតជាឈឺចិត្តមែនទែន...ខ្ញុំយំ ខ្ញុំពិតជាឈឺចិត្តខ្លាំងមែនទែន ហើយខ្ញុំស្ទើរតែមិនអាចក្រោកដើររួច។ ខ្ញុំចង់តែបោកក្បាលនឹងជញ្ជាំងសម្លាប់ខ្លួនឯង។*
- ⇨ *ប្រសិនបើបងជាប្រពន្ធ ហើយខ្ញុំជាប្តីវិញ ហើយរាល់ពេលខ្ញុំបើកប្រាក់ខែ ខ្ញុំគិតតែពីចំណាយលុយនេះសម្រាប់ខ្លួនឯង និងមើលងាយប្រពន្ធដូចជាសម្រាម។ បើសិនជាខ្ញុំធ្វើអញ្ចឹង តើបងនឹងមានអារម្មណ៍យ៉ាងណាដែរ? ពេលលឺខ្ញុំសួរអញ្ចឹង គាត់ឆ្លើយថា "ខ្ញុំមិនដឹងពីអារម្មណ៍ហ្នឹងទេ ព្រោះអីខ្ញុំជាប្រុស។ អ្នកឯងជាប្រពន្ធ ហើយករណីនេះវាកើតឡើងចំពោះតែអ្នកប៉ុណ្ណោះ។ ខ្ញុំអត់ដឹងពីអារម្មណ៍ឈឺចាប់ហ្នឹងទេ អញ្ចឹងឈប់និយាយពីរឿងហ្នឹងជាមួយខ្ញុំទៀត"។*

## ការអនុវត្តន៍ការរើសអើង

ជនរួចពីរងគ្រោះបាននិយាយរៀបរាប់ពីទម្រង់យ៉ាងច្រើននៃ "ការរើសអើងសង្គម" នៅក្នុងអំឡុងពេលប៉ាន់ប្រមាណរយៈពេល៤ឆ្នាំនេះ (មើលក្នុងតារាងទី៥)។ បទពិសោធន៍រើសអើង៣ប្រភេទ ដែលអ្នកតបសម្ភាសន៍ទាំងពីរក្រុមបានរៀបរាប់ច្រើនជាងគេបំផុតគឺ ការរំលោភដោយពាក្យសម្តី និងការជេរស្តី មានចំនួនស្មើនឹង៣១.៧% (១៩នាក់ n=60ដង) ការផ្តាច់ខ្លួនពីសហគមន៍ និង/ឬគ្រួសារ មានចំនួន៣០% (១៨នាក់ពីក្រុមទាំងពីរ n=60ដង) និងអំពើហិង្សាក្នុងគ្រួសារ មាន២៥.៧% នៃអ្នកតបសម្ភាសន៍ដែលបានរៀបការ ឬមានដៃគូ (ស្មើនឹង៩នាក់ក្នុងចំណោមអ្នកមានប្តី ឬដៃគូ៣៥នាក់)។

ភាគរយនៃអ្នកដែលបានរៀបរាប់ពីបទពិសោធន៍នៃការរើសអើង គឺមានភាពស៊ីគ្នាជាមួយនឹងភាគរយនៃអ្នក ដែលបានបង្ហាញឲ្យស្គាល់ពីក្រុមអ្នកមាក់ងាយ ព្រោះអ្នកតបសម្ភាសន៍ស្ទើរតែទាំងស្រុង បានរៀបរាប់ពីសមាភាពនៃការមាក់ងាយនេះព្រមៗគ្នាតែម្តង។ ជាថ្មីម្តងទៀត អត្រាប្រេវ៉ាឡង់នៃការរើសអើង គឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាងក្រុមស្ត្រី/ក្មេងស្រី SP/RC និងក្រុមស្ត្រី/ក្មេងស្រី RC (មើលតារាងទី៥)។ នៅក្នុងក្រុមទាំងពីរនេះមានអតិថិជន ដែលនិយាយពីការប្រឈមជាមួយនឹងការរើសអើងក្នុងរយៈពេលជាច្រើនឆ្នាំ។ អ្នកតបសម្ភាសន៍បានរៀបរាប់ពីការរំលោភបំពានដោយពាក្យសម្តី និងអំពើហិង្សាក្នុងគ្រួសារកើតឡើងអស់រយៈពេលជាច្រើនឆ្នាំពីសំណាក់ប្តី និងឪពុកម្តាយក្មេក (មើលតារាងទី៤)។ ៣នាក់ក្នុងចំណោម៤នាក់នៃអ្នកតបសម្ភាសន៍ពីក្រុមស្ត្រី/ក្មេងស្រី SP/RC និង៩នាក់ក្នុងចំណោម១៣នាក់ពីក្រុមស្ត្រី/ក្មេងស្រី RC។

**តារាងទី5៖ អត្រាប្រេវ៉ាឡង់នៃការរើសអើង ដែលស្ត្រី/ក្មេងស្រី SP/RCបានជួបប្រទះ (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់) ឆ្នាំ២០១១ដល់២០១៤**

| Survivors talk about discrimination practices: | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | n* | % | Total Count | Individuals w/ Multiple Years | n* | % | Total Count | Individuals w/ Multiple Years |
| Verbal abuse | 7 | *21.2* | 13 | 4 | 12 | *44.4* | 27 | 9 |
| Social isolation in the community | 4 | *12.1* | 4 | | 9 | *33.3* | 15 | 5 |
| Domestic violence | 4 | *12.1* | 9 | 4 | 5 | *18.5* | 10 | 3 |
| Social isolation in the family | 0 | *0* | 0 | | 5 | *18.5* | 6 | 1 |
| Sexual harassment | 2 | *6.1* | 2 | | 4 | *14.8* | 6 | 2 |
| Gossip | 6 | *18.2* | 6 | | 4 | *14.8* | 7 | 2 |
| Extortion / Corruption | 1 | *3.0* | 1 | | 4 | *14.8* | 4 | |
| Sexual violence | 1 | *3.0* | 2 | 1 | 3 | *11.1* | 3 | |
| Abandonment | 0 | *0* | 0 | | 3 | *11.1* | 4 | 1 |
| Collusion | 0 | *0* | 0 | | 2 | *7.4* | 2 | |
| Workplace / Community violence | 1 | *3.0* | 1 | | 2 | *7.4* | 4 | 1 |
| Sexual exploitation | 3 | *9.1* | 4 | 1 | 1 | *3.7* | 2 | 1 |
| Threatening physical harm | 1 | *3.0* | 1 | | 0 | *0* | 0 | |
| Total** | 16 | *48.5* | 43 | 4 | 21 | *77.8* | 90 | 12 |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
Blank - No Observations
* -Number of Individuals
** - Individuals talk about multiple discrimination practices; therefore, counts are not additive.

ជាញឹកញាប់អ្នកតបសម្ភាសន៍ រៀបរាប់បទពិសោធន៍ទទួលការមាក់ងាយ ដោយបញ្ជាក់ពីក្រុមអ្នកមាក់ងាយពួកគេបានយ៉ាងច្បាស់។ តាមរបៀបនេះ ជនរួចពីរងគ្រោះជាទៀងទាត់បានពិព័ណ៌នាពីការប្រឈមជាមួយនឹងការមាក់ងាយដូចជា៖

- ទទួលរងនូវការផ្តាច់ខ្លួនពីសង្គម និងការនិយាយដើមពីសំណាក់អ្នកជិតខាង អ្នករួមការងារ មិត្តរួមថ្នាក់ និងក្រុមគ្រួសាររបស់ពួកគេ។

- ទទួលរងនូវការរំលោភបំពានដោយពាក្យសម្ដី និងអំពើហិង្សាក្នុងគ្រួសារពីសំណាក់ប្ដី/ដៃគូ និងឪពុកម្ដាយក្មេក។
- ទទួលរងនូវការយាយី ការកេងប្រវ័ញ្ច និងអំពើហិង្សាលើផ្លូវភេទ នៅខណៈពេលពួកគេបម្រើការងារក្នុងវិស័យកម្សាន្ត (ប៉ុន្តែមិនមែនគ្រប់ការងារទាំងអស់សុទ្ធតែជាអ្នកធ្វើការរកស៊ីលក់ផ្លូវភេទនោះទេ) ហើយករណីខ្លះវាក៏កើតមានឡើងនូវបញ្ហានេះ នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ ដែរ។
- ការឃុបឃិត ការបោះបង់ចោល ការជំរិតយកប្រាក់ ឬអំពើពុករលួយពីសំណាក់ប្ដី/ដៃគូ និង/ឬគ្រួសាររបស់ប្ដី ជាពិសេសនៅពេលដែលនាងត្រូវបានដៃគូរបស់នាងបដិសេធ ឬមិនទទួលយកទុកដូចជាប្រពន្ធ។

ឧទាហរណ៍បីដែលជនរួចពីរងគ្រោះបានរៀបរាប់ពីបទពិសោធន៍ទទួលរងនូវការរើសអើង៖

⇨ *ពួកគេចាប់ផ្ដើមឈប់និយាយរកខ្ញុំនៅពេលពួកគេបានដឹងពីប្រវត្តិរបស់ខ្ញុំ។ ពួកគេចាប់ផ្ដើមមើលងាយខ្ញុំ ហើយគិតថាខ្ញុំជាមនុស្សមិនល្អ។ ពួកគេមិនចាត់ទុកខ្ញុំជាមនុស្សម្នាក់ ដែលស្ថិតនៅក្នុងក្រុម ឬឋានៈដូចពួកគេទេ។ ចាស! ជាការពិតពួកគេមិនឲ្យតម្លៃខ្ញុំទេ។ ពួកគេមើលងាយខ្ញុំ ព្រោះពួកគេបានដឹងពីប្រវត្តិរបស់ខ្ញុំ... ខ្ញុំចាប់ផ្ដើមមានអារម្មណ៍បែបនេះតាំងពីពេល ដែលពួកគេបានលឺពីរឿងរបស់ខ្ញុំ ហើយពួកគេចាប់ផ្ដើមលែងសូវមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងខ្ញុំ... បន្ទាប់ពីពួកគេបានដឹងពីប្រវត្តិរបស់ខ្ញុំ ពួកគេចាប់ផ្ដើមយករឿងរបស់ខ្ញុំទៅប្រាប់អ្នកទើបចូលមកធ្វើការថ្មីទៀត។ ពួកគេប្រាប់រឿងទាំងអស់របស់ខ្ញុំទៅបុគ្គលិកថ្មី។*

⇨ *មុនពេលខ្ញុំសម្រាលកូនខ្ញុំ ខ្ញុំបានខំប្រឹងធ្វើការងារ និងលក់ផលិតផលសំអាងខ្លះ ដើម្បីសន្សំលុយសម្រាប់ទៅមន្ទីរពេទ្យ។ ប្ដីខ្ញុំ គាត់ខូចមែនទែន។ គាត់បានយកលុយ ដែលខ្ញុំបានសន្សំសម្រាប់សម្រាលកូននេះទាំងអស់ទៅឲ្យម្ដាយគាត់ដើម្បីយកទៅទិញម៉ូតូ។ ហេតុការណ៍នេះបានកើតឡើងមុនតែពីរថ្ងៃប៉ុណ្ណោះ មុនពេលខ្ញុំសម្រាលកំណើតកូនខ្ញុំ។ នៅយប់ដែលខ្ញុំសម្រាលកូន ខ្ញុំមានលុយតែ១ម៉ឺនរៀលតែប៉ុណ្ណោះ...។ ខ្ញុំបានសុំអង្វរពេទ្យឲ្យសម្រាលឲ្យខ្ញុំ ហើយដល់ព្រឹកស្អែកខ្ញុំនឹងបង់ប្រាក់សម្រាប់ថ្លៃសម្រាល...។ ការសម្រាលកូនខ្ញុំពេលនេះគឺពិតជាលំបាកមែនទែន ព្រោះអីក្បាលកូនរបស់ខ្ញុំធំ ប៉ុន្តែត្រគាករបស់ខ្ញុំតូច...។ ប្រសិនបើខ្ញុំមិនអាចសម្រាលកូនបានតាមធម្មជាតិ ខ្ញុំពិតជាស្លាប់មិនខាន ព្រោះអីខ្ញុំគ្មានលុយសម្រាប់ការវះកាត់ទេ។*

⇨ *វាពិបាកនៅពេលដែលគ្រួសារសាច់ថ្លៃប្រព្រឹត្តមិនសមរម្យដាក់ខ្ញុំ។ នៅពេលណាខ្ញុំធ្វើអីខុសមួយ នៅពេលថ្ងៃ ប្តីរបស់ខ្ញុំគាត់ស្តីរឲ្យខ្ញុំនៅចំពោះមុខគេឯងគ្រប់គ្នា តែនៅពេលយប់វិញ គាត់វាយធ្វើបាបខ្ញុំ និងធ្វើមិនសមរម្យជាច្រើនដាក់ខ្ញុំ។ គាត់វាយខ្ញុំពេលខ្លះរហូតដល់ជាំ និងខៀវភ្នែក។ គាត់វាយខ្ញុំដល់បាក់ធ្មេញ និងមានស្នាមជាំ។ ខ្ញុំមានស្នាមជាំនៅលើជើង និងពេញខ្លួនទាំងអស់ ដោយសារគាត់វាយធ្វើបាបខ្ញុំ។ ខ្ញុំឈឺចាប់មែនទែន ប៉ុន្តែខ្ញុំគិតថាខ្ញុំត្រូវតែទ្រាំព្រោះអីខ្ញុំរស់នៅទីនេះតែម្នាក់ឯងជាមួយនឹងឪពុកម្តាយក្មេក។ ឪពុកម្តាយខ្ញុំមិនរស់នៅទីនេះទេ។ ខ្ញុំអត់មានផ្ទះជារបស់ខ្លួនឯង។*

## សេចក្តីសង្ខេបទាក់ទងនឹងការមាក់ងាយ

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ យើងឃើញជនរួចពីរងគ្រោះបានរៀបរាប់ពីប្រធានបទធំៗសំខាន់បី ដែលភាគច្រើនជាដើមចមនៃការមាក់ងាយ។ ប្រធានបទទាំងបីនោះមាន៖ វិសមភាពយេនឌ័រ លទ្ធភាពអាពាហ៍ពិពាហ៍ និងស្ថានភាពសេដ្ឋកិច្ចសង្គម។ ទិដ្ឋភាពមួយចំនួននៃសញ្ញាណយេនឌ័រ ត្រូវបានចាត់ទុកថាជាគោលការណ៍សំខាន់មួយនៅក្នុងប្រពៃណីវប្បធម៌សង្គមខ្មែរ៖ ព្រហ្មចារីរបស់កូនក្រមុំ និងឋានៈខ្ពង់ខ្ពស់របស់កូនកម្លោះ គឺពិតជាមានទាក់ទងទៅនឹងស្ត្រី(Gorman and Kheng 1999)។ ចំណងអាពាហ៍ពិពាហ៍ គឺជាបទដ្ឋានដែលត្រូវបានគេឲ្យតម្លៃយ៉ាងខ្លាំងនៅក្នុងសង្គមកម្ពុជា។ ហេតុនេះហើយការទទួលបាន ឬបាត់បង់ឋានៈក្នុងការទទួលបានអាពាហ៍ពិពាហ៍ គឺពិតជាកត្តាសំខាន់ណាស់ ដែលវាមិនគ្រាន់តែមានសារៈសំខាន់ចំពោះបុគ្គលម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែវាមានសារៈសំខាន់សម្រាប់គ្រួសាររបស់គេទាំងមូលតែម្តង (រាប់បញ្ចូលទាំងសាច់ញាតិគ្រួសារធំ)។ សមត្ថភាពក្នុងការបង្កើនស្ថានភាពសេដ្ឋកិច្ចសង្គមរបស់បុគ្គលម្នាក់ និងស្ថានភាពក្រុមគ្រួសារ ក៏ជាបទដ្ឋានសង្គមមួយដ៏មានតម្លៃ ដែលវាអាចជះឥទ្ធិលដល់អាពាហ៍ពិពាហ៍ផងដែរ។

ប្រធានបទស្តីពីវិសមភាពយេនឌ័រ លទ្ធភាពអាពាហ៍ពិពាហ៍ និងស្ថានភាពសេដ្ឋកិច្ចសង្គមគឺមានបញ្ជាក់យ៉ាងច្បាស់តាមរយៈសាច់រឿងរបស់ជនរួចពីរងគ្រោះ នៅពេលពួកគេរៀបរាប់ពីការមាក់ងាយ ការដាក់ងារអវិជ្ជមាន ការទទួលបាន និងបាត់បង់ឋានៈសង្គម គុណតម្លៃ និងកិត្តិយសបុគ្គលផ្ទាល់។ ស្ថានភាននៃការមាក់ងាយមានភាពកាន់តែអាក្រក់ខ្លាំង នៅពេលដែលបុគ្គលម្នាក់គិតថាខ្លួនឯងគ្មានតម្លៃ កិត្តិយសគ្រួសារខ្លួនមិនសមនឹងទទួលអាពាហ៍ពិពាហ៍ ហើយបុគ្គលនោះត្រូវបានអ្នកដទៃមើលឃើញថា គេជាមនុស្សមិនមានឥទ្ធិពល ឬគ្មានសមត្ថភាពចូលរួមចំណែកដើម្បីធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសាររបស់គេប្រែមកជាល្អបានឡើយ។ ស្ថានភាពនៃការមាក់ងាយមិនមែនកើតឡើងតែក្នុងដំណាក់កាលដំបូងជុំវិញពេលធ្វើសមាហរណកម្ម ឬកើតឡើងនៅពេលដែលជនរួចពីរងគ្រោះនោះបានរៀបការនោះទេ ប៉ុន្តែស្ថានភាពនៃការមាក់ងាយអាចកើតឡើងគ្រប់ពេលវេលាទាំងអស់ ជាពិសេសនៅពេលដែល

នរណាម្នាក់គិតពិចារណាពីសារៈសំខាន់នៃកិត្តិយសគ្រួសារជាចម្បង។ ដូច្នេះហើយ ការមាក់ងាយអាចជាបញ្ហាដ៏សំខាន់ចំពោះជនរួចពីរងគ្រោះ ដែលវាមិនមែនគ្រាន់តែជាបញ្ហានៅពេលពួកគេធ្វើសមាហរណកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏កើតឡើងនៅក្នុងជីវិតរបស់ពួកគេនៅពេលខាងមុខដែរ គឺនៅពេលពួកគេធ្វើអន្តរកម្មទំនាក់ទំនងនៅក្នុងសហគមន៍។

ខណៈពេលដែលប្រភេទនៃការមាក់ងាយនីមួយៗមានបញ្ចូលនូវលក្ខណៈ ឬស្ថានភាពពិសេសរបស់ខ្លួន ការដាក់ងារអវិជ្ជមាន និងការយល់ឃើញអវិជ្ជមានក្នុងការប្រព្រឹត្តិសំខាន់ៗ ដែលវាមើលទៅហាក់ដូចជាសកម្មភាពសាមញ្ញប្រចាំថ្ងៃ។ ចំនុចនេះបានចងភ្ជាប់ប្រភេទនៃការមាក់ងាយទាំងនេះទៅនឹងកម្រិតនៃស្ថានភាពសេដ្ឋកិច្ចសង្គម លទ្ធភាពអាពាហ៍ពិពាហ៍ និងវិសមភាពយេនឌ័រ (មើលតារាងទី២)។ ការកើតឡើងនេះគឺពិតជាសមហេតុផល ដែលអាចនាំមកនូវភាពស្មុគស្មាញនៅក្នុងជីវិត ការយល់ឃើញពីអាំងតង់ស៊ីតេនៃការមាក់ងាយ និងទំហំនៃការយល់ដឹងរបស់ក្រុមអ្នកមាក់ងាយធ្វើ ឬមិនធ្វើដោយផ្អែកទៅតាមស្ថានភាពបច្ចុប្បន្ន និងប្រវត្តិពីអតីតកាលរបស់ជនរួចពីរងគ្រោះ។ ជាឧទាហរណ៍មានជនរួចពីរងគ្រោះមួយចំនួន បានរៀបរាប់ពីការប្រឈមនឹងការមាក់ងាយ ទាក់ទងនឹងលទ្ធភាពអាពាហ៍ពិពាហ៍ពីសំណាក់ឪពុកម្តាយក្មេក ដោយសារគ្រួសាររបស់ពួកគេមានឋានៈទាបនៅក្នុងសហគមន៍ ហើយការមាក់ងាយនេះ វាមិនមានពាក់ព័ន្ធអ្វីទៅនឹងបទពិសោធន៍ពីអតីតកាលរបស់ពួកគេ ដូចជាធ្លាប់ត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ ឬប្រកបរបរកស៊ីផ្លូវភេទនោះទេ។ ខាងក្រោមគឺជាឧទាហរណ៍បញ្ជាក់ពីករណីទាំងនេះដែលថាការដឹងពីប្រវត្តិអតីតកាលរបស់ជនរួចពីរងគ្រោះ អាចបន្ថែមទៅលើការមាក់ងាយឲ្យកាន់តែខ្លាំងថែមទៀត។

ជនរួចពីរងគ្រោះម្នាក់បានរៀបរាប់ប្រាប់បញ្ហានេះថា៖

- ⇨ *ខ្ញុំបានសម្រេចចិត្តរៀបការជាមួយប្តីខ្ញុំ ព្រោះខ្ញុំមិនចង់ឲ្យអ្នកដទៃមើលងាយខ្ញុំទៀត។ ប្តីរបស់ខ្ញុំសុំខ្ញុំរៀបការ ហើយខ្ញុំក៏បានដឹងថាគាត់មានស្រីក្រៅច្រើនបន្ទាប់ពីភ្ជាប់ពាក្យជាមួយខ្ញុំ។ ខ្ញុំជាមនុស្សម្នាក់ដែលរឹងមាំដែរ ប៉ុន្តែខ្ញុំនៅតែគិតថាជីវិតខ្ញុំគ្មានតម្លៃ។ ពេលខ្លះខ្ញុំគិតថា ខ្លួនខ្ញុំមានតម្លៃតែពាក់ កណ្តាលប៉ុណ្ណោះ...នេះហើយជាមូលហេតុដែលខ្ញុំមិនប្រាប់ប្តីខ្ញុំពីប្រវត្តិពីអតីតកាលរបស់ខ្ញុំ ព្រោះប្រសិនបើគាត់ដឹងរឿងនោះ គាត់នឹងមើលងាយខ្ញុំកាន់តែខ្លាំងជាងសព្វថ្ងៃនេះទៅទៀត។*

បទពិសោធន៍របស់ជនរួចពីរងគ្រោះទាក់ទងនឹងការមាក់ងាយ គឺជាបញ្ហាថាមវន្ត និងស្មុគស្មាញ។ ហើយជាញឹកញាប់វាបានកើតឡើងម្តងហើយម្តងទៀត។ សាច់រឿងរបស់ជនរួចពីរងគ្រោះម្នាក់បានពន្យល់ពីចំនុចនេះ។

ក្មេងស្រីអាយុ១៨ឆ្នាំ នាងបានធ្វើសមាហរណកម្មទៅរស់នៅជាមួយគ្រួសារនាងវិញ នៅពេលនាងមានអាយុ១៦ឆ្នាំ ហើយនាងបានរក្សាទុកនូវបទពិសោធន៍ដូចខាងក្រោម។ ថ្ងៃមួយនាង និងក្រុមគ្រួសារបានទៅចូលរួមពិធីមង្គលការសាច់ញាតិរបស់នាងនៅក្បែរផ្ទះ។ នៅពេលទទួលភ្ញៀវពិសារភោជនាហារ ម្តាយមីងរបស់នាង ដែលមានវ័យរាងចំណាស់ តែមិនទាន់រៀបការបានមកដល់យឺត ដោយមានបុរសពីរនាក់ទៀតមកជាមួយ។ ជាការពិត ម្តាយមីង និងបុរសពីរនាក់នោះបានដល់ដោយស្រវឹងស្រារួចទៅហើយ។ យោងតាមការរៀបរាប់របស់នាង ម្តាយមីង និងបុរសពីរនាក់នោះ និយាយលឺៗ និងមានអាកប្បកិរិយាស្និទ្ធស្នាលជ្រុលពេកនៅទីសាធារណៈ។ វាធ្វើឲ្យជីតារបស់នាងខឹងនឹងអាកប្បកិរិយារបស់ម្តាយមីងនោះ ហើយគាត់ក៏ជេរស្តីជាសាធារណៈពីអាកប្បកិរិយា "ចៃចង់" របស់ម្តាយមីង និងស្តីបន្ទោសដែលគាត់មិនប្រព្រឹត្តខ្លួនឲ្យសមជាស្ត្រីក្រមុំ ដើម្បីលើកស្ទួយកិត្តិយសគ្រួសារ។ ការជជែកឈ្លោះគ្នាខ្លាំងបានកើតឡើងរវាងម្តាយមីងនឹងជីតា។ នាងបានប្រាប់ថា នាងមិនបានចូលទៅជជែកតតាំងជាមួយពួកគាត់នោះទេ ប៉ុន្តែស្រាប់តែនាងមានអារម្មណ៍ថាបញ្ហារបស់នាងបានក្លាយជាទីចាប់អារម្មណ៍យ៉ាងខ្លាំងនៅពេលដែលម្តាយមីងនោះ បែរមកនិយាយពីរឿងរបស់នាង ហើយបានចោទប្រកាន់នាងជាសាធារណៈថាធ្វើឲ្យខូចឈ្មោះគ្រួសារទាំងមូល ដោយសារនាងធ្លាប់ធ្វើការជាស្រីរកស៊ីផ្លូវភេទ "គ្រប់គ្នាដឹងថានាងធ្លាប់ធ្វើការជាស្រីរកស៊ីផ្លូវភេទ"។ បន្ទាប់ពីការចោទប្រកាន់ម្តាយមីងជាសាធារណៈ ពូៗមួយចំនួនបានបែរចំណាប់អារម្មណ៍របស់ពួកគេមកកាន់នាង ហើយគំរាមថានឹងសម្លាប់នាងចោល ប្រសិនបើនាងត្រលប់ទៅផ្ទះ។ ពួកគេមិនចង់ឲ្យនាងរស់នៅក្នុងភូមិទៀតទេ ព្រោះនាងបានធ្វើឲ្យគេភ្លើឈ្មោះគ្រួសារទាំងមូលខូចអស់។ "ខ្ញុំខ្លាច មិនហ៊ានគេងនៅផ្ទះរបស់ខ្ញុំទេ ព្រោះអីម្តាយមីង និងពូៗរបស់ខ្ញុំសន្យាថានឹងមកសម្លាប់ខ្ញុំនៅពេលខ្ញុំដេកលក់"។ បន្ទាប់ពីជំនួបនៃការសម្ភាសន៍នោះមក នាងបានទៅរស់នៅជាមួយគ្រួសាររបស់អ្នកដទៃ និងបានផ្លាស់ប្តូរទៅរស់នៅកន្លែងផ្សេង។

នៅក្នុងការសម្ភាសន៍ក្នុងឆ្នាំ២០១៥ ជនរួចពីរងគ្រោះនេះបានរៀបរាប់ពីការរៀបការថ្មោងថ្មីរបស់នាង និងភាពរំភើបក្នុងអំឡុងពេលរៀបការដោយនាងអាចធ្វើពិធី "កាត់ផ្លែឈើ"។ បន្ទាប់មកនាងរៀបរាប់ប្រាប់ពីការដំឡើងតំណែងរបស់នាង និងការទទួលបានឋានៈជា "មេគ្រួសារ" ពីគ្រួសាររបស់នាង ដោយនាងនិយាយពន្យល់ថា "នៅពេលម្តាយខ្ញុំអត់មានលុយ គាត់តែរមកខ្ចីលុយខ្ញុំ" ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការកើនឡើងនូវស្ថានភាពសង្គម នៅក្នុងក្រុមគ្រួសាររបស់នាងក៏ត្រូវបានជះកំហឹងដល់នាងដូចបានរៀបរាប់នូវក្នុងការពិភាក្សាដូចខាងក្រោម៖

⇨ *ជាការពិត ប្តីខ្ញុំក៏រើសអើងខ្ញុំដែរ។ គាត់មិនបានដឹងថាខ្ញុំធ្លាប់រស់នៅក្នុងអង្គការទេ រហូតដល់ពេលរៀបការរួច។ ឥលូវខ្ញុំមានអារម្មណ៍ថាគាត់អត់សូវចូលចិត្តខ្ញុំប៉ុន្មានទេ។ គាត់ធ្លាប់និយាយ*

*ថា "អា! ប្រសិនបើខ្ញុំដឹងថាឯងជាក្មេងអង្គការ ខ្ញុំនឹងមិនរៀបការជាមួយទេ"។ ពេលគាត់និយាយអញ្ចឹង ខ្ញុំមានអារម្មណ៍ថាពិបាក និងឈឺចាប់ណាស់។*

សាច់រឿងនេះគឺពិតជាមិនមែនមានតែនៅក្នុងចំណោមជនរួចពីរងគ្រោះប៉ុណ្ណោះទេ។ ជនរួចពីរងគ្រោះភាគច្រើនរៀបរាប់ពីការរស់នៅ និងបទពិសោធន៍របស់ពួកគេទាក់ទងនឹងបញ្ហាការមាក់ងាយដែលមានភាពប្រែប្រួល និងស្មុគស្មាញ។

## កត្តាដែលមានឥទ្ធិពលលើការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ

មានកត្តាមួយចំនួន ដែលបានកំណត់នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ ថាបានជះឥទ្ធិពលយ៉ាងខ្លាំងលើបញ្ហាការមាក់ងាយក្នុងចំណោមក្រុមអ្នកចូលរួមនៅក្នុងការសិក្សាប៉ាន់ប្រមាណ។

<u>កម្មវិធីថៃទាំជំនួស និងកម្មវិធីមណ្ឌលស្នាក់នៅ</u> - អ្នកតបសម្ភាសន៍ដែលរស់នៅក្នុងកម្មវិធីថៃទាំជំនួសបានរៀបរាប់តិចតួចប៉ុណ្ណោះពីបទពិសោធន៍ទទួលរងនូវការមាក់ងាយ។ មានតែ៤%នៃចំនួនសរុបក្នុនឆ្នាំនៃការប៉ាន់ប្រមាណ (n=50 មើលតារាងទី៦)។ ចំនុចនេះមិនមែនមានន័យថាជនរួចពីរងគ្រោះមិនបានរៀបរាប់ពីជម្លោះ ឬសកម្មភាពដែលជនរួចពីរងគ្រោះមួយចំនួនមានអារម្មណ៍ទទួលនូវការរើសអើងពីអ្នករស់នៅក្នុងមណ្ឌលជាមួយគ្នានោះទេ។ ជនរួចពីរងគ្រោះជាច្រើននាក់បាននិយាយពីជម្លោះ ជាពិសេសនៅពេលពួកគេទើបនឹងចូលក្នុងកម្មវិធីមណ្ឌលដំបូងៗ។ ប៉ុន្តែស្ទើរគ្រប់ករណីទាំងអស់ជម្លោះទាំងអស់នេះវាគ្រាន់តែកើតឡើងក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ទោះបីជាស្ថានភាពទាំងនេះ វាហាក់ដូចជាសំខាន់ក្នុងជីវិតរបស់ជនរួចពី រងគ្រោះ នៅខណៈពេល ដែលកើតមាននូវបញ្ហានេះ ប៉ុន្តែបញ្ហាទាំងនេះមិនត្រូវបានកំណត់ចូលជាបទពិសោធន៍ទទួលរងនូវការមាក់ងាយ នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះទេ។ នេះដោយសារមានមូលហេតុពីរយ៉ាង។ មូលហេតុទី១ គឺមិត្តភក្តិរួមមណ្ឌលជាទូទៅមានប្រវត្តិរូបស្រដៀងៗគ្នា ហើយគ្មានការបែងចែកអំណាចពិតប្រាកដ ដែលអាចឲ្យយើងចាត់ទុកជាកត្តាជាក់លាក់ចំពោះជម្លោះទាំងនោះទេ។ ចំនុចទី២គឺថាទោះបីជាកម្មវិធីថៃទាំជំនួស ពេលខ្លះមិនមែនជាកន្លែង ដែលគ្មានការមាក់ងាយទាំងស្រុង តែគុណតម្លៃស្នូលនៃកម្មវិធីទាំងនេះមានគោលបំណងការពារជនរួចពីរងគ្រោះពីជម្លោះ និងស្ថានភាពមាក់ងាយ។

តារាងទី៦៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រីSP/RC និងក្រុមស្ត្រី/ក្មេងស្រីRC បែងចែកតាមឆ្នាំបន្ទាប់ពីធ្វើសមាហរណកម្ម

| Year | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | No Stigma | | Stigma | | No Stigma | | Stigma | |
| | n* | % | n* | % | n* | % | n* | % |
| SP ** | 48 | *96.0* | 2 | *4.0* | -- | | -- | -- |
| RC Year 1 | 24 | *72.7* | 9 | *27.3* | 21 | *77.8* | 6 | *22.2* |
| RC Year 2 | 19 | *65.5* | 10 | *34.5* | 9 | *33.3* | 18 | *66.7* |
| RC Year 3 | 8 | *61.5* | 5 | *38.5* | 11 | *40.7* | 16 | *59.3* |
| RC Year 4 | | | | | 7 | *36.8* | 12 | *63.2* |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
* - Total Number of individual observations (Individual Assessment Years)
** - Shelter Programs (SP); Stigma frequency assessed for all years survivors stayed in SP
"--" - No long-term stay in SP
Blank - No observations

ការសិក្សាប៉ាន់ប្រមាណពីការមាក់ងាយតាមឆ្នាំនីមួយៗ បន្ទាប់ពីធ្វើសមាហរណកម្មបានបញ្ជាក់ឲ្យឃើញថា នៅឆ្នាំទី១ ការមាក់ងាយមានអត្រាប្រេវ៉ាឡង់ទាបជាងគេបំផុត។ ប្រេកង់នៃការមាក់ងាយនៅក្នុងឆ្នាំទី១គឺមាន២៧.៣% និង២២.២% ចំពោះក្រុមស្ត្រី/ក្មេងស្រី SP/RC និងក្រុមស្ត្រី/ក្មេងស្រីRC តាមលំដាប់រៀងគ្នា (មើលតារាងទី៦)។ អត្រាប្រេវ៉ាឡង់នៃការមាក់ងាយមានការកើនឡើងនៅឆ្នាំបន្តបន្ទាប់សម្រាប់ក្រុមទាំងពីរ (មានការកើនឡើងខ្លាំងចំពោះក្រុមស្ត្រី/ក្មេងស្រីRC)។ លទ្ធផលនៃការសិក្សានេះបានបញ្ជាក់ថា នៅឆ្នាំទី១បន្ទាប់ពីធ្វើសមាហរណកម្ម វាមើលទៅហាក់ដូចជាមិនសូវមានបញ្ហាលំបាកដូចឆ្នាំបន្តបន្ទាប់ប៉ុន្មានទេចំពោះជនរួចពីរងគ្រោះទាក់ទងនឹងបញ្ហាការមាក់ងាយ។

អាចមានមូលហេតុមួយចំនួន ដែលធ្វើឲ្យជនរួចពីរងគ្រោះរៀបរាប់ពីបញ្ហាការមាក់ងាយតិចតួច នៅក្នុងឆ្នាំទី១។ មូលហេតុទាំងនោះរួមមានដូចជា ផែនការធ្វើសមាហរណកម្ម ដែលមានការគិតបានយ៉ាងល្អិតល្អន់ កម្មវិធីបណ្តុះបណ្តាលការងារ និងការទទួលបានការងារធ្វើភ្លាមៗ និង/ឬសេវាតាមដាន និងការគាំទ្រទៅនឹងស្ថានភាពមួយចំនួន ដែលធ្វើឡើងដើម្បីឆ្លើយតបនឹងការមាក់ងាយសំខាន់ៗ ឬកាត់បន្ថយបញ្ហាការមាក់ងាយ។ មិនថាជាយ៉ាងណាក្តី លទ្ធផលនៃការសិក្សានេះមានការប៉ះពាល់ សម្រាប់ប្រធានកម្មវិធីក្នុងការដែលពួកគេគិតពិចារណាពីវិសាលភាពនៃធនធាន និងរយៈពេលនៃការតាមដានចំពោះជនរួចពីរងគ្រោះនៅពេលពួកគេចាប់ផ្តើមធ្វើសមាហរណកម្មទៅសហគមន៍វិញ។

<u>ជាតិសាសន៍</u> – ជាតិសាសន៍ គឺជាកត្តាមួយដ៏សំខាន់ក្នុងការស្វែងយល់ពីសក្តានុពលនៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ (មើលតារាងទី៧)។ នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ យើងធ្វើការសិក្សាទៅលើការមាក់ងាយ ដែលភាគច្រើនជាប់ទាក់ទងនឹងបទដ្ឋានសង្គម និងវប្បធម៌កម្ពុជា។ ជនរួចពីរង

គ្រោះជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា គឺជាទូទៅមិនមានពាក់ព័ន្ធទៅនឹងវប្បធម៌កម្ពុជា ហើយវាក៏ដូចគ្នាដែរ ចំពោះជនរួចពីរងគ្រោះដែលមានសញ្ញាតិចម្រុះជាតិសាសន៍។ ជាទូទៅ ពួកគេមិនបានចែករំលែកពីក្តីព្រួយបារម្ភ និងបទពិសោធន៍ស្រដៀងគ្នាទាក់ទងនឹងការមាក់ងាយនេះទេ។ ការសិក្សាផ្សេងៗទៀតដែលបញ្ជាក់ពីលទ្ធផលនៃការសិក្សាទាំងនេះ បានបង្ហាញថាសហគមន៍វៀតណាមអាចមានទិដ្ឋភាពជាក់ស្តែងច្រើនជាងនេះ ដែលជាហេតុធ្វើឲ្យទស្សនៈមាក់ងាយមានតិចតួចទៅលើការប្រកបរបរផ្លូវភេទ (Reimer et al. 2007)។ ទោះបីជា ក្រុមនេះមិនបានរៀបរាប់ពីការមាក់ងាយពូជសាសន៍ វាក៏នៅតែជាប្រធានបទមួយគួរឲ្យកត់សម្គាល់ដែរ ជាពិសេសរវាងជនជាតិខ្មែរនឹងជនជាតិវៀតណាម (Berman 1996)។ លើសពីនេះទៅទៀត សំណួរភាគច្រើននៅក្នុងបញ្ជីសំណួរអង្កេត ផ្តោតសំខាន់តែទៅលើការមាក់ងាយនៅក្នុងបរិបទក្រុមគ្រួសារ និងសហគមន៍ ហើយសំណួរទាំងនោះមិនបានសួរបញ្ជាក់ឲ្យចំទៅលើការមាក់ងាយ ឬការរើសអើងពូជសាសន៍នោះទេ។

**តារាងទី7៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយបែងចែកតាមជាតិសាសន៍ ខណៈពេលពួកគេរស់នៅក្នុងសហគមន៍**

| Ethnicity | Female SP/RC and Female RC | | | |
|---|---|---|---|---|
| | No Stigma | | Stigma | |
| | n* | % | n* | % |
| Khmer** | 74 | *50.3* | 73 | *49.7* |
| Vietnamese | 7 | *100* | | |
| Khmer / Vietnamese | 12 | *75.0* | 4 | *25.0* |
| Khmer / Thai | 5 | *100* | | |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
* - Total Number of individual observations in community (Individual Assessment Years)
** - Khmer includes Khmer / Chinese
Blank - No observations

<u>ស្ថានភាពអាពាហ៍ពិពាហ៍</u> - ស្ថានភាពអាពាហ៍ពិពាហ៍ក៏ជាកត្តាសំខាន់មួយដែរ ទាក់ទងនឹងការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ។ ទិន្នន័យបានបង្ហាញពីស្ថានភាពអាពាហ៍ពិពាហ៍ គឺអ្នកនៅលីវមានអត្រាប្រេវ៉ាឡង់នៃការមាក់ងាយទាបជាងគេ ខណៈពេលដែលអ្នកមានទំនាក់ទំនងដៃគូរយៈពេលវែងមានអត្រាប្រេវ៉ាឡង់ខ្ពស់ជាងគេបំផុត (មើលតារាងទី៨)។ ការមាក់ងាយដែលកើតមានចំពោះអ្នកមានទំនាក់ទំនងដៃគូរយៈពេលវែងភាគច្រើនបង្ករដោយសារបញ្ហាវិសមភាពយេនឌ័រ និងកង្វះនូវការទទួលស្គាល់ពីសំណាក់ឪពុកម្តាយក្មេក។ ស្ថានភាពអាពាហ៍ពិពាហ៍ដូចជាការលែងលះក៏មានអត្រាប្រេវ៉ាឡង់នៃការមាក់ងាយខ្ពស់ដែរ (មើលតារាងទី៨)។ លទ្ធផលនេះគឺស៊ីគ្នាជាមួយនឹងកម្រិតខ្ពស់នៃការមាក់ងាយវប្បធម៌ទាក់ទងនឹង លទ្ធភាពអាពាហ៍ពិពាហ៍ យេនឌ័រ និងការលែងលះ។

**តារាងទី៨៖ ភាគរយនៃជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការមាក់ងាយក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រីជនជាតិខ្មែរបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និងក្រុមអ្នកចូលរួម ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤**

| Marital Status | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | No Stigma | | Stigma | | No Stigma | | Stigma | |
| | n* | % | n* | % | n* | % | n* | % |
| No Previous Marriage/Partner | | | | | | | | |
| Single | 21 | *61.8* | 13 | *38.2* | 12 | *63.2* | 7 | *36.8* |
| New Partner/Married** | 10 | *71.4* | 4 | *28.6* | 1 | *20.0* | 4 | *80.0* |
| Partner / Married > 1-Year | 2 | *33.3* | 4 | *66.7* | 13 | *44.8* | 16 | *55.2* |
| Divorce / Separated | | | | | | | | |
| Single | 1 | *50.0* | 1 | *50.0* | 6 | *42.9* | 8 | *57.1* |
| New Partner/Married** | 1 | *50.0* | 1 | *50.0* | 2 | *40.0* | 3 | *60.0* |
| Partner / Married > 1-Year | | | | | 5 | *31.3* | 11 | *68.8* |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
* - Total Number of individual observations in community (Individual Assessment Years) for all Khmer survivors
** - New Partner/Married for less than 1-Year
Blank - No observations

## 4.4 ការយល់ដឹងពីការមាក់ងាយដោយខ្លួនឯង

ជនរួចពីរងគ្រោះប្រហែលជាមានការចម្រូងចម្រាសជាមួយនឹងគំនិតបែបមាក់ងាយខ្លួនឯង ដែលកើតឡើងម្តងហើយម្តងទៀត ព្រមជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តអំឡុងពេលទទួលរងនូវការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរ។ Zimmerman et al. (2014) បានបង្ហើបឱ្យឃើញនូវលទ្ធផលនៃការសិក្សានេះថាមាន ៧៥% នៃស្ត្រីជាជនរួចពីរងគ្រោះដែលបានរាយការណ៍ថាមានអំពើហិង្សាផ្លូវភេទ ពួកគេមានក្តីព្រួយបារម្ភរួចទៅហើយថាតើអ្នកផ្ទះនៅក្នុងសហគមន៍របស់គេនឹងប្រព្រឹត្តចំពោះគេយ៉ាងដូចម្តេច គឺពួកគេមានក្តីព្រួយបារម្ភនេះតាំងពីពេល ដែលពួកគេស្ថិតនៅក្នុងស្ថានភាពជួញដូរមកម្ល៉េះ។ ការឆ្លើយតបទាំងនេះបានបញ្ជាក់ពី "ការយល់ដឹងពីក្តីបារម្ភ" ទាក់ទងនឹងការមាក់ងាយក្នុងចំណោមអ្នកចូលរួមក្នុងការសិក្សាប៉ាន់ប្រមាណ។ ដូចបានពិភាក្សាខាងលើ អ្នកតបសម្ភាសន៍ ជាពិសេសប្រជាជនខ្មែរ ពួកគេបានធំដឹងក្តីដោយបានរៀនដក់ជាប់ទៅហើយទាក់ទងនឹងចំនុចមួយចំនួនដូចជាច្បាប់ស្រី និងការដាក់ងារពាក់ព័ន្ធនឹង "អាកប្បកិរិយារបស់ស្ត្រី ឬក្មេងស្រី ដែលអាចទទួលយក និងមិនអាចទទួលយកបាន" ពីសំណាក់សង្គមរបស់ពួកគេ (មើលការពិភាក្សានៅក្នុងទំព័រទី៧)។ នៅក្នុងអំឡុងពេលទទួលការជួញដូរ ឬការកេងប្រវ័ញ្ចផ្លូវភេទ ពេលខ្លះជនរួចពីរងគ្រោះយល់ឃើញថាស្ថានភាពជីវិតរបស់ពួកគេត្រូវបានផ្លាស់ប្តូរអស់ហើយ ហើយឥលូវនេះ ជីវិតរបស់ពួកត្រូវចូលទៅក្នុងស្ថានភាពសង្គមមួយផ្សេងទៀត ដែលជាស្ថានភាពសង្គមមួយប្រកបដោយការយល់ឃើញ និងការឲ្យតម្លៃបែបអវិជ្ជមានដល់ពួកគេ។ ខណៈពេលជនរួចពីរងគ្រោះបាន "យល់ដឹងពីការមាក់ងាយ" ពួកគេប្រហែលជាបានប្រឈមជាមួយនឹងគំនិតបែបមាក់ងាយ និងរើសអើងខ្លួនឯងរួចទៅហើយ។ ស្ថានភាពទាំងនេះបានបញ្ជាក់យ៉ាងច្បាស់តាមរយៈពាក្យសម្តីរបស់ជនរួចពីរងគ្រោះ៖

- *ខ្ញុំមានអារម្មណ៍ថា ខ្លួនខ្ញុំអត់មានអីទាំងអស់ ដោយសារតែខ្ញុំធ្លាប់បានគេធ្វើបាបម្តងរួចមកហើយ។ អញ្ចឹងហើយបានជាខ្ញុំយល់ព្រមទៅធ្វើការ(នៅផ្ទះបន)ជាមួយម្នាក់ហ្នឹង បន្ទាប់ពីគេបានធ្វើបាបខ្ញុំ។*

- *នៅពេលខ្ញុំបានជួបនឹងបញ្ហាហ្នឹង ខ្ញុំមិនដែលគិតថាខ្ញុំអាចសង្គ្រោះខ្លួនឲ្យបានល្អប្រសើរជាងពេលនោះទេ...ពីមុនខ្ញុំមិនដែលគិតថាត្រូវធ្វើយ៉ាងម៉េច ដើម្បីឲ្យជីវិតរបស់ខ្ញុំបានប្រសើរនោះទេ។ ខ្ញុំតែងតែគិតថាខ្លួនខ្ញុំជាមនុស្សមិនល្អដូចអ្នកដទៃនិយាយអញ្ចឹង ហើយទោះបីជាខ្ញុំខំប្រឹងធ្វើល្អយ៉ាងណា ក៏អ្នកដទៃនៅតែគិតថាខ្ញុំជាមនុស្សអាក្រក់ដដែល។*

- *ខ្ញុំធ្វើការមិនល្អ ហើយខ្ញុំបានក្លាយជាមនុស្សមិនល្អ។*

- *ខ្ញុំមានអារម្មណ៍ខ្មាសអៀន ហើយខ្ញុំគិតថាខ្លួនខ្ញុំជាមនុស្សមិនល្អ។*

## ការឆ្លើយតបជាបន្តបន្ទាប់ទៅនឹងការមាក់ងាយ

ការឆ្លើយតបរបស់ជនរួចពីរងគ្រោះចំពោះការដាក់ងារ និងការយល់ឃើញជាអវិជ្ជមាន មានវិសាលភាពជាបន្តបន្ទាប់តាំងពីស្ថិតក្នុងស្ថានភាពបាក់ទឹកចិត្តរហូតដល់ស្ថានភាពពង្រឹងអំណាច។ ជនរួចពីរងគ្រោះមួយចំនួនបានរៀបរាប់ពីការផ្លាស់ប្តូរការគិតរបស់ពួកគេ ដោយសារពួកគេបានទទួលសេវាប្រឹក្សាយោបល់ និងសេវាផ្សេងៗទៀតពីកម្មវិធីរបស់អង្គការ។ ជនរួចពីរងគ្រោះពីរនាក់បានបង្ហាញពីគំលាតនៃការឆ្លើយតបទាំងនេះ៖

- *បន្ទាប់ពីខ្ញុំបានលែងលះជាមួយប្តីខ្ញុំ ហើយវិលមករស់នៅក្នុងប្រទេសកម្ពុជាវិញ អ្នកជិតខាងរបស់ខ្ញុំមើលងាយខ្ញុំដោយសារជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំមិនជោគជ័យ ហើយម្យ៉ាងទៀតខ្ញុំត្រលប់មកខ្មែរវិញ ក្រ។ ខ្ញុំអត់មានលុយសោះ។ មុនពេលខ្ញុំរៀបការ នៅជាក្រមុំព្រហ្មចារី ខ្ញុំស្អប់ស្រីខារ៉ាអូខេណាស់ ប៉ុន្តែបន្ទាប់ពីខ្ញុំបានលែងលះគ្នា ខ្ញុំលែងខ្វល់ពីខ្លួនខ្ញុំទៀតហើយ។ ខ្ញុំបានគិតថាខ្ញុំគួរតែទៅធ្វើការនៅហាងខារ៉ាអូខេ ព្រោះអីខ្ញុំមិនមែនជាក្រមុំព្រហ្មចារីអីទៀតហើយ ម្យ៉ាងទៀតគ្រប់ៗគ្នាសុទ្ធតែបានបន្ទោសខ្ញុំរួចទៅហើយដោយសារខ្ញុំលែងលះគ្នា...។ ខ្ញុំមានអារម្មណ៍ខ្មាសអៀនខ្លាំងរួចទៅហើយពីអ្នកជិតខាងរបស់ខ្ញុំ ដោយសារការលែងលះ និងដោយសារតែខ្ញុំក្រ។ អញ្ចឹងហើយខ្ញុំសម្រេចចិត្តបន្ថែមភាពខ្មាសអៀននេះទៀត ដោយសារទៅធ្វើការនៅក្នុងហាងខារ៉ាអូខេ។*

- *និយាយដោយស្មោះទៅ ប្រសិនបើមានក្មេងស្រីដែលគាត់ជួបប្រទះបញ្ហាដូចខ្ញុំ ខ្ញុំចង់ឲ្យពួកគេរឹងមាំឡើង និងកុំឆោរឡោ...ប្រសិនបើមានបញ្ហា សូមកុំមានភាពភ័យខ្លាចខ្លាំងពេក។ ប្រសិនបើ*

*ជួបបញ្ហា អ្នកត្រូវតែរឹងមាំ និងតស៊ូឡើង។ ពេលអ្នកជួបបញ្ហា កុំគិតថាជីវិតអ្នកចប់ត្រឹមហ្នឹង ហើយមិនអាចកែប្រែបាន។ ជីវិតរបស់យើងគឺនៅវែងជាងនេះទៅទៀត អីចឹងសូមកុំបញ្ឈប់វានៅត្រឹមហ្នឹង ឬបំផ្លាញវាថែមទៀត។ ខ្ញុំតែងតែគិតវិជ្ជមានបែបនេះ។*

## 4.5 កម្រិតនៃការមាក់ងាយ

នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ ជនរួចពីរងគ្រោះបានរៀបរាប់ពីការមាក់ងាយដែលមានកម្រិត និងអាំងតង់ស៊ីតេផ្សេងៗគ្នាដោយផ្អែកយ៉ាងសំខាន់ទៅលើក្រុមអ្នកមាក់ងាយ និងទម្រង់នៃការរើសអើង។ ស្ទើរតែគ្រប់ពេលទាំងអស់ ការមាក់ងាយត្រូវបានរៀបរាប់ក្នុងទម្រង់នៃមាក់ងាយសាធារណៈដ៏ខ្លាំងក្លាមួយទៅលើបុគ្គលម្នាក់។ ឧទាហរណ៍ ជនរួចពីរងគ្រោះម្នាក់ប្រហែលជាអាចនិយាយអំពីការដោះស្រាយជាមួយនឹងការផ្តាច់ខ្លួនពីសង្គម ពីសំណាក់អ្នកជិតខាង ដោយសារតែគេធ្លាប់ធ្វើការនៅក្នុងវិស័យរកស៊ីផ្លូវភេទ។ ខណៈពេលដែលជនរួចពីរងគ្រោះម្នាក់ទៀត ប្រហែលជាអាចនិយាយអំពីការដោះស្រាយជាមួយនឹងការផ្តាច់ខ្លួនពីសង្គម ពីសំណាក់គ្រួសារ និងអ្នកជិតខាង ដោយសារតែគេធ្លាប់ធ្វើការនៅក្នុងវិស័យរកស៊ីផ្លូវភេទ។ នៅក្នុងករណីទាំងអស់នេះ ការមាក់ងាយមានអាំងតង់ស៊ីតេផ្សេងៗគ្នា។ ឧទាហរណ៍មួយទៀតគឺថា មានជនរួចពីរងគ្រោះម្នាក់អាចប្រឈមជាមួយនឹងការរំលោភបំពានដោយពាក្យសម្តី និងអំពើហិង្សាពីសំណាក់ប្តី និងឪពុកម្តាយក្មេករបស់គេ (នៅពេលពួកគេរស់នៅក្នុងផ្ទះជាមួយគ្រួសាររបស់គេ) ដោយសារតែគេធ្លាប់ធ្វើការនៅក្នុងវិស័យរកស៊ីផ្លូវភេទ។ ឧទាហរណ៍ទី៣ គឺការមាក់ងាយមានអាំងតង់ស៊ីតេ និងកម្រិតផ្សេងៗគ្នាសម្រាប់ឧទាហរណ៍ដំបូងទាំងពីរខាងលើ។ ជាទូទៅ លទ្ធផលនៃការសិក្សាប៉ាន់ប្រមាណបង្ហាញថាកម្រិត និងអាំងតង់ស៊ីតេនៃការមាក់ងាយកើនឡើង នៅពេលដែលជនរួចពីរងគ្រោះទទួលរងនូវបទពិសោធន៍រើសអើងច្រើនទម្រង់ផ្សេងៗគ្នា ហើយការរើសអើងនោះនៅតែបន្តកើតឡើងម្តងហើយម្តងទៀតក្នុងរយៈពេលជាច្រើនឆ្នាំ។ អាំងតង់ស៊ីតេ និងកម្រិតនៃការមាក់ងាយនេះក៏អាចក្លាយជាធ្ងន់ធ្ងរទៅៗបានដែរ នៅពេលដែលពួកគេចាប់ផ្តើមមានធនធានកាន់តែតិចទៅៗដូចជា ធនធានសង្គមដែលអាចទុកចិត្តបាន (ឧទាហរណ៍៖ មិត្តភក្តិ ឬសមាជិកគ្រួសារ) និងទីកន្លែងសុវត្ថិភាពនៅក្នុងសហគមន៍ (ឧទារហណ៍៖ សាច់ញាតិ និងផ្ទះអ្នកជិតខាង ឬទីកន្លែងធ្វើការជាដើម)។

ការបូកបញ្ចូលនូវគំនិតបែបមាក់ងាយ និងរើសអើងខ្លួនឯងជាច្រើនទម្រង់ចូលគ្នាក៏បានបញ្ជាក់ឲ្យឃើញពីកម្រិត និងអាំងតង់ស៊ីតេនៃការមាក់ងាយខុសៗគ្នាច្រើនដែរ ក្នុងចំណោមជនរួចពីរងគ្រោះ។ នៅពេលយើងសម្ភាសន៍ជាមួយជនរួចពីរងគ្រោះ ពួកគេខ្លះបានរៀបរាប់អំពីកម្រិតនៃការរើសអើង ដែលកំពុងកើនឡើងដោយមានការរួមបញ្ចូលគ្នាជាមួយគំនិតបែបមាក់ងាយខ្លួនឯង (មើលនៅក្នុងតារាងទី៩ យើងឃើញមាន២១.៧%នៃអ្នកតបសម្ភាសន៍ទាំងអស់)។ ករណីទាំងនេះវាខុសគ្នាពីការដែលមានគំនិតតែមួយទាក់ទងនឹងការមាក់ងាយចំពោះបទពិសោធន៍អតីតកាលនេះ។ ជំនួសមកវិញ ពួកគេនឹងនិយាយតែ

ពីស្ថានភាពនាពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ។ វាសំខាន់ដែលយើងគួរកត់សម្គាល់ថា មិនមែនគ្រប់ជនរួចពីរងគ្រោះដែលកំពុងប្រឈមជាមួយនឹងការមាក់ងាយជាច្រើនទម្រង់ ពួកគេនិយាយរៀបរាប់ប្រាប់យើងពីគំនិតបែបនេះទាំងអស់គ្នានោះទេ។ ហើយវាក៏ដូចគ្នាទៅនឹងជនរួចពីរងគ្រោះ ដែលបានប្រាប់ថាពួកគេគ្មានបទពិសោធន៍ ឬមានបទពិសោធន៍តិចតួចជាមួយនឹងការមាក់ងាយសង្គម មិនមានគំនិតមាក់ងាយខ្លួនឯងនោះដែរ។ ជនរួចពីរងគ្រោះម្នាក់បានរៀបរាប់ពីបទពិសោធន៍ដែលគេមានគំនិតបែបមាក់ងាយ និងរើសអើងខ្លួនឯងក្នុងពេលតែមួយដូចរបៀបខាងក្រោមនេះ៖

⇨ *ខ្ញុំបាក់ទឹកចិត្ត ហើយវាធ្វើឲ្យខ្ញុំឈឺចិត្តណាស់ដោយសារតែសាច់ញាតិរបស់ខ្ញុំមើលងាយខ្ញុំ ព្រោះខ្ញុំធ្លាប់មានទំនាក់ទំនងជាមួយប្រុសៗច្រើននាក់ ហើយថែមទាំងធ្លាប់មានផ្ទៃពោះទៀតផង។ ខ្ញុំធ្លាប់ទម្លាក់កូនចោលច្រើនដងដែរ។ ក្រោយមកខ្ញុំមានប្ដី តែយើងមិនបានរៀបការទេ។ ដូច្នេះហើយបានជាសាច់ញាតិបងប្អូនរបស់ខ្ញុំមើលងាយ និងរើសអើងខ្ញុំ។ គ្រួសារខាងប្ដីខ្ញុំក៏មិនព្រមទទួលយកខ្ញុំដែរ។ វាធ្វើឲ្យខ្ញុំឈឺចិត្ត និងបាក់ចិត្តចំពោះខ្លួនឯងយ៉ាងខ្លាំង។ ខ្ញុំមានអារម្មណ៍ថាខ្ញុំជាមនុស្សគ្មានតម្លៃអីទេ។*

**តារាងទី១៖ ជនរួចពីរងគ្រោះ ដែលបានរៀបរាប់ពីការជួបប្រទះនឹងការមាក់ងាយច្រើនទម្រង់ក្នុងរយៈពេលជាច្រើនឆ្នាំក្នុងចំណោមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់) និងស្ត្រី/ក្មេងស្រី RC (n=27នាក់) ឆ្នាំ២០១១ដល់ឆ្នាំ២០១៤**

| Assessment Groupings | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | Multiple Categories | | Multiple Categories Multiple Years | | Multiple Categories | | Multiple Categories Multiple Years | |
| | n* | % | n* | % | n* | % | n* | % |
| Stigma Categories | 9 | *27.3* | 2 | *6.1* | 14 | *51.9* | 5 | *18.5* |
| Stigmatizing Groups | 7 | *21.2* | 1 | *3.0* | 15 | *55.6* | 6 | *22.2* |
| Discrimination Practices | 9 | *27.3* | 5 | *15.2* | 15 | *55.6* | 9 | *33.3* |
| Self-Stigma and Public Stigma** | 2 | *6.1* | 2 | *6.1* | 5 | *18.5* | 4 | *14.8* |

Notes: RC - (Re-) integrated into Community
P/RC - Shelter Program then (Re-) integrated into Community
Blank - No Observations
* -Number of Individuals
** - Survivors discuss self-stigmatizing thoughts along with multiple forms of public stigma and discrimination

## 4.6 បញ្ហារ៉ាំរ៉ៃនៃការមាក់ងាយក្នុងចំណោមជនរួចពីរងគ្រោះ

មានភស្តុតាងជាច្រើនដែលបញ្ជាក់ថាការមាក់ងាយ គឺជាបញ្ហារ៉ាំរ៉ៃមួយដែលកើតឡើងនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះ។ ការសិក្សាប៉ាន់ប្រមាណនេះបានបង្ហាញពីការមាក់ងាយយ៉ាងទូលំទូលាយមួយ ជាក់ស្ដែងជនរួចពីរងគ្រោះមួយចំនួនបានធ្លាប់ជួបប្រទះវារួចមកហើយ គឺមុនពេលពួកគេត្រូវបានគេជួញដូរ

ទៅទៀត ដូចជាការមាក់ងាយដោយសារភាពក្រីក្រ និងការរើសអើងយេនឌ័រនៅក្នុងសង្គមគ្រួសារជាដើម។ មានករណីជាច្រើន ដែលជនរួចពីរងគ្រោះនៅតែប្រឈមជាមួយនឹងប្រភេទនៃការមាក់ងាយទាំងនេះបន្ថែមពីលើការមាក់ងាយដោយសារពួកគេធ្លាប់មានបទពិសោធន៍ត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។ កថាខណ្ឌខាងក្រោមនេះនឹងបង្ហាញយើងពីកត្តាសំខាន់ៗមួយចំនួនទាក់ទងនឹងការមាក់ងាយ និងបញ្ហាភ្ជាប់របស់វា។

## ការរំលឹកប្រវត្តិអតីតកាលម្តងហើយម្តងទៀត

មានជនរួចពីរងគ្រោះមួយចំនួនបានរៀបរាប់ប្រាប់ថា សមាជិកគ្រួសាររបស់គេពេលខ្លះនៅតែបន្តរំលឹក និងស្តីបន្ទោសពួកគេចំពោះការងារ ដែលពួកគេធ្លាប់ធ្វើការនៅក្នុងវិស័យកម្សាន្តកន្លងមក។ អ្នកខ្លះបានរៀបរាប់បទពិសោធន៍ស្រដៀងគ្នានេះដែរ ដោយសារពួកគេធ្លាប់លែងលះគ្នា។ ការបន្តរំលឹកប្រវត្តិអតីតកាលម្តងហើយម្តងទៀតនេះ វាធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេផងដែរ។ វាបានធ្វើឲ្យអាំងតង់ស៊ីតេនៃការមាក់ងាយកើនឡើងខ្លាំង ហើយពេលខ្លះវាក៏បង្ករឲ្យមានជម្លោះកើតឡើងម្តងទៀត ជាពិសេសចំពោះទំនាក់ទំនងជាមួយនឹងអ្នកជិតខាង និងសមាជិកក្នុងគ្រួសាររួមមានទាំងប្តី ហើយករណីខ្លះឪពុកម្តាយក្មេងជាដើម។ ទម្រង់នៃការរើសអើងសង្គមហាក់ដូចជាដើរតួយ៉ាងសំខាន់ក្នុងការរំលឹកពីប្រវត្តិអតីតកាលរបស់ជនរួចពីរងគ្រោះម្តងហើយម្តងទៀត ហើយពេលខ្លះវាមានទម្រង់លក្ខណៈហាក់ដូចជាខ្លាំងជាងនេះដែរ (ឧទាហរណ៍ដូចជា អ្នកដែលមានប្រវត្តិមិនល្អ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងពិធីមួយចំនួនក្នុងពិធីមង្គលការជាដើម)។ ជនរួចពីរងគ្រោះបាននិយាយពីបទពិសោធន៍ ដែលត្រូវបានគេរំលឹកពីប្រវត្តិអតីតកាលរបស់ពួកគេ៖

- *ក្នុងឆ្នាំ២០១២-ក្រុមគ្រួសារខ្ញុំ ឈប់មើលងាយខ្ញុំខ្លាំង ដូចពួកគេធ្លាប់ធ្វើដាក់ខ្ញុំកាលពីមុនទៀតហើយ គ្រាន់តែពេលខ្លះពួកគេរំលឹកប្រវត្តិមិនល្អរបស់ខ្ញុំនៅពេលបងស្រីខ្ញុំស្តីបន្ទោសឲ្យខ្ញុំចំពោះការដើរលេងយប់...វាធ្វើឲ្យខ្ញុំឈឺចិត្ត។ ប៉ុន្តែក្នុងចិត្តរបស់ខ្ញុំ ខ្ញុំខ្លាចបងថ្លៃប្រុសមើលងាយខ្ញុំណាស់...ទោះបីជាដល់ពេលឥលូវនេះ...គាត់នៅតែស្តីបន្ទោសឲ្យខ្ញុំ និងមើល ងាយខ្ញុំស្ទើរតែគ្រប់ពេលវេលា។ គ្រប់ពេលគាត់ឈ្លោះគ្នាជាមួយបងស្រីខ្ញុំ គាត់បែរជាមកស្តីបន្ទោសឲ្យខ្ញុំ ដែលធ្លាប់ធ្វើជាស្រីខូច ហើយថែមទាំងហៅគ្រួសារខ្ញុំថាជា "គ្រួសារស្រីខូច"។*

  *ឆ្នាំ២០១៤-ព្រោះពេលយើងឈ្លោះគ្នា ប្តីខ្ញុំតែងតែស្តីបន្ទោសឲ្យខ្ញុំ ហើយគាត់រំលឹករឿងចាស់ (ប្រវត្តិអាក្រក់) ពីគ្រួសារខ្ញុំ ប៉ុន្តែគាត់មិនដែលនិយាយអ្វីពីប្រវត្តិរបស់ខ្ញុំដែលធ្លាប់មានប្តីមុននោះទេ។*

⇨ *ឆ្នាំ២០១២ត្រីមាសទី១-ខ្ញុំមានអារម្មណ៍ថាបងប្អូនជីដូនមួយរបស់ខ្ញុំរើសអើងខ្ញុំ ព្រោះនាងប្រាប់មិនឲ្យកូននាងមកលេង និងមានទំនាក់ទំនងជាមួយខ្ញុំ។ ពេលខ្លះគាត់ជេរថាឲ្យខ្ញុំដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាឈឺចិត្តណាស់។*

*ឆ្នាំ២០១២ត្រីមាសទី១-ក្នុងរយៈពេល៤ខែនេះ ខ្ញុំគិតថាបងប្អូនជីដូនមួយខ្ញុំរើសអើងខ្ញុំ ព្រោះអីគាត់មិននិយាយជាមួយខ្ញុំទេ។ គាត់ស្អប់ខ្ញុំ ហើយមិនដែលត្រូវគ្នាជាមួយខ្ញុំទេ។ ជាញឹកញាប់គាត់ឧស្សាហ៍និយាយខឹងដងដាក់ខ្ញុំណាស់ (និយាយពីប្រវត្តិដែលខ្ញុំធ្លាប់ធ្វើការនៅកន្លែងកម្សាន្ត)។ វាធ្វើឲ្យខ្ញុំឈឺចិត្តណាស់។*

## ការមាក់ងាយទាក់ទងនឹងលទ្ធភាពអាពាហ៍ពិពាហ៍

ដោយយោងទៅតាមការរៀបរាប់របស់ជនរួចពីរងគ្រោះ យើងបានរកឃើញថាជនរួចពីរងគ្រោះស្ទើរតែទាំងអស់គឺបានជ្រាបដឹងពីការមាក់ងាយយ៉ាងច្រើនទាក់ទងទៅនឹង "លទ្ធភាព" អាចរៀបការ អាចលែងលះ ឬក៏សម្រាប់អ្នកខ្លះ ទាក់ទងនឹងការរៀបការម្តងទៀតដែរ។ ចំនុចនេះគឺត្រូវបានរំពឹងទុកថាសង្គមកម្ពុជានឹងឲ្យតម្លៃ និងផ្តល់កិត្តិយស ប្រសិនបើយើងបានបញ្ចូលវាទៅក្នុងស្ថាប័នស្របច្បាប់នៃអាពាហ៍-ពិពាហ៍។ ភាគច្រើន តែមិនមែនទាំងអស់នោះទេ ក្នុងចំណោមជនរួចពីរងគ្រោះដែលនៅលីវ បាននិយាយរៀបរាប់ពីការប្រឈមតតាំងជាមួយនឹងការមាក់ងាយ ទាក់ទងនឹងលទ្ធភាពនៃការរៀបការនៅពេលខ្លះ នៅក្នុងអំឡុងពេលនៃការសិក្សាប៉ាន់ប្រមាណនេះ។ ជនរួចពីរងគ្រោះដែលមានទំនាក់ទំនងពោរពេញដោយអំពើហិង្សា និងការរំលោភបំពាន មានការប្រឈមជាមួយនឹងការមាក់ងាយទាក់ទងនឹងបញ្ហាយេនឌ័រ ក៏ដូចជាការមាក់ងាយបែបវប្បធម៌ប្រពៃណី ទាក់ទងនឹងជម្រើសក្នុងការសម្រេចចិត្តផ្សេងៗដូចជាការសម្រេចចិត្តលែងលះ ជាដើម។ វាខុសគ្នាពីវប្បធម៌របស់ពួកអឺរ៉ុបខាងលិច។ ការលែងលះគឺជាចំនុច ដែលត្រូវបានគេមាក់ងាយយ៉ាងខ្លាំងចំពោះស្ត្រីនៅក្នុងប្រទេសកម្ពុជា ដែលពួកសម្រេចចិត្តយ៉ាងលំបាក្នុងការជ្រើសរើសយកការលែងលះ (Van Der Keur 2014)។ ដោយសារតែការសម្រេចចិត្តបែកគ្នាជាមួយដៃគូ ដែលប្រើអំពើហិង្សាអាចបង្កឲ្យមានការមាក់ងាយ ដូច្នេះហើយ ប្រជាជនខ្មែរភាគច្រើន (ស្មើនឹង៧៥%) បានជឿជាក់ថា ប្រពន្ធគួរតែចេះអត់ធ្មត់ និងស៊ូទ្រាំនឹងអំពើហិង្សាក្នុងគ្រួសារ (ឧទាហរណ៍៖ រក្សាភាពស្ងៀមស្ងាត់ មិននិយាយចេញទៅក្រៅ) ដើម្បីរក្សាក្រុមគ្រួសាររបស់គេឲ្យអាចរស់នៅជុំគ្នាបាន(Van Der Keur 2014)។ បច្ចុប្បន្នជនរួចពី រងគ្រោះមួយចំនួនកំពុងប្រឈមនឹងការមាក់ងាយច្រើនទម្រង់ នៅពេលដែលការមាក់ងាយនោះវិវឌ្ឍន៍ពីការទំនាក់ទំនងមិនល្អជាមួយប្តី (រំលោភបំពាន) ទៅជាការលែងលះ ឬរស់នៅបែកគ្នា ហើយបន្ទាប់មកទៀតទៅរៀបការដៃគូថ្មីម្តងទៀត ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍នោះនៅតែមានការរំលោភបំពានដដែល (មើលការពន្យល់នៅក្នុងក្រាហ្វិកទី១)។ ជនរួចពីរងគ្រោះមួយចំនួនបានរៀបរាប់ពីការប្រឈម និងក្តីបារម្ភរបស់ពួកគេចំពោះវិសមភាពយេនឌ័រ ការមាក់ងាយក្នុងអាពាហ៍ពិពាហ៍ និងការលែងលះដូចខាងក្រោម៖

⇨ *គាត់និយាយដើមខ្ញុំ។ អ្នកភូមិអាណិតខ្ញុំណាស់ដែលខ្ញុំអភ័ព្វ ហើយពួកគេប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំមិនរៀបការជាមួយបុរសនេះទេ (បុរសពិការ)។ ប្រហែលគ្មានបុរសណាផ្សេងមកសុំខ្ញុំរៀបការទៀតទេ។*

⇨ *ប្តីប្រពន្ធត្រូវតែផ្តល់តម្លៃឲ្យគ្នាទៅវិញទៅមក។ អ្នកជាប្តីរបស់ខ្ញុំ ប៉ុន្តែអ្នកមិនដែលផ្តល់តម្លៃឲ្យខ្ញុំទុកដូចជាប្រពន្ធទេ។ ខ្ញុំនិយាយប្រាប់គាត់អញ្ចឹង។*

⇨ *ខ្ញុំគិតថា ខ្ញុំលែងមានតម្លៃទៀតហើយ។ ខ្ញុំឈប់ខ្វល់ពីរាងកាយខ្ញុំទៀតហើយ។ ប្តីខ្ញុំគាត់អាចមានស្រីក្រៅច្រើនបាន។ អញ្ចឹងខ្ញុំក៏អាចមានមិត្តប្រុសច្រើនបានដែរ។ (ជនរួចពីរងគ្រោះនេះទើបតែបានលែងលះជាមួយប្តីនាង ហើយនាងសម្រេចចិត្តចាប់ផ្តើមទៅធ្វើការនៅក្នុងហាងខារ៉ាអូខេ)។*

## ក្រាហ្វិកទី1៖ វដ្តនៃការមាក់ងាយទាក់ទងនឹងលទ្ធភាពអាពាហ៍ពិពាហ៍




ជនរួចពីរងគ្រោះបានពិព័ណ៌នាពីករណីមួយចំនួន ដែលការមាក់ងាយពី "លទ្ធភាពអាពាហ៍ពិពាហ៍" ជះឥទ្ធិពលដល់ការគិត និងការសម្រេចចិត្តរបស់ពួកគេស្តីពីការបង្កើតទំនាក់ទំនង។ កម្រិតក្នុងការកំណត់ថាជនរួចពីរងគ្រោះមានការប្រែប្រួលនូវឥរិយាបថជាមនសិការ និងគ្មានមនសិការក្នុងការស្វែងរកបង្កើតទំនាក់ទំនងនេះគឺវាហួសពីទំហំនៃការសិក្សាប៉ាន់ប្រមាណនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្តី វាបានបញ្ជាក់យ៉ាងច្បាស់ថា ជនរួចពីរងគ្រោះបានគិតថាពួកគេមានឱកាសតិចតួចប៉ុណ្ណោះក្នុងការបង្កើតទំនាក់ទំនង ហើយពេលខ្លះពួកគេក៏បានបដិសេធចំពោះការបង្កើតទំនាក់ទំនងទៀតផង ព្រោះដោយសារតែពួកគេខ្លាចទទួលរងនូវការមាក់ងាយ ដោយសារតែប្រវត្តិពីអតីតកាលរបស់ពួកគេ។

- ⇨ *ខ្ញុំបានស្គាល់បុរសម្នាក់។ គាត់មកពីគ្រួសារអ្នកមានដែរ។ គាត់ស្រលាញ់ខ្ញុំ ហើយគាត់ចង់នាំខ្ញុំឲ្យជួបជាមួយឪពុកម្តាយគាត់ ប៉ុន្តែខ្ញុំបានបដិសេធជាមួយគាត់ព្រោះខ្ញុំខ្លាចគ្រួសារគាត់មើលងាយខ្ញុំដោយសារតែខ្ញុំមានប្រវត្តិមិនល្អ។*
- ⇨ *អ្នកដឹងទេ មានបុរសក្មេងម្នាក់បានមកជួបខ្ញុំ ហើយសុំខ្ញុំរៀបការ។ ប៉ុន្តែខ្ញុំមិនអាចធ្វើអញ្ចឹងបានទេព្រោះខ្ញុំមានផ្ទុកមេរោគអេដស៍។ ខ្ញុំខ្លាចខ្ញុំបំផ្លាញអនាគតរបស់គាត់។*

ជនរួចពីរងគ្រោះមួយចំនួនក៏បាននិយាយពីការចាប់ផ្តើមទំនាក់ទំនងដៃគូជាមួយបុរស ដែលពួកគេបានជួបដោយចៃដន្យ ដោយគ្រាន់តែចំណាយពេលវេលាតិចតួចបំផុតក្នុងការស្គាល់គ្នា ដើម្បីស្វែងយល់ពីអនាគតប្តីរបស់ពួកគេ។ ជនរួចពីរងគ្រោះម្នាក់បានចាប់ផ្តើមទំនាក់ទំនងជាមួយបុរសម្នាក់ បន្ទាប់ពីនាងបានចាប់អារម្មណ៍បុរសនោះតាមផ្លូវនៅពេលនាងចេញមកដើរលេងខាងក្រៅមណ្ឌលស្នាក់នៅ។ ម្នាក់ទៀតបានចាប់ផ្តើមទំនាក់ទំនងជាមួយបុរសម្នាក់ ដែលនាងទូរសព្ទច្រឡំលេខនៅពេលនាងកំពុងស្រវឹងស្រា។ ឯម្នាក់ទៀតវិញ បានសម្រេចចិត្តចាប់ផ្តើមទំនាក់ទំនងជាមួយបុរសម្នាក់ដែលនាងស្គាល់នៅពេលនាងកំពុងស្នាក់នៅជាមួយអ្នកដទៃ បើទោះបីជានាងត្រូវគេធ្វើបាបរាងកាយ និងរហូតដល់មានផ្ទៃពោះជាមួយគ្នាក៏ដោយ។ ជាលទ្ធផល ជនរួចពីរងគ្រោះទាំងអស់នោះពីមួយថ្ងៃទៅមួយថ្ងៃ ជីវិតអាពាហ៍ពិពាហ៍/ជីវិតគូរបស់ពួកគេពោរពេញដោយការរំលោភបំពានទាំងផ្លូវកាយ និងរំលោភបំពានដោយពាក្យសម្តី។ ទោះបីជាការមាក់ងាយដែលបានកើតឡើងតាមរយៈការសម្រេចចិត្ត មិនត្រូវបានគេមើលឃើញច្រើនយ៉ាងណាក៏ដោយ សាច់រឿងបានបង្ហាញពីការលំបាកដែលជនរួចពីរងគ្រោះមួយចំនួនជួបប្រទះបន្ទាប់ពីធ្វើសមាហរណកម្មក្នុងការស្វែងរក/បង្កើតទំនាក់ទំនងដៃគូដែលចេះគាំទ្រ និងលើកទឹកចិត្តគ្នាទៅវិញទៅមក។

## ការបាត់បង់ឱកាសទទួលបានការអប់រំ

ស្ត្រីរួចពីរងគ្រោះនៅក្នុងការសិក្សាប៉ាន់ប្រមាណមានការលំបាកក្នុងការរៀនឲ្យបានចប់។ តាមឯកសារយោងបានកត់ត្រាថា មានឧបសគ្គជាច្រើន ដែលសិស្សស្រីមានការលំបាកក្នុងបញ្ចប់ការសិក្សានៅក្នុងប្រទេសកម្ពុជា។ ឧបសគ្គទាំងនោះមានដូចជា ភាពក្រីក្រ ផ្ទះឆ្ងាយពីសាលារៀន និងការព្រួយបារម្ភពីសុវត្ថិភាពសម្រាប់សិស្សស្រី ការលំអៀងនៃយេនឌ័រនៅក្នុងគ្រួសារ និងជម្លោះក្នុងគ្រួសារជាដើម។ ជនរួចពីរងគ្រោះបានជួបប្រទះនូវឧបសគ្គទាំងអស់នេះព្រមគ្នាជាមួយនឹងបញ្ហាផ្សេងៗទៀត។ ជនរួចពីរងគ្រោះខ្លះបាននិយាយអំពីការបាត់បង់ឱកាសដោយសារត្រូវបានគេជួញដូរយូរពេក ពិបាករៀនឡើងវិញ ហើយអ្នកខ្លះទៀតត្រូវបោះបង់ការសិក្សាដោយសារការមាក់ងាយសង្គម ពីសំណាក់សិស្សរួមថ្នាក់ថាឲ្យពួកគេថា "ចាស់ហើយនៅមករៀនថ្នាក់កម្រិងនេះទៀត" (Miles and Miles 2011)។ នៅក្នុងឆ្នាំ២០១៤ ជនរួចពីរងគ្រោះនៅក្នុងការសិក្សាមិនមាននរណាម្នាក់បានរៀនចប់ថ្នាក់ទី១២ និងប្រលងជាប់ថ្នាក់បាក់-

ឧបទេ។ ក្នុងចំណោមជនរួចពីរងគ្រោះនៅក្នុងការសិក្សាមាន៨៥%បានបោះបង់ការសិក្សា។ ជនរួចពីរងគ្រោះភាគច្រើនក្នុងចំណោមក្រុមស្ត្រី/ក្មេងស្រី SP/RC បានចូលរៀនខណៈពួកគេបានចូលមកស្នាក់នៅក្នុងមណ្ឌល (ស្មើនឹង២៣នាក់ក្នុងណោម៣៣នាក់)។ បន្ទាប់ពីពួកគេបានធ្វើសមាហរណកម្ម មាន៦១% នៃក្រុមស្ត្រី/ក្មេងស្រីនេះ បានបោះបង់ការសិក្សា (ស្មើនឹង១៤នាក់ក្នុងចំណោម២៣នាក់) ទោះបីជាថវិការសម្រាប់ការសិក្សាស្ទើរតែទាំងអស់បានមកពីការផ្គត់ផ្គង់របស់កម្មវិធីថៃទាំជំនួសក៏ដោយ។

យោងតាមចំនួនឧបសគ្គ ដែលស្ត្រី/ក្មេងស្រីរួចពីរងគ្រោះជួបប្រទះ និងទិសដៅដែលជនរួចពីរងគ្រោះភាគច្រើនជ្រើសរើសយកបន្ទាប់ពីធ្វើសមាហរណកម្ម យើងមើលទៅហាក់ដូចជាមានចំនួនតិចតួចប៉ុណ្ណោះ ដែលពួកគេមានបំណងរៀនបន្តដើម្បីបញ្ចប់ការសិក្សារបស់ពួកគេ។ លទ្ធផលនៃការសិក្សានេះបញ្ជាក់ឲ្យឃើញថា ជនរួចពីរងគ្រោះស្ទើរតែទាំងអស់នឹងនៅតែបន្តជួបនូវការមាក់ងាយដោយសារខ្វះចំណេះដឹងដដែល (ឧទាហរណ៍ វិសមភាពយេនឌ័រក្នុងជីវិតអាពាហ៍ពិពាហ៍ ស្ថានភាពសេដ្ឋកិច្ចសង្គមជាដើម)។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារបានជួយជនរួចពីរងគ្រោះយ៉ាងច្រើនឲ្យពួកគេបានរៀនពីជំនាញការងារដែលមានតម្លៃ និងអាចស្វែងរកការងារបានធ្វើ ប៉ុន្តែនៅពេលខ្លះជំនាញទាំងនេះមិនអាចជួយស្ត្រី/ក្មេងស្រី ដែលបានបញ្ចប់ការសិក្សារបស់ពួកគេឲ្យទទួលបានកិត្តិយសមកវិញទេ។ ចូរពិចារណាពីសាច់រឿងមួយដែលស្ត្រីរួចពីរងគ្រោះម្នាក់បានរៀបរាប់ប្រាប់។ គាត់ជាស្ត្រីដែលមានការៀនសូត្របានតិចតួច ហើយមានការងារនៅកន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯប្តីរបស់គាត់ជាអ្នកដែលបានរៀនចប់មហាវិទ្យាល័យ ហើយសព្វថ្ងៃធ្វើការជាប្រធានផ្នែកមន្ត្រីឥណទាននៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយកន្លែង៖

- ⇨ *ពេលខ្លះខ្ញុំបានសួរគាត់ តើគាត់គិតចំពោះខ្ញុំយ៉ាងម៉េចដែរ ឬគាត់មានចាត់ទុកខ្ញុំជាអ្វីទេ? ខ្ញុំបានសួរគាត់ តើគាត់គិតថាខ្ញុំជាមនុស្សអត់ចិត្ត គ្មានគំនិត គ្មានខួរក្បាល និងជាមនុស្សដែលអាចទទួលគ្រប់យ៉ាងដែលគាត់ធ្វើមកលើខ្ញុំមែនទេ? តើសព្វថ្ងៃនេះគាត់មានយល់ពីអារម្មណ៍ខ្ញុំដែរឬទេ? ខ្ញុំសួរគាត់ តើគាត់មានដឹងទេថាខ្ញុំឈឺយ៉ាងម៉េច ហើយកូនប្រុសយើងឈឺយ៉ាងម៉េចដែរ? តើគាត់មានដឹងពីការរស់នៅរបស់យើងដែរទេ? ប្តីខ្ញុំអត់មានឆ្លើយតបអ្វីសោះ។ តែបន្ទាប់មកគាត់ឆ្លើយទាំងគំរោះគំរើយដាក់ខ្ញុំថា "អញអត់មានខួរក្បាលទេ! អញ្ចឹង អញអត់ដឹងអីទាំងអស់" ។ គាត់និយាយអញ្ចឹង ហើយគាត់ប្រាប់ខ្ញុំឲ្យឈប់និយាយជាមួយគាត់ ព្រោះខ្ញុំគ្មានខួរក្បាល ខ្ញុំដូចជាសត្វឆ្កែ ហើយខ្ញុំអត់ចេះគិតគូរអីទេ។*

## អាពាហ៍ពិពាហ៍ស្របច្បាប់

ជនរួចពីរងគ្រោះភាគច្រើន ដែលមានទំនាក់ទំនងជាមួយប្តី/ដៃគូ បានសម្រេចចិត្តមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមផ្លូវច្បាប់នៅក្នុងច្បាប់សង្គមស៊ីវិលទេ។ ចំនុចនេះជានិន្នាការរំខានមួយក្នុង

ចំណោមជនរួចពីរងគ្រោះនៅក្នុងការសិក្សានេះ។ យើងឃើញមានតែម្នាក់ប៉ុណ្ណោះក្នុងចំណោមអ្នកតបសម្ភាសន៍៣៦នាក់ជាអ្នកមានប្ដី/ដៃគូ បានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់។ កត្តាមួយចំនួនដែលជនរួចពីរងគ្រោះប្រាប់ថា វាជាមូលហេតុដែលពួកគេមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍។ មូលហេតុទាំងនេះរួមមានដូចជា ការចំណាយពេលវេលា និង/ឬផ្ទះឆ្ងាយពីកន្លែងចុះសំបុត្រអាពាហ៍ពិពាហ៍ ប្ដី ឬក៏នាងខ្លួនឯងបដិសេធមិនទៅចុះ កង្វះចំណេះដឹងទាក់ទងនឹងដំណើរការនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ កង្វះចំណេះដឹងទាក់ទងនឹងសារៈសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងតម្លៃក្នុងការរំលាយសំបុត្រអាពាហ៍ពិពាហ៍ថ្លៃនៅពេលលែងលះជាដើម។

ខណៈពេលជនរួចពីរងគ្រោះបានបញ្ជាក់ហេតុផលជាច្រើន ចំពោះការមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍របស់ពួកគេ បញ្ហាសំខាន់ក៏បានលេចឡើងក្នុងលក្ខណៈជាប្រព័ន្ធទាក់ទងនឹងការមាក់ងាយជុំវិញបញ្ហាការលែងលះ។ Van Der Keur (2014) បង្ហាញពីប្រភេទនៃការរើសអើងជាច្រើនចំពោះស្ត្រី ដែលពួកគេនឹងប្រឈមនៅពេលមានដំណើរការសុំការលែងលះនៅក្នុងប្រព័ន្ធយុត្តិធម៌សង្គមស៊ីវិល។ បញ្ហាចម្បងៗទាំងបីរួមមាន៖

- គូស្វាមីភរិយា ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវតែទៅសុំលិខិតរំលាយអាពាហ៍ពិពាហ៍ស្របច្បាប់ ដើម្បីឲ្យពួកគេអាចបង្កើតចំណងអាពាហ៍ពិពាហ៍មួយទៀតស្របជាមួយនឹងនិទណ្ឌភាពនៃច្បាប់
- ច្បាប់ស្ដីពីការលែងលះបានឆ្លុះបញ្ចាំងពីវប្បធម៌សង្គមកម្ពុជា និងជាការមាក់ងាយលើការលែងលះគ្នាដែលធ្វើឲ្យមានដំណាក់កាល និងឧបសគ្គជាច្រើនក្នុងការទទួលបានការវិនិច្ឆ័យកាត់ក្ដីឲ្យលែងលះគ្នា។ ដំណាក់កាល និងឧបសគ្គទាំងនេះ គឺទាមទារឲ្យមានការចំណាយប្រាក់ជាច្រើនសម្រាប់គូស្វាមីភរិយា ដែលមានប្រាក់ចំណូលទាបជាង
- បុរសមានអំណាចគ្របដណ្ដប់ច្រើននៅក្នុងប្រព័ន្ធយុត្តិធម៌សង្គមស៊ីវិល (ក្រុមប្រឹក្សាឃុំ/សង្កាត់មាន ៨២% ជាបុរស និង ៩១.៥% នៃចៅក្រមគឺជាបុរស)

ច្បាប់អាពាហ៍ពិពាហ៍នៅប្រទេសកម្ពុជាមិនបានចែងពី *"សិទ្ធិ និងកាតព្វកិច្ចរបស់ប្ដីប្រពន្ធណាមួយដែលបរាជ័យ ឬមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់នៅក្នុងបញ្ជីអត្រានុកូលដ្ឋានសង្គមស៊ីវិលឡើយ"* (Van Der Keur 2014; p. 2) ។ ស្ត្រី/ប្រពន្ធដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ គឺមិនត្រូវបានធានាពីសិទ្ធិរបស់ពួកគេទៅលើសិទ្ធិទទួលបានទ្រព្យសម្បត្តិគ្រួសារ ទ្រព្យសម្បត្តិរកបាននៅក្នុងចំណងអាពាហ៍ពិពាហ៍ ហើយបានចុះឈ្មោះដោយដាក់ឈ្មោះរបស់គាត់ ឬឈ្មោះដៃគូ សោធន-អាហារកិច្ចដៃគូ និងការផ្គត់ផ្គង់កូនជាដើម។ ពួកគេនឹងមិនមានសិទ្ធិអំណាចអ្វីទាំងអស់ក្នុងការចរចាដោយមិនមានភាពភ័យខ្លាចចំពោះអំពើហិង្សា ផលវិបាកផ្នែកហិរញ្ញវត្ថុ ការបោះបង់ចោល និងការបង្ខំឲ្យ

ចាកចេញ នៅពេលណាមានជម្លោះ ឬការមាក់ងាយដោយសារវិសមភាពយេនឌ័រណាមួយកើតឡើងក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេនោះទេ។ ជាឧទាហរណ៍ ចូរគិតពិចារណាពីសាច់រឿងដែលបានលើកឡើងខាងលើ (ផ្នែកខាងលើក្នុងទំព័រទី៣២) ដែលស្ត្រីរួចពីរងគ្រោះបានជជែកវែកញែកពីជម្រើសដែលអាចមាន និងការពិភាក្សាជាមួយប្ដីរបស់នាង។ ពួកគេទាំងពីរមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ទេ ហើយនាងក៏មិនបានទទួលសិទ្ធិអ្វីក្នុងការទទួលទ្រព្យសម្បត្តិក្នុងចំណងអាពាហ៍ពិពាហ៍ ក៏ដូចគ្នានឹងសិទ្ធិទទួលបានការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុសម្រាប់នាង ឬសម្រាប់កូនរបស់នាងដែរ ប្រសិនបើប្ដីរបស់នាងសម្រេចចិត្តបោះបង់ចោលទំនាក់ទំនងជាមួយនឹងនាង។ បើសិនជាអញ្ចឹងមែន មានជនរួចពីរងគ្រោះជាច្រើននាក់ ដែលប្រហែលជានឹងប្រឈមនឹងបញ្ហាការមាក់ងាយពាំវ៉ៃទាក់ទងទៅនឹងវិសមភាព-យេនឌ័រ និងការលែងលះនេះដែរ។

## ស្ថានភាពសុខភាព

ការលាក់ប្រវត្តិពីអតីតកាល អាចជាសម្ពាធខាងសតិអារម្មណ៍ និងរាងកាយមួយយ៉ាងសំខាន់ដែលគួរឲ្យកត់សម្គាល់។ ជនរួចពីរងគ្រោះមួយចំនួននិយាយពីក្ដីបារម្ភខ្លាចថា ប្រសិនបើមាននរណាអាចដឹងពីប្រវត្តិរបស់ពួកគេ ឬថាមិត្តភក្តិ ឬក្រុមគ្រួសាររបស់គេសម្រេចចិត្តចូលទៅមើលនៅក្នុងប្រព័ន្ធអ៊ីធើណែតរកព័ត៌មានទាក់ទងនឹងអង្គការដែលគេធ្លាប់ស្នាក់នៅ ឬកន្លែងដែលគេកំពុងធ្វើការសព្វថ្ងៃ។ ឧទាហរណ៍ខាងក្រោមបង្ហាញពីជនរួចពីរងគ្រោះម្នាក់ ពិព័ណ៌នាចំពោះការរលឹកដឹងពីការមាក់ងាយ ដែលវាជះឥទ្ធិពលទៅលើបញ្ហាសុខភាព ដែលបណ្ដាលមកពីភាពតានតឹងដោយសារការប្រឈមនឹងការមាក់-ងាយ។ នាងទើបបានរៀបការហើយថ្មីៗ ហើយនាងបាននិយាយប្រាប់ថា បន្ទាប់ពីនាងបានរៀបការហើយ បញ្ហាការមាក់ងាយពីក្រុមគ្រួសារហាក់ដូចជាមានការថយចុះ ប៉ុន្តែជំនួសមកវិញ នូវភាពភ័យខ្លាចចំពោះឳពុកម្ដាយក្មេករបស់នាងបានកើនឡើង។ នាងខ្លាចប្រសិនបើថ្ងៃណាមួយពួកគេបានដឹងពីប្រវត្តិអតីតកាលរបស់នាង។ ប្ដីរបស់នាងដឹងពីប្រវត្តិរបស់នាង ប៉ុន្តែនាងមិនសូវទុកចិត្តចំពោះប្ដីនាងទាំងស្រុងនោះទេ។ នាងបាននិយាយថាភាពតានតឹងនេះ គឺជាក្ដីព្រួយបារម្ភមួយធំជាងគេបំផុតនៅក្នុងជីវិតរបស់នាង៖

- ⇨ *អ្វីដែលខ្ញុំគិតខ្លាំងជាងគេបំផុតនោះគឺជាបញ្ហាមួយនេះ។ ខ្ញុំគិតវាច្រើនមែនទែន។ ខ្ញុំអត់ដឹងថានឹងត្រូវធ្វើយ៉ាងម៉េចទេ ប្រសិនបើម្ដាយឪពុកក្មេកខ្ញុំដឹងពីប្រវត្តិរបស់ខ្ញុំ។*
  *(នៅពេលអ្នកស្រាវជ្រាវសួរគាត់ថា តើវាជះឥទ្ធិផលដល់សុខភាពគាត់ដែរទេ? គាត់ឆ្លើយថា) ចាស! ជះឥទ្ធិពល។ ខ្ញុំតែងមិនសូវលក់ ញ៉ាំមិនសូវបាន និងមានអារម្មណ៍ថាល្វើយអស់កម្លាំង ដូចដែលបងបានឃើញខ្ញុំឥលូវនេះអីចឹង។*

ស្ថានភាពនៃការមាក់ងាយ និងការរើសអើងអាចមានការផ្លាស់ប្តូរយ៉ាងលឿន ប៉ុន្តែផលប៉ះពាល់នៃការមាក់ងាយលើបញ្ហាសុខភាពផ្លូវចិត្ត និងសុខភាពរាងកាយអាចនឹងមិនឆ្លើយតបនៅក្នុងលក្ខណៈដូចគ្នានោះទេ។ ការសិក្សាប៉ាន់ប្រមាណនេះបានបញ្ជាក់ឲ្យឃើញថាជនរួចពីរងគ្រោះបានប្រឈមជាមួយនឹងបញ្ហានៃការមាក់ងាយដែលមានកម្រិត និងរាំងតង់ស៊ីតេផ្សេងៗគ្នា។ ហើយនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ យើងក៏មិនដឹងច្បាស់ដែរ ថាតើការមាក់ងាយ វាបានជះឥទ្ធិពលទៅនឹងបញ្ហាសុខភាពផ្លូវចិត្ត និងសុខភាពរាងកាយរបស់ជនរួចពីរងគ្រោះដល់កម្រិតណានោះទេ។ ការសិក្សាស្រាវជ្រាវនាពេលអនាគត គួរតែធ្វើការសិក្សាលើបញ្ហានេះបន្ថែមទៀត ដើម្បីជាប្រយោជន៍ដល់ប្រធានកម្មវិធីក្នុងការរៀបចំគម្រោងសម្រាប់ការតាមដានទៅលើជីវិតរបស់ជនរួចពីរងគ្រោះ និងប៉ាន់ប្រមាណពីតម្រូវការ និងសេវាថែទាំសំខាន់ៗមួយចំនួនដល់ពួកគេ។

## 4.7 វិធីសាស្ត្រដោះស្រាយសម្រាប់ការមាក់ងាយ

ជនរួចពីរងគ្រោះភាគច្រើនបានរៀបរាប់ពីវិធីសាស្ត្រ ឬយន្តការដោះស្រាយជាមួយនឹងការប្រឈមនឹងបញ្ហាការមាក់ងាយ និងការរើសអើងយ៉ាងហោចណាស់មួយ (មើលតារាងទី១០)។ ជនរួចពីរងគ្រោះដែលបាននិយាយពីយន្តការដោះស្រាយបញ្ហាមាក់ងាយមាន៧៥.៨% សម្រាប់ក្រុមស្ត្រី/ក្មេងស្រី SP/RC និង៧៧.៨% សម្រាប់ក្រុមស្ត្រី/ក្មេងស្រី RC តាមលំដាប់រៀងគ្នា។ ចំពោះចំនួនរាប់សរុបរវាងក្រុមស្ត្រីទាំងពីរនេះក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ។ "ការលាក់ប្រវត្តិពីអតីតកាល" គឺជាវិធីសាស្ត្រដែលត្រូវបាននិយាយលើកឡើងញឹកញាប់ជាងគេបំផុត មាន១៣នាក់ពីក្រុមស្ត្រី/ក្មេងស្រី SP/RC និង៨នាក់ពីក្រុមស្ត្រី/ក្មេងស្រី RC។

**តារាងទី10៖ អត្រាប្រេវ៉ាឡង់នៃយន្តការដោះស្រាយបញ្ហាការមាក់ងាយ និងការរើសអើងដែលបានរៀបរាប់ដោយក្រុមស្ត្រី/ក្មេងស្រី SP/RC (n=33នាក់ និងស្ត្រី/ក្មេងស្រីRC (n=27នាក់) ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤**

| Survivors strategies for coping with stigma and discrimination: | Female SP/RC | | | | Female RC | | | |
|---|---|---|---|---|---|---|---|---|
| | n* | % | Total Count | Ind. w/ Multiple Years | n* | % | Total Count | Ind. w/ Multiple Years |
| Keep the past a secret | 13 | *39.4* | 14 | 1 | 8 | *29.6* | 13 | 4 |
| Patience and endure | 7 | *21.2* | 7 | | 6 | *22.2* | 9 | 2 |
| Careful and confident | 3 | *9.1* | 3 | | 5 | *18.5* | 7 | 2 |
| Anger / Fighting | 4 | *12.1* | 7 | 2 | 5 | *18.5* | 8 | 2 |
| Share about past with spouse/partner | 6 | *18.2* | 6 | | 4 | *14.8* | 4 | |
| Use alcohol/drugs | 3 | *9.1* | 4 | 1 | 4 | *14.8* | 8 | 3 |
| "Be strong" | 4 | *12.1* | 4 | | 4 | *14.8* | 4 | |
| Stop work in the sex industry and move on | 0 | *0* | 0 | | 4 | *14.8* | 4 | |
| Religious faith | 4 | *12.1* | 4 | | 3 | *11.1* | 3 | |
| Move away (another home) | 4 | *12.1* | 5 | 1 | 2 | *7.4* | 2 | |
| Share with trusted family member / friend | 2 | *6.1* | 3 | 1 | 2 | *7.4* | 2 | |
| Develop no close relationships | 0 | *0* | 0 | | 2 | *7.4* | 2 | |
| Get married or go back to previous partner | 1 | *3.0* | 1 | | 1 | *3.7* | 1 | |
| Spend and buy things / pretend happy | 2 | *6.1* | 2 | | 1 | *3.7* | 1 | |
| Suicidal thoughts / Self-harm | 0 | *0* | 0 | | 1 | *3.7* | 1 | |
| Polite and respectful - "dutiful" | 0 | *0* | 0 | | 1 | *3.7* | 1 | |
| Quit school or job | 2 | *6.1* | 2 | | 0 | *0* | 0 | |
| Total** | 25 | *75.8* | 62 | 4 | 21 | *77.8* | 70 | 7 |

Notes: RC - (Re-) integrated into Community
SP/RC - Shelter Program then (Re-) integrated into Community
Blank - No Observations
* -Number of Individuals
** - Individuals talk about multiple coping strategies; therefore, counts are not additive.

ឧទាហរណ៍ខាងក្រោម គឺជាវិធីសាស្ត្រ និងយន្តការដោះស្រាយមួយចំនួនដែលជនរួចពីរងគ្រោះបានរៀបរាប់នៅពេលពួកគេប្រឈមជាមួយការមាក់ងាយ៖

- ⇨ *ខ្ញុំមានការផ្លាស់ប្តូរច្រើនណាស់។ ខ្ញុំរឹងមាំជាងមុន និងមិនឆាប់យំដូចមុនទេ។ ខ្ញុំព្យាយាមធ្វើខ្លួនខ្ញុំឲ្យរឹងមាំដើម្បីកុំឲ្យអ្នកដទៃមើលងាយខ្ញុំ។*
- ⇨ *សេចក្តីជំនឿ ពិតជាបានផ្លាស់ប្តូរខ្ញុំ ហើយបានធ្វើឲ្យខ្ញុំមានកម្លាំងចិត្តច្រើនជាងមុន។ នៅពេលខ្ញុំជួបនូវបញ្ហាលំបាក ខ្ញុំអធិដ្ឋានទៅព្រះជាម្ចាស់ ហើយទ្រង់បានឆ្លើយតបនឹងការអធិដ្ឋានរបស់ខ្ញុំ។*
- ⇨ *ខ្ញុំបានសម្រេចចិត្តរៀបការប្តីទី២របស់ខ្ញុំនៅក្នុងឆ្នាំ២០១២។ តាមពិត ប្តីរបស់ខ្ញុំបានតាមស្រលាញ់តាំងពីយូរមកហើយ។ ហើយគាត់មិនដែលទៅរៀបការស្រីផ្សេងទេ ព្រោះអីគាត់ចង់រៀបការជាមួយខ្ញុំ។ ដូច្នេះហើយ ខ្ញុំក៏សម្រេចចិត្តទទួលគាត់។ ជាក់ស្តែង យើងបានស្គាល់គ្នាទៅវិញទៅមកតាំងពីក្មេងៗមកម្ល៉េះ ព្រោះយើងរស់នៅក្នុងភូមិជាមួយគ្នា។ ទោះបីជាប្តីខ្ញុំបានដឹងពីប្រវត្តិពីអតីតកាលរបស់ខ្ញុំក៏ដោយ ក៏គាត់នៅតែស្រលាញ់ និងអាណិតខ្ញុំ។*

⇨ *រាល់យប់ខ្ញុំតែងមិនសូវលក់ទេ បើសិនជាខ្ញុំមិនញ៉ាំស្រាដោយសារខ្ញុំមានអារម្មណ៍តានតឹងជាមួយប្តីខ្ញុំពេក ព្រោះគាត់ឧស្សាហ៍មិនមកផ្ទះ ហើយបើសិនជាគាត់មកផ្ទះ គាត់បានវាយធ្វើបាបខ្ញុំ។*

នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះបានបញ្ជាក់យ៉ាងច្បាស់ថា ជនរួចពីរងគ្រោះពិតជាប្រឈមជាមួយនឹងការមាក់ងាយ។ ជនរួចពីរងគ្រោះមួយចំនួនមិនមែនជាជនរងគ្រោះដែលអស់សង្ឃឹមមិនធ្វើអ្វីទាំងអស់នោះទេ ប៉ុន្តែជំនួសមកវិញ ពួកគេខំប្រឹងប្រែងប្រឈមនឹងការមាក់ងាយទាំងនោះដោយប្រើប្រាស់វិធីសាស្ត្រ និងយន្តការផ្សេងៗជាច្រើន។ ជាក់ស្តែង ជនរួចពីរងគ្រោះខ្លះបានរៀនពីយន្តការដោះស្រាយបញ្ហាមួយចំនួនពីកម្មវិធីជំនួយ និងពីកម្មវិធីបណ្តុះបណ្តាលការងារ ហើយឥលូវនេះពួកគេក៏បានប្រើប្រាស់យន្តការទាំងនោះដើម្បីដោះស្រាយចំពោះការមាក់ងាយនៅក្នុងសហគមន៍របស់គេ។ នៅក្នុងការសិក្សាប៉ាន់ប្រមាណ យើងមិនបានកំណត់ថាតើវិធីសាស្ត្រមួយណាមានប្រសិទ្ធភាពជាងមួយណានោះទេ ដោយសារមិនមែនគ្រប់ជនរួចពីរងគ្រោះទាំងអស់សុទ្ធតែមានប្តី ឬសមាជិកគ្រួសារដែលគេអាចទុកចិត្តបាន និងមិនមែនពួកគេទាំងអស់គ្នាសុទ្ធត្រូវលាក់ប្រវត្តិពីអតីតកាលរបស់ពួកគេដែរ។ ប៉ុន្តែជាញឹកញាប់ យើងតែងតែសង្កេតឃើញថា ជនរួចពីរងគ្រោះបានជ្រើសរើសយកយុទ្ធសាស្ត្រក្នុងការ "គិតពិចារណាឲ្យល្អិតល្អន់ពីស្ថានភាពនីមួយៗ" ថាជាវិធីដែលមើលទៅហាក់ដូចជាមានប្រសិទ្ធភាពច្រើនជាងគេចំពោះការដោះស្រាយបញ្ហាការមាក់ងាយ។

ជាទូទៅ ស្ទើរតែគ្រប់យុទ្ធសាស្ត្ររបស់ជនរួចពីរងគ្រោះទាំងអស់នោះរួមមាន៖ ការលាក់ប្រវត្តិពីអតីតកាលពីមនុស្សមួយចំនួន (ឧទាហរណ៍៖ប្រាប់ប្រវត្តិតែចំពោះអ្នកខ្លះតែប៉ុណ្ណោះ)។ មានស្ត្រី/ក្មេងស្រីច្រើនគួរឲ្យគត់សម្គាល់ដែរ ដែលពួកគេបានប្រើប្រាស់វិធីសាស្ត្រនេះ និងបានចំណាយពេលមួយរយៈស្នាក់នៅក្នុងមណ្ឌល (ពី២ឆ្នាំទៅ៣ឆ្នាំ) ជាហេតុធ្វើឲ្យមនុស្សមួយចំនួនធំនៅក្នុងសហគមន៍ភ្លេចពីប្រវត្តិ/រឿងដែលបានកើតឡើងចំពោះពួកគេនៅពេលពួកគេធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍វិញ។ ជាការសំខាន់ ដែលពួកគេមានឱកាសក្នុងការចាប់ផ្តើមជីវិតរបស់គេម្តងទៀតជាមួយនឹងមនុស្សផ្សេងទៀតមួយចំនួន។ ជនរួចពីរងគ្រោះដែលមិនទៅស្នាក់នៅក្នុងកម្មវិធីមណ្ឌល និងមិនបានផ្លាស់ប្តូរលំនៅទៅកន្លែងមួយផ្សេងទៀត មើលទៅពួកគេហាក់ដូចជាមិនអាចរក្សាអតីតកាលរបស់ខ្លួនជាសម្ងាត់បានទេ ដោយសារមូលហេតុជាច្រើន។

វិធីសាស្ត្រមួយចំនួនត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយជាមួយនឹងបញ្ហា "ការមាក់ងាយខ្លួនឯង" ដូចជាវិធីសាស្ត្រ "ត្រូវតែរឹងមាំ" និងវិធីសាស្ត្រផ្សេងទៀតដូចជា "មានទំនុកចិត្ត និងមានការប្រុងប្រយ័ត្ន" គឺត្រូវបានប្រើប្រាស់ដើម្បីឆ្លើយបតទាំងបញ្ហា "ការមាក់ងាយខ្លួនឯងផង និងការរើសអើងសង្គមផង"។ ជនរួចពីរងគ្រោះដែលមានទំនុកចិត្ត និងប្រុងប្រយ័ត្ន ជាញឹកញាប់ពួកគេតែងតែធ្វើការគិតពិចារណាយ៉ាងល្អិត

ល្អន់មុនពេលគេសម្រេចចិត្តធ្វើអ្វីមួយ។ ហើយម្យ៉ាងទៀត ជាញឹកញាប់ពួកគេត្រូវបានពង្រឹងអំណាច និងមានគំនិតផ្តួចផ្តើមនៅពេលពួកគេជួបប្រទះនូវបញ្ហា និងការមាក់ងាយផ្សេងៗ។ អ្នកខ្លះទៀតវិញ គាត់បាន "ផ្តាច់ខ្លួន" ចេញពីចំណងដែលពាក់ព័ន្ធនឹងជីវិតនៅក្នុងវិស័យកម្សាន្ត តាមរយៈការផ្លាស់ប្តូរទីលំនៅ និងចាប់ផ្តើមជីវិតរបស់គេសារជាថ្មីម្តងទៀត ហើយគេចែករំលែករឿងប្រវត្តិពីអតីតកាលរបស់គេតិចតួចប៉ុណ្ណោះជាមួយមិត្តភក្តិ និងអ្នកជិតខាងរបស់គេ។

## ការយកឈ្នះលើការមាក់ងាយរបស់ជនរួចពីរងគ្រោះ

ក្រុមជនរួចពីរងគ្រោះមួយចំនួននៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ បានយកឈ្នះលើស្ថានភាពមាក់ងាយជាច្រើន ដែលពួកគេបានជួបប្រទះនៅក្នុងជីវិត។ ក្រុមនេះបានចែករំលែកចំនុចសំខាន់ៗរួមមួយចំនួនទាក់ទងនឹងបុគ្គលិកលក្ខណៈ និងគុណតម្លៃនៃភាពធន់។ គុណតម្លៃ និងបុគ្គលិកលក្ខណៈទាំងនេះត្រូវបានពិភាក្សាយ៉ាងលម្អិតដូចខាងក្រោម៖

<u>ការប្រាស្រ័យទាក់ទង</u> – ចំនុចដែលធ្វើឲ្យស្ថានភាពនៃការមាក់ងាយកាន់តែអាក្រក់ខ្លាំង គឺនៅពេលដែលមានការផ្តាច់ខ្លួនពួកគេចេញពីចំណោមក្រុមមនុស្សដោយបែងចែងរវាង "ពួកយើង និងពួកគេ"។ អ្នកដែលមានការប្រាស្រ័យទាក់ទងល្អ (ឧទាហរណ៍មានអ្នកជួយលើកទឹកចិត្ត និងមានមនុស្ស ដែលខ្លួនអាចទុកចិត្តបាន) មើលទៅហាក់ដូចជាមិនមានកម្រិតនៃ "ការផ្តាច់ខ្លួន" ដូចគ្នាទៅនឹងអ្នកដែលគិតថាពួកគេ "មិនមាននរណាម្នាក់ ដែលខ្លួនអាចទុកចិត្តបាន" នោះទេ។

បើប្រៀបធៀបលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណនេះ ទៅនឹងការសិក្សាពីគុណតម្លៃនៃភាពធន់ នៅក្នុងឆ្នាំ២០១៤ (មើលនៅក្នុងឯកសារយោង Morrison et al. 2014) បានបង្ហាញថា ជនរួចពីរងគ្រោះដែលអាច យកឈ្នះលើស្ថានភាពនៃការមាក់ងាយបាន ក៏បាននិយាយពីការលើកទឹកចិត្ត និងការទុកចិត្តរបស់ពួកគេជាមួយនឹងប្តី និង/ឬសមាជិកគ្រួសាររបស់ពួកគេដែរ។ ពួកគេទាំងអស់នោះមានបទពិសោធន៍ល្អជាមួយនឹងទំនាក់ទំនងដែលមានការទុកចិត្ត និងលែងទទួលនូវការរំលឹកម្តងហើយម្តងទៀតពីប្រវត្តិពីអតីតកាល និងការលំបាករបស់ពួកគេទៀតហើយ។ ការសិក្សារបស់ Gray (2012) បានពិព័ណ៌នាលក្ខណៈខុសគ្នានៃភាពធន់បែបវប្បធម៌ ឬលក្ខណៈពិសេសដែលយុវជនកម្ពុជាកំណត់ពី "ការផ្គត់ផ្គង់គ្រួសារ និងសហគមន៍" និង "ការទំនាក់ទំនង និងការផ្គត់ផ្គង់" ថាជាសមាសភាពដ៏សំខាន់ស្តីពីភាពធន់នៅក្នុងសង្គមកម្ពុជា។ ចំនុចនេះបានចាក់រឹសកប់យ៉ាងជ្រៅនៅក្នុងវប្បធម៌សង្គមកម្ពុជា និងជាចំនុចដែលត្រូវបានចាត់ទុកថាជារបៀបសមរម្យក្នុងការចុះសម្រុងជាមួយនឹងមនុស្សផ្សេងៗ នៅក្នុងសង្គម។ ជនរួចពីរងគ្រោះដែលត្រូវបានទទួលយកនៅក្នុងស្ថានភាពទាំងនេះ ដោយគិតថាបញ្ហាការមាក់ងាយមិនអាចរំខាន ឬគំរាមដល់គុណតម្លៃវប្បធម៌ដែលជាចំនុចមួយសំខាន់ជាងគេបំផុតនៅក្នុងជីវិតរបស់ពួកគេឡើយ។

កម្លាំងផ្លូវចិត្តខ្លាំង – ឃ្លា "ត្រូវតែរឹងមាំ" គឺជាឃ្លាមួយដែលជាទូទៅត្រូវបានប្រើប្រាស់សម្រាប់លើកទឹកចិត្តស្ត្រីនៅក្នុងសង្គមកម្ពុជានៅពេលពួកគេជួបនូវការលំបាកនានា។ នៅក្នុងផ្នែកខ្លះនៃឃ្លានេះប្រហែលជាបានកើតចេញពីការរំពឹងទុក និងតួនាទីយេនឌ័រជាប្រពៃណីថាស្ត្រីដែលរៀបការត្រូវតែ "រឹងមាំ" (Khun 2008)។ តែទោះជាយ៉ាងណា ឃ្លានេះក៏ជាឧទាហរណ៍គំរូល្អមួយស្តីពីយន្តការដោះស្រាយបញ្ហា ដែលជនរួចពីរងគ្រោះបានប្រើប្រាស់នៅពេលពួកគេប្រឈមនឹងបញ្ហាការមាក់ងាយខ្លួនឯង។ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រសង្គមប្រហែលជាអាចជ្រើសរើសពាក្យថា "ភាពធន់ផ្នែកផ្លូវចិត្ត" ដើម្បីពិព័ណ៌នាពីទម្រង់នៃភាពខ្លាំងខាងផ្នែកផ្លូវចិត្តទាំងនេះ។

មានការសិក្សាមួយចំនួនបានរៀបរាប់ពីសារៈសំខាន់នៃការធ្វើអន្តរាគមន៍បែបអាជីពក្នុងការពង្រឹង និងផ្តល់ឥទ្ធិពលល្អដល់ភាពធន់ផ្នែកផ្លូវចិត្ត និងការជាសះស្បើយឡើងវិញរបស់ជនរួចពីរងគ្រោះ ដោយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(Gozdziak et al. 2006; Abu-Ali and Al-Bahar 2011; Gray et al. 2012; Sobon 2015)។ ការសិក្សារបស់ Gray et al. (2012) បានផ្តល់អនុសាសន៍ថា ការអន្តរាគមន៍ដែលបង្កើននូវការគ្រប់គ្រង គឺជាមធ្យោបាយមួយក្នុងការពង្រឹងនូវភាពធន់ក្នុងពេលប្រឈមនឹងបញ្ហានៅពេលអនាគត ហើយបញ្ហាទាំងនេះភាគច្រើនទាក់ទងនឹងការមាក់ងាយ។ អ្នកនិពន្ធទាំងនេះបាន ផ្តល់អនុសាសន៍ថា ការធ្វើអន្តរាគមន៍គួរតែធ្វើទៅឲ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយនូវរោគសញ្ញានៃការបាក់ស្បាត និងគួរតែធ្វើទៅតាម "វិធីសាស្ត្រតាមអាយុសមរម្យដើម្បីបង្កើនការបំពេញមុខងារ ការគ្រប់គ្រង និងសមត្ថភាពផ្នែកចិត្តសាស្ត្រ បន្ថែមទៅលើការស្តារភាពធន់ទាំងអស់" (Gray et al. 2012: 368)។

ជាក់ស្តែង មានជនរួចពីរងគ្រោះជាច្រើននាក់បានបង្ហាញការអរគុណចំពោះសេវាប្រឹក្សាយោបល់ដែលពួកគេបានទទួលពីសំណាក់អង្គការ និងសមាកជិកគ្រួសាររបស់ពួកគេ។ អ្នកខ្លះបានរៀបរាប់ពីដំណើរការនៃការផ្លាស់ប្តូរទាក់ទងនឹងរបៀបនៃការគិតបានត្រឹមត្រូវ បានជួយសម្របសម្រួលដល់ការប្រាស្រ័យទាក់ទង និងបន្តកើតឡើងជាបន្តបន្ទាប់ក្នុងជីវិតរបស់ពួកគេនៅក្នុងសហគមន៍។

- ⇨ *ពីមុនខ្ញុំឧស្សាហ៍ស្តីបន្ទោសខ្លួនឯងញឹកញាប់ណាស់ ប៉ុន្តែឥលូវនេះខ្ញុំលែងស្តីបន្ទោសខ្លួនឯងហើយ។ ខ្ញុំដឹងច្រើនជាងមុន និងមានគំនិតថ្មីៗជាច្រើន ហើយខ្ញុំលែងសួរខ្វល់ពីបញ្ហាពីអតីតកាលរបស់ខ្ញុំទៀតហើយ។*
- ⇨ *ម្តាយរបស់ខ្ញុំយល់ពីខ្ញុំច្បាស់។ គាត់និយាយថា ខ្ញុំត្រូវតែធ្វើខ្លួនឲ្យរឹងមាំ។ ខ្ញុំមិនធ្លាប់ស្តាប់បង្គាប់គាត់ តែឥលូវខ្ញុំចេះស្តាប់បង្គាប់គាត់ហើយ។*
- ⇨ *ពេលលើកដំបូងដែលខ្ញុំជួបរឿងនៅតុលាការ ខ្ញុំខ្លាច ព្រោះខ្ញុំបានឃើញជនល្មើសនៅចំពីមុខខ្ញុំ ប៉ុន្តែខ្ញុំព្យាយាមប្រាប់ខ្លួនឯង។ ម្យ៉ាងទៀត ខ្ញុំព្យាយាមប្រាប់ខ្លួនឯងថា "ត្រូវតែរឹងមាំឡើង" ដើម្បី*

*កុំឲ្យពួកគេមើលដឹងថាខ្ញុំខ្លាចគេ ឬឃើញពីចំនុចខ្សោយរបស់ខ្ញុំ។ ដល់ពេលអញ្ចឹង ខ្ញុំឈប់ខ្លាចនៅពេលខ្ញុំបានទៅជួបពួកគេនៅតុលាការលើកក្រោយៗទៀត។*

⇨ *គ្រប់ៗគ្នាសុទ្ធតែមានតម្លៃ ទោះបីជាពួកគេធ្លាប់ធ្វើការនៅហាងខារ៉ាអូខេក្នុងរយៈពេលយូរដូចជា៥ឆ្នាំ ឬ១០ឆ្នាំក៏ដោយ ក៏ពួកគេនៅតែអាចរស់បាន ហើយពួកគេនៅតែមានតម្លៃ។ ពួកគេមិនមែនមកពីភក់ជ្រាំដូចមនុស្សមួយចំនួននិយាយនោះទេ។ វាមិនមែនជាការពិតទេ។ ទោះបីជាមនុស្សជាច្រើននិយាយថា ខ្ញុំធ្លាប់ធ្វើការនៅហាងខារ៉ាអូខេ ខ្ញុំមិនអាចជួបបុរសល្អទេ។ និយាយបែបនេះ វាមិនពិតទេ។ ប្រសិនបើអ្នកជឿទុកចិត្តលើខ្លួនឯង ហើយអ្នកនៅតែអាចធ្វើខ្លួនឲ្យរឹងមាំបាន អ្នកនៅតែអាចមានមនុស្សជាច្រើនដែលចង់ឃើញពីការរីកចំរើននៅក្នុងជីវិតរបស់អ្នក។*

<u>ការខំប្រឹងប្រែងធ្វើការ និងការតស៊ូ</u> – នៅពេលក្រុមស្រាវជ្រាវសុំឲ្យជនរួចពីរងគ្រោះផ្តល់អនុសាសន៍ តើអនុសាសន៍អ្វីដែលពួកគេនឹងផ្តល់ដល់អ្នកដទៃ ពួកគេភាគច្រើនឆ្លុះបញ្ចាំងទៅលើការខិតខំប្រឹងប្រែងធ្វើការ និងការតស៊ូ។ ការសិក្សាមួយចំនួននៅក្នុងប្រទេសកម្ពុជាបានបញ្ជាក់ថា ការខំប្រឹងធ្វើការ គឺជាផ្នែកមួយដ៏សំខាន់ទាក់ទងនឹងភាពធន់របស់ជនរួចពីរងគ្រោះដោយសាររបបខ្មែរក្រហម Muco (2013)។ ការសិក្សារបស់ Muco (2013) បញ្ជាក់ថា ឆន្ទៈក្នុងការខំប្រឹងធ្វើការបង្ហាញពីកម្លាំងជំរុញចិត្ត ដែលជនរួចពីរងគ្រោះត្រូវការដើម្បីទទួលជោគជ័យក្នុងជីវិត ដែលវាជាចំនុចមួយដ៏សំខាន់សម្រាប់ពួកគេក្នុងការដោះស្រាយជាមួយនឹងការប្រឈមនឹងបញ្ហាការមាក់ងាយខ្លួនឯង និងបញ្ហាការមាក់ងាយផ្សេងៗទៀត នៅក្នុងសហគមន៍។ ស្ត្រីរួចពីរងគ្រោះម្នាក់បានពន្យល់ពីសារៈសំខាន់នៃការខំប្រឹងធ្វើការ និងការតស៊ូដើម្បីប្រឈមនឹងការមាក់ងាយតាមរបៀបដូចខាងក្រោម៖

⇨ *ខ្ញុំចង់ប្រាប់ពួកគេថា ឲ្យពួកគេនៅតែបន្តដំណើរទៅមុខទៀត ទោះបីជាពួកគេជួបនូវបញ្ហានេះក៏ដោយ ប៉ុន្តែយើងត្រូវតែខំប្រឹងតស៊ូបន្ថែមទៀត។ ត្រូវគិតថា អនាគតរបស់យើងមិនទាន់ចប់ទេ ព្រោះយើងនៅមានជីវិតនៅឡើយ។ យើងត្រូវតែព្យាយាម និងមានសង្ឃឹម។ ជឿជាក់ និងពង្រឹងខ្លួនឯងដើម្បីមានអនាគតល្អ។ ទោះបីយើងបានជួបបញ្ហានេះ ប៉ុន្តែយើងបានដើរឆ្លងកាត់វារួចទៅហើយ។ ពេលខ្លះយើងមានអារម្មណ៍តានតឹងពីវា ប៉ុន្តែយើងត្រូវចាំថា យើងបានដើរឆ្លងកាត់វាផុតទៅហើយ។ វាជារឿងកន្លងផុតទៅហើយ។ អញ្ចឹង សូមព្យាយាមឲ្យខ្លាំងថែមទៀតដើម្បីអនាគតរបស់អ្នក។*

<u>រៀនជំនាញវិជ្ជាជីវៈ ឬធ្វើអាជីវកម្ម និងការខំប្រឹងធ្វើការឲ្យបានល្អប្រសើរនៅកន្លែងធ្វើការ</u> – ជនរួចពីរងគ្រោះដែលបានយកឈ្នះលើការមាក់ងាយ បាននិយាយប្រាប់ពីដំណើរការនៃការរៀនសូត្រ ឬការបណ្តុះ-បណ្តាលជំនាញវិជ្ជាជីវៈ ការស្វែងរកការងារល្អធ្វើ និងការបន្តរៀនសូត្រនូវជំនាញថ្មីៗ។ ជាញឹកញាប់ពួកគេបាននិយាយពីការចាប់ផ្តើមការងារថ្មី ហើយបន្ទាប់មកបានក្លាយជាអ្នកគ្រប់គ្រង ឬអ្នកបណ្តុះ-

បណ្តាល និងចាប់ផ្តើមបង្រៀនជំនាញដែលពួកគេចេះទៅអ្នកដទៃផ្សេងទៀត។ នៅពេលខ្លះចំនុចទាំងនេះបានកើតឡើងជាដំណើរ ច្រើនជាងមួយនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះ។ ដំណើរការនេះត្រូវបានមើលឃើញមិនត្រឹមតែតាមរយៈព័ត៌មាន ដែលពួកគេបានប្រាប់ដល់ក្រុមស្រាវជ្រាវប៉ុណ្ណោះទេ តែពេលខ្លះតាមរយៈភាសាកាយវិការ និងកម្រិតនៃទំនុកចិត្តរបស់ពួកគេក្នុងការឆ្លើយតបជាមួយនឹងសំនួរនៅពេលអ្នកស្រាវជ្រាវកំពុងសម្ភាសន៍។

<u>អារម្មណ៍ដឹងថាខ្លួន "បានទទួលកិត្តិយសមកវិញ" តាមរយៈការធ្វើសេចក្តីសម្រេចចិត្តនានា</u> – ចំនុចនេះគឺប្រហែលជាបុគ្គលិកលក្ខណៈសំខាន់ជាងគេបំផុតក្នុងការយកឈ្នះលើបញ្ហាការមាក់ងាយ ដែលជនរួចពីរងគ្រោះបាននិយាយប្រាប់ ព្រោះវាទាក់ទងនឹងទស្សនៈយល់ឃើញចំពោះខ្លួនឯងក្នុងការទទួលបាននូវកិត្តិយសមកវិញ។ វាមានសារៈសំខាន់ដូចគ្នាហ្នឹងដែរ ដែលការទទួលបាននូវអារម្មណ៍ "ទទួលបានកិត្តិយសមកវិញ" គឺត្រូវបានកើតឡើងដោយសារការធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងជីវិតរបស់ពួកគេ។ នៅពេលជនរួចពីរងគ្រោះនិយាយពីការផ្លាស់ប្តូរពី "ភាពគ្មានការងារធ្វើ" ឬ "ធ្វើការងារមិនល្អ" មកធ្វើ "ការងារល្អ" ឬនៅក្នុងស្ថានភាពផ្សេងទៀតដូចជា "បានរៀបការហើយ" និងអាចស្ថិតក្នុង "លទ្ធភាពអាចរៀបការបាន"។ អ្នកខ្លះបានរៀបរាប់ពីការពង្រឹងអំណាច និងខ្លះទៀតនិយាយពីការទទួលបានកិត្តិយសមក វិញ។ វប្បធម៌កម្ពុជាផ្តល់តម្លៃដល់អ្នកដែលបានរៀបការហើយ អ្នកមានមធ្យោបាយរកចវិការ និងអ្នកដែលមានចំណេះដឹង ឬជំនាញ។ ជនរួចពីរងគ្រោះគ្រប់វ័យ និងគ្រប់ស្ថានភាពអាពាហ៍ពិពាហ៍បាននិយាយរៀបរាប់ពីបរិបទនេះដូចខាងក្រោមៈ

- ⇨ *ខ្ញុំនឹងប្រាប់នាងថា អ្នកត្រូវតែខិតខំរៀនសូត្រ អ្នកមិនគួរដើរលេងទេ។ អ្នកត្រូវតែខំរៀនដើម្បីអនាគតរបស់អ្នក ដើម្បីបានធ្វើការនៅក្នុងការិយាល័យ និងធ្វើការនៅកន្លែងល្អៗ។*
- ⇨ *ខ្ញុំជឿជាក់ថា ខ្ញុំអាចផ្លាស់ប្តូរការគិតមិនល្អរបស់អ្នកជិតខាងមកលើរូបខ្ញុំ តាមរយៈការខិតខំប្រឹងប្រែងរៀនសូត្រ និងស្វែងរកការងារល្អធ្វើ។ វានឹងធ្វើឲ្យពួកគេឈប់និយាយដើមមិនល្អពីខ្ញុំ។ ឈប់និយាយពីការកេងប្រវ័ញ្ចផ្លូវភេទជារឿងអតីតកាលរបស់ខ្ញុំ។*
- ⇨ *ឥលូវខ្ញុំក្លាយជាមេគ្រួសារ (ជាអ្នករកលុយផ្គត់ផ្គង់គ្រួសារសំខាន់ជាងគេ)...នៅពេលម្តាយខ្ញុំ គាត់អត់មានលុយ គាត់តែរមកខ្ចីលុយខ្ញុំ។*
- ⇨ *ខ្ញុំមានគម្រោងបន្តការសិក្សារហូតដល់បានទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យ ដើម្បីឲ្យខ្ញុំអាចមានអនាគតភ្លឺស្វាង និងមានការងារល្អធ្វើ។ ដល់ពេលនោះ នឹងលែងមាននរណាហ៊ានមើលងាយខ្ញុំទៀតហើយ។ ហើយបន្ទាប់ពីខ្ញុំរៀបការ និងមានក្រុមគ្រួសារ ខ្ញុំនឹងមានអារម្មណ៍មានមោទនភាពចំពោះខ្លួនឯង។*

⇨ *និយាយដោយស្មោះត្រង់ទៅ ចំនុចប្រែប្រួលដែលសំខាន់ជាងគេបំផុតនៅក្នុងជីវិតខ្ញុំ គឺខ្ញុំបានមកធ្វើការនៅកន្លែងមួយ ដែលវាមិនជះឥទ្ធិពលអាក្រក់ដល់ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងមនុស្សដែលនៅជុំវិញខ្ញុំ។ ខ្ញុំធ្វើការនៅកន្លែងល្អ។ នេះគឺជាចំនុចសំខាន់ជាងគេបំផុត ដែលយើងធ្វើការនៅកន្លែងល្អ ហើយខ្ញុំក៏ចូលចិត្តធ្វើការនៅក្នុងអង្គការដែរ។ ខ្ញុំបានឈប់ធ្វើការនៅកន្លែងដែលខ្ញុំមិនគួរធ្វើហើយ។*

ស្រ្តីរួចពីរងគ្រោះម្នាក់ទៀតបានរៀបរាប់អំពីគោលគំនិតនេះ ដោយឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរការងាររបស់នាង ហើយសិទ្ធិក្នុងជីវិតអាពាហ៍ពិពាហ៍ទីពីររបស់នាង ដោយប្រៀបធៀបទៅនឹងជីវិតអាពាហ៍ពិពាហ៍ទីមួយរបស់នាង។ ក្នុងអំឡុងជីវិតអាពាហ៍ពិពាហ៍ដំបូងរបស់នាង នាងមានប្រាក់ខែតាមរយៈការធ្វើការជាមួយ អង្គការមួយកន្លែង ប៉ុន្តែសព្វថ្ងៃនេះ នាងបានរៀបការលើកទី២ ហើយនាងគ្មានប្រាក់ខែទៀតទេ តែនាងនៅតែធ្វើការ ដើម្បីផ្គត់ផ្គង់គ្រួសារដដែលដោយនាងជួយការងាររអាជីវកម្មរបស់ឪពុកម្តាយក្មេករបស់នាង។

⇨ *ប្រសិនបើខ្ញុំប្រៀបធៀបស្ថានភាពបច្ចុប្បន្នទៅនឹងពេល ដែលខ្ញុំកំពុងធ្វើការជាមួយនឹងអង្គការ ខ្ញុំចង់ត្រលប់ទៅពេលវេលាកាលពេលនោះវិញ។ ខ្ញុំមិនចូលចិត្តស្ថានភាពសព្វថ្ងៃនេះទេ ព្រោះអីខ្ញុំរស់នៅជាមួយប្តីខ្ញុំ និងគ្រួសាររបស់គាត់។ ឪពុកម្តាយប្តីខ្ញុំធ្វើការរកស៊ីដើម្បីផ្គត់ផ្គង់គ្រួសារខ្ញុំដែរ ហើយនេះជាមូលហេតុដែលធ្វើឲ្យអ្នកផ្សេងទៀតនៅក្នុងគ្រួសារប្តីខ្ញុំមើលងាយខ្ញុំ និងប្រើពាក្យសម្តីគំរោះគំរើយដាក់ខ្ញុំ ដែលធ្វើឲ្យខ្ញុំមិនសប្បាយចិត្តពេលខ្លះ។ ខ្ញុំបានប្រាប់ប្តីទីពីរខ្ញុំថា នៅពេលខ្ញុំរស់នៅជាមួយប្តីទី១ ខ្ញុំមិនដែលខ្លាចក្នុងការនិយាយស្តីអីទៅកាន់គាត់ទេ ព្រោះខ្ញុំធ្វើការ (ធ្វើជាមួយអង្គការ) និងរកលុយដើម្បីផ្គត់ផ្គង់កូនរបស់ខ្ញុំ ប៉ុន្តែឥលូវខ្ញុំពឹងផ្អែកលើគ្រប់គ្នា ហើយអញ្ចឹងខ្ញុំមិនអាចនិយាយអ្វីបានទាំងអស់។*

ជនរួចពីរងគ្រោះដែលអាចយកឈ្នះលើការមាក់ងាយ អាចនឹងនិយាយទាំងមានកិត្តិយសនៅពេលពួកគេនិយាយពីជីវិតរបស់ពួកគេ ឬក៏ពួកគេអាចនិយាយពីដំណើរការដែលពួកគេគិតថា ពួកគេបានទទួលកិត្តិយសមកវិញ តាមរយៈការសម្រេចចិត្តរបស់ពួកគេ។

## 5.0 លទ្ធផលនៃការសិក្សា និងអនុសាសន៍

លទ្ធផលនៅក្នុងការសិក្សាប៉ាន់ប្រមាណ បានបែងចែកសមាសភាពសំខាន់ៗនៃការមាក់ងាយជាប្រព័ន្ធ និងចងក្រងជាឯកសារទាក់ទងនឹងការដាក់ងារអវិជ្ជមាន ផ្នត់គំនិតអវិជ្ជមានបែបវប្បធម៌ ក្រុមអ្នកមាក់ងាយសំខាន់ៗ និងបទពិសោធន៍នៃរើសអើងមួយចំនួន ដែលជនរួចពីរួចពីរងគ្រោះជួបប្រទះក្នុងរយៈពេលវែងនៅពេលពួកគេរស់នៅក្នុងសហគមន៍។ ជនរួចពីរួចពីរងគ្រោះបានពិភាក្សាពីការប្រឈមជាមួយ

នឹងការមាក់ងាយសង្គមនៅពេលមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់ពួកគេពីមួយឆ្នាំទៅមួយឆ្នាំ។ ពួកគេបានផ្តល់ "សម្លេង" របស់ពួកគេ គឺមិនមែនសម្រាប់តែធ្វើការតវ៉ាទៅនឹងការមាក់ងាយ និងវិសមភាពដែលជាញឹកញាប់ពួកគេបានប្រឈមតែប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងផ្តល់ "សម្លេង" នេះ ដើម្បីលើកទឹកចិត្តដល់អ្នកផ្សេងៗទៀត ឲ្យពួកគេប្រឈមនឹងបញ្ហាការមាក់ងាយ និងរើសអើង និងឲ្យពួកគេតស៊ូដើម្បីយកឈ្នះលើការលំបាកៗទាំងនេះនៅក្នុងជីវិត។ តាមរយៈការផ្សព្វផ្សាយពី "សម្លេង" របស់ពួកគេ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ អង្គការសម្ព័ន្ធចាប់ដៃយើងសង្ឃឹមជឿជាក់ថា កម្មវិធី និងគោលនយោបាយធ្វើសមាហរកម្មនានានឹងទទួលបានព័ត៌មាន និងមានភាពវិវឌ្ឍន៍ទៅមុខដើម្បីឲ្យជីវិតរបស់ជនរួចពីការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទ មានភាពប្រសើរឡើងទាំងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងទូទាំងពិភពលោក។

ខាងក្រោម គឺជាអនុសាសន៍មួយចំនួនដែលបានចងក្រងឡើងយោងទៅតាមលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណនេះ៖

1. **លទ្ធផលនៃការសិក្សា៖** ប្រធានបទសំខាន់ៗដូចជាវិសមភាពយេនឌ័រ លទ្ធភាពអាពាហ៍ពិពាហ៍ និងស្ថានភាពសេដ្ឋកិច្ចសង្គម គឺត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈប្រវត្តិសាច់រឿងរបស់ជនរួចពីរងគ្រោះ ដែលពួកគេបានរៀបរាប់ពីបញ្ហាការមាក់ងាយការដាក់ងារអវិជ្ជមាន និងការធ្លាក់ចុះ និងកើនឡើងនូវឋានៈសង្គម។
   **អនុសាសន៍៖** លទ្ធផលនៃការសិក្សានេះ បានផ្តល់អនុសាសន៍ដល់អ្នកកាន់ករណី (caseworkers) និងអ្នកប្រឹក្សាយោបល់ (counselors)។ ការជួយជនរួចពីរងគ្រោះឲ្យបានយល់ពីការមាក់ងាយ និងគំនិតបែបមាក់ងាយខ្លួនឯង គឺជាដំណាក់កាលដ៏សំខាន់មួយក្នុងការបង្កើតវិធីសាស្ត្រ ដើម្បីប្រឈមជាមួយនឹងបញ្ហាទាំងនោះ។ ការពិភាក្សាពីប្រធានបទទាំងនេះ និងវិធីសាស្ត្រដោះស្រាយជាមួយនឹងសមាសភាពផ្សេងៗគ្នានៃការមាក់ងាយ (ឧទាហរណ៍ដូចជាការដាក់ងារអវិជ្ជមាន ផ្នត់គំនិតអវិជ្ជមាន និងការបាត់បង់នូវឋានៈសង្គម) នឹងជួយរៀបចំជនរួចពីរងគ្រោះ នៅពេលពួកគេធ្វើសមាហរណកម្មត្រលប់ទៅរស់នៅក្នុងសហគមន៍របស់ពួកគេវិញ។

2. **លទ្ធផលនៃការសិក្សា៖** ពេលខ្លះជនរួចពីរងគ្រោះបានប្រឈមនឹងគំនិតបែបមាក់ងាយខ្លួនឯងរួចទៅហើយនៅក្នុងអំឡុងពេលដែលពួកគេត្រូវបានគេជួញដូរ ឬកេងប្រវ័ញ្ចផ្លូវភេទ។ នៅខណៈពេលនោះពួកគេបានដឹងខ្លួនឯងរួចជាស្រេចថា ពួកគេអាចនឹងប្រឈមជាមួយនឹងបញ្ហា ការដាក់ងារអវិជ្ជមាន និងផ្នត់គំនិតអវិជ្ជមានមកលើពួកគេ នៅពេលដែលជីវិតរបស់ពួកគេបានផ្លាស់ប្តូរនៅក្នុងស្ថានភាពបែបនេះ។ ការជ្រាបដឹងដោយខ្លួនឯងពីបញ្ហាការមាក់ងាយជាមុន អាចជះ

ឥទ្ធិពល និងអាចធ្វើឲ្យគំនិតបែបរើសអើងខ្លួនឯងរបស់ពួកគេកើតមានកាន់តែច្រើនឡើងថែមទៀត ហើយវាក៏អាចជះឥទ្ធិពលទៅលើការសម្រេចចិត្ត ការផ្លាស់ប្តូរនៅក្នុងជីវិត និងឱកាសមួយចំនួនរបស់ពួកគេដែរ។

**អនុសាសន៍៖** លទ្ធផលនៃការសិក្សានេះ បានផ្តល់អនុសាសន៍ដល់បុគ្គលិកធ្វើការនៅក្នុងស្ថាប័នអង្គការក្រៅរដ្ឋាភិបាល និងមន្ទីរក្រសួងរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់។ ការយល់ដឹង និងការចាប់អារម្មណ៍ស្តីពីបញ្ហាមាក់ងាយវប្បធម៌របស់បុគ្គលិក ក៏ដូចគ្នានឹងកម្មវិធីផ្តល់សេវាប្រឹក្សាយោបល់ដែលធ្វើការដើម្បីឆ្លើយតបនឹងបញ្ហាការមាក់ងាយខ្លួន គឺជាសមាសភាពដ៏សំខាន់របស់អង្គការដែលធ្វើការទាក់ទងនឹងការថែទាំមូលដ្ឋាន។ ការយល់ដឹងពីបញ្ហាប្រឈមនឹងការមាក់ងាយខ្លួនឯងរបស់ជនរួចពីរងគ្រោះ ការជ្រាបដឹងដោយខ្លួនឯងពីការមាក់ងាយអាចជះឥទ្ធិពលលើការសម្រេចចិត្ត និងការមាក់ងាយខ្លួនឯងដែលអាចធ្វើឲ្យមានផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តកើតមានកាន់តែច្រើន គឺជាចំណុចដែលគួរពិចារណាសំខាន់ៗនៅក្នុងការប៉ាន់ប្រមាណបឋម និងផែនការថែទាំចំពោះជនរួចពីរងគ្រោះ ទោះបីជាគ្មានសញ្ញាណាណាមួយលេចចេញមកខាងក្រៅក៏ដោយ។

3. **លទ្ធផលនៃការសិក្សា៖** ជនរួចពីរងគ្រោះភាគច្រើនបានពិព័ណ៌នាពីជីវិត និងបទពិសោធន៍ទទួលរងនូវការមាក់ងាយដែលមានភាពប្រែប្រួល និងស្មុគស្មាញ។ ការសិក្សាពីការមាក់ងាយនៅក្នុងឆ្នាំជាបន្តបន្ទាប់នៃការធ្វើសមាហរណកម្មបានបញ្ជាក់ឲ្យឃើញថា នៅក្នុងឆ្នាំទី១ អត្រាប្រេវ៉ាឡង់នៃការមាក់ងាយមានភាគរយទាបជាងគេបំផុត។

   **អនុសាសន៍៖** លទ្ធផលនៃការសិក្សានេះ បានផ្តល់អនុសាសន៍ដល់ប្រធានរៀបចំកម្មវិធី នៅពេលពួកគេគិតពិចារណាពីវិសាលភាព និងរយៈពេលគម្រោងក្នុងការធ្វើសមាហរណកម្ម និងតាមដានជនរួចពីរងគ្រោះនៅក្នុងសហគមន៍។ ចំនុចទាំងអស់នោះរួមមានដូចជា៖ ១.កម្មវិធីធ្វើសមាហរណកម្ម និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអាចមានឥទ្ធិពលជាវិជ្ជមានក្នុងការកាត់បន្ថយការមាក់ងាយនៅក្នុងជីវិតរស់នៅរបស់ជនរួចពីរងគ្រោះ នៅក្នុងឆ្នាំទី១ បន្ទាប់ពីធ្វើសមាហរណកម្ម និង២.ស្ថានភាពនៃការមាក់ងាយខ្លាំង អាចកើតឡើងនៅក្នុងឆ្នាំជាបន្តបន្ទាប់។

4. **លទ្ធផលនៃការសិក្សា៖** បន្ទាប់ពីធ្វើសមាហរណកម្មជនរួចពីរងងគ្រោះ គឺបានជ្រាបដឹងពីការមាក់ងាយយ៉ាងខ្លាំងទាក់ទងទៅនឹង "លទ្ធភាព" អាចរៀបការ អាចលែងលះ ឬសម្រាប់អ្នកខ្លះអាចទាក់ទងនឹងការរៀបការម្តងទៀតដែរ។ ជនរួចពីរងគ្រោះដែលនៅលីវ បាននិយាយរៀបរាប់ពីការប្រឈមតតាំងជាមួយនឹងការមាក់ងាយ ទាក់ទងនឹងលទ្ធភាពនៃការរៀបការ។ ជនរួចពីរងគ្រោះមួយចំនួនទៀតដែលមានទំនាក់ទំនងពោរពេញដោយអំពើហិង្សា និងការរំលោភបំពាន

មានការប្រឈមជាមួយនឹងការមាក់ងាយទាក់ទងនឹងបញ្ហាយេនឌ័រ និងការមាក់ងាយបែបវប្បធម៌ប្រពៃណីទាក់ទងនឹងជម្រើសក្នុងការសម្រេចចិត្តផ្សេងៗដូចជាការសម្រេចចិត្តលែងលះជាដើម។

**អនុសាសន៍៖** លទ្ធផលនៃការសិក្សាត្រង់ចំនុចនេះ បានផ្តល់អនុសាសន៍ដល់បណ្តាអង្គការក្រៅរដ្ឋាភិបាល និងមន្ទីរក្រសួងរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងការថែទាំមូលដ្ឋាន។ ការរៀបអាពាហ៍ពិពាហ៍ គឺជាព្រឹត្តិការណ៍វប្បធម៌សង្គមដ៏សំខាន់មួយនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះ។ វគ្គបណ្តុះបណ្តាល និងការពិភាក្សានានាស្តីអំពីការកសាងទំនាក់ទំនងដៃគូ ការដោះស្រាយជម្លោះ ការពង្រឹងអំណាចនៅក្នុងជីវិតអាពាហ៍ពិពាហ៍ និងវិធីសាស្ត្រនានាក្នុងការប្រឈមនឹងបញ្ហាវិសមភាពយេនឌ័រ អាពាហ៍ពិពាហ៍ គឺត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងឲ្យអនុវត្ត។ ចំនុចសំខាន់ដែលត្រូវគិតពិចារណាមួយទៀត គឺការលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់ និងការការពារដែលទទួលបានពីការចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ នៅក្នុងសៀវភៅអត្រានុកូលដ្ឋានសង្គមស៊ីវិល។ ស្ទើរតែគ្មានជនរួចពីរងគ្រោះណាម្នាក់នៅក្នុងការសិក្សាប៉ាន់ប្រមាណរបស់យើងនេះ សម្រេចជ្រើសរើសយកជម្រើសមួយនេះទេ។ ស្ត្រី/ប្រពន្ធដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ គឺមិនត្រូវបានធានាពីសិទ្ធិរបស់ពួកគេទៅលើសិទ្ធិទទួលបានទ្រព្យសម្បត្តិគ្រួសារ ទ្រព្យសម្បត្តិរកបាននៅក្នុងចំណងអាពាហ៍ពិពាហ៍ សោធនអាហារកិច្ចដៃគូ និងការផ្គត់ផ្គង់កូន...ជាដើមឡើយ។

5. **លទ្ធផលនៃការសិក្សា៖** ជាទូទៅ លទ្ធផលនៃការសិក្សាប៉ាន់ប្រមាណបង្ហាញថាកម្រិត និងអាំងតង់ស៊ីតេនៃការមាក់ងាយកើនឡើង នៅពេលដែលជនរួចពីរងគ្រោះទទួលរងនូវបទពិសោធន៍រើសអើងច្រើនទម្រង់ផ្សេងគ្នា ហើយការរើសអើងនោះនៅតែបន្តកើតឡើងម្តងហើយម្តងទៀតក្នុងរយៈពេលជាច្រើនឆ្នាំ។ អាំងតង់ស៊ីតេ និងកម្រិតនៃការមាក់ងាយនេះក៏អាចក្លាយជាធ្ងន់ធ្ងរទៅៗបានដែរ នៅពេលដែលពួកគេចាប់ផ្តើមមានធនធានកាន់តែតិចទៅៗដូចជាធនធានសង្គមដែលអាចទុកចិត្តបាន (ឧទាហរណ៍៖មិត្តភក្តិ ឬសមាជិកគ្រួសារ) និងទីកន្លែងសុវត្ថិភាពនៅក្នុងសហគមន៍ (ឧទារហណ៍៖ផ្ទះសាច់ញាតិ និងផ្ទះអ្នកជិតខាង ឬទីកន្លែងធ្វើការជាដើម)។

   **អនុសាសន៍៖** លទ្ធផលនៃការសិក្សានេះបានផ្តល់អនុសាសន៍សម្រាប់ការអនុវត្តន៍ផ្ទាល់ចំពោះអ្នកកាន់ករណី (caseworkers) និងប្រធានរៀបចំគម្រោងនូវចំនុចសំខាន់មួយចំនួនក្នុងការប៉ាន់ប្រមាណទៅលើបញ្ហាការមាក់ងាយ និងការរើសអើងចំពោះជនរួចពីរងគ្រោះ នៅក្នុងសហគមន៍។ ចំនុចទាំងអស់នោះរួមមានដូចខាងក្រោម៖

- ស្វែងរកមធ្យោបាយដើម្បីធ្វើការ និងពិភាក្សាពីបញ្ហាការមាក់ងាយដែលមិនបន្ត ឬ "ពង្រឹង" ឲ្យមាន "ការដាក់ងារអវិជ្ជមាន" កើតឡើងទៀត
- ធ្វើការប៉ាន់ប្រមាណគ្រួសារដោយបញ្ជាក់ឲ្យបានច្បាស់ពីបញ្ហាសំខាន់ៗ ទាក់ទងនឹងការមាក់ងាយ ហើយប្រសិនជាអាច ត្រូវប្រើប្រាស់កម្មវិធីលើកកម្ពស់ការយល់ដឹងដើម្បីកាត់បន្ថយបញ្ហាការមាក់ងាយនេះ។
- ធ្វើការតាមដានជនរួចពីរងគ្រោះក្នុងរយៈពេល៦ខែទៅ១ឆ្នាំ បន្ទាប់ពីពួកគេបានរៀបការ (ឬមានដៃគូ) ជាពិសេស សម្រាប់ជនរួចពីរងគ្រោះដែលរស់នៅជាមួយនឹងឪពុកម្តាយក្មេក ហើយមិនមានការងារធ្វើ ឬធ្វើការនៅផ្ទះជាមួយអាជីវកម្មគ្រួសាររបស់ពួកគេ។
- ជួយជនរួចពីរងគ្រោះ ដែលកំពុងប្រឈមជាមួយនឹងការមាក់ងាយក្នុងការកំណត់ពីទីកន្លែងសុវត្ថិភាព និងធនធានសង្គមដែលខ្លួនអាចទុកចិត្តបាន។

6. **លទ្ធផលនៃការសិក្សា៖** ការមាក់ងាយត្រូវបានមើលឃើញថា វាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាព។ នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ បានបញ្ជាក់ថាជនរួចពីរងគ្រោះបានប្រឈមជាមួយនឹងបញ្ហានៃការមាក់ងាយដែលមានកម្រិត និងអាំងតង់ស៊ីតេផ្សេងៗគ្នា។ ហើយនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ យើងក៏មិនដឹងច្បាស់ដែរថាតើ ការមាក់ងាយ វាបានជះឥទ្ធិពលទៅដល់បញ្ហាសុខភាពផ្លូវចិត្ត និងសុខភាពរាងកាយរបស់ជនរួចពីរងគ្រោះដល់កម្រិតណានោះទេ។

   **អនុសាសន៍៖** ការយល់ដឹងអំពីទំនាក់ទំនងទាំងនេះ បានផ្តល់អនុសាសន៍ដល់ប្រធានគម្រោង និងក្រសួងរដ្ឋាភិបាល។ ការសិក្សាស្រាវជ្រាវលើនេះថែមទៀតទៅលើសូចនាករស្តីអំពីការមាក់ងាយពីសង្គម និងខ្លួនឯង សូចនាករសុខភាពផ្លូវចិត្ត និងផ្លូវកាយនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះអំឡុងពេលបន្ទាប់ពីការធ្វើសមាហរណកម្ម នឹងជួយឲ្យយើងយល់កាន់តែស៊ីជម្រៅបន្ថែមទៀតអំពីអន្តរកម្មទំនាក់ទំនងទាំងនេះ។ ការសិក្សាស្រាវជ្រាវបន្ថែមទៀតលើបញ្ហានេះនាពេលអនាគត អាចនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រធានគម្រោង និងមន្ទីរក្រសួងរដ្ឋាភិបាលក្នុងការដែលពួកគេធ្វើការតាមដានទៅលើជីវិតរបស់ជនរួចពីរងគ្រោះ និងប៉ាន់ប្រមាណពីតម្រូវការ និងសេវាថែទាំសំខាន់ៗមួយចំនួនដល់ពួកគេ។

7. **លទ្ធផលនៃការសិក្សា៖** ជនរួចពីរងគ្រោះដែលអាចយកឈ្នះលើការមាក់ងាយ បាននិយាយទាំងមានទំនុកចិត្តនៅពេលពួកគេរៀបរាប់ពីជីវិតរបស់ពួកគេ។ ជាញឹកញាប់ ពួកគេនិយាយអំពី

ដំណើរការដែលពួកគេគិតថា ពួកគេបាន “ទទួលកិត្តិយស” មកវិញ តាមរយៈការសម្រេចចិត្តនានារបស់ពួកគេ។

**អនុសាសន៍៖** ទាំងកម្មវិធីមណ្ឌលស្នាក់នៅ និងផ្ទះស្នាក់នៅបណ្តោះអាសន្ន គួរតែគិតពិចារណាក្នុងការបង្កើតផែនការ ដើម្បីបណ្តុះបណ្តាលពីយន្តការដោះស្រាយជាមួយនឹងការមាក់ងាយទៅដល់ជនរួចពីរងគ្រោះ។ ចំនុចទាំងអស់នោះមានរួមដូចជា៖ ជួយពួកគេក្នុងការបង្កើតទំនាក់ទំនងដៃគូដែលចេះគាំទ្រ និងជួយគ្នាទៅវិញទៅមក ស្វែងរកមធ្យោបាយល្អៗក្នុងការប្រឈមនឹងគំនិតបែប មាក់ងាយខ្លួនឯង ជួយឲ្យពួកគេបានបញ្ចប់ការអប់រំ និង/ឬរៀននូវជំនាញដែលអាចរកការងារបាន ជួយឲ្យពួកគេអាចកំណត់ពីធនធានសុវត្ថិភាពនានា ដែលពួកគេអាចពឹងពាក់បាននៅពេលអនាគត ប្រសិនបើពួកគេជួបប្រទះនូវអំពើហិង្សាក្នុងគ្រួសារនៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។